ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ថ្ងៃកាត់ទោសមេគុកទួលស្លែង គឺជារបត់របស់កម្ពុជា
- មួយពាន់សំឡេង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១១១ ខែមីនា ឆ្នាំ២០០៩

# ស្វែងរកការពិត

លេខ១១១ ខែមីនា ឆ្នាំ២០០៩

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ថ្ងៃកាត់ទោសមេគុកទួលស្លែង គឺជារបត់របស់កម្ពុជា ..........១

**ផ្នែកឯកសារ**

◆លឹម លី: ប្រធានសេដ្ឋកិច្ចកងពលទី២ភាគពាយ័ព្យ ..........២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ជនរងគ្រោះកំពុងរង់ចាំភាពយុត្តិធម៌ ..........៥

◆សវនាការបឋមរបស់ ឌុច ..........៦

◆មួយពាន់សំឡេង ..........១៣

◆ព័ត៌មានជ័យជម្នះដែលឈ្នះដោយកងទ័ពបដិវត្តន៍..........១៨

**ផ្នែកច្បាប់**

◆ការស៊ើបអង្កេតរបស់តុលាការលើករណី ឌុច ..........២១

◆សេចក្ដីប្រកាសព័ត៌មាន..........២៦

◆សេចក្ដីប្រកាសព័ត៌មាន..........២៨

**វេទិកាពិភាក្សាសាធារណៈ**

◆គម្រោងដំណើរការកាត់សេចក្ដីរបស់អង្គជំនុំជម្រះ ..........៣០

◆តើមានចុងចោទប៉ុន្មាននូបដែលថាច្រើនក្នុងសាលាក្ដីកាត់ទោស ..........៣៧

◆នួន ជា កាលពីក្មេងនៅទីក្រុងបាងកក (១៩៤២-១៩៥០) ..........៣៩

◆រឿងល្ខោននិយាយៈ ទម្លាយភាពស្ងប់ស្ងាត់ ..........៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆មួយជីវិតនឹកឃើញជានិច្ច ..........៥៦



ឈុតមួយនៃការសម្តែងក្នុងរឿងទម្លាយភាពស្ងប់ស្ងាត់



ឈុតមួយនៃការសម្តែងក្នុងរឿងទម្លាយភាពស្ងប់ស្ងាត់

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នាលេខនេះ :** ដួង សុភារិទ្ធ, ស៊ីរ៉ិ សាវីណា, ជី ទេរិទ្ធ, ទីលី នីម, ថាយលី នីមស៍, ដេវីដ សេហ៊ុរ, អ៊ីជី មូ៉រ៉ាស្សុីម៉ា, សើ សាយ្យាណា និង អ៊ុង វណ្ណា **អ្នកនិពន្ធនិងស្រាវជ្រាវ :** គាត លក្ខិណា, សោម ប៊ុនថន, ស៊ុន សុធីតា, ទេស ម៉ារ៉ែម **អ្នកបកប្រែៈ** ជា ដល្លា **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ទេព ម៉េងឃាន **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ម៉ម សុជាត Email: dccam@online.com.kh, Homepage: www.dccam.org

***សំបុត្រ៖***

# ថ្ងៃកាត់ទោសមេគុកទួលស្លែង គឺជារបត់របស់កម្ពុជា

*ថ្ងៃ៣០ មីនា ២០០៩ គឺជាចំណុចរបត់មួយរបស់ប្រទេសកម្ពុជា ។ ថ្ងៃនេះក្រោយពីបានរង់ចាំអស់រយៈពេល៣០ឆ្នាំ ប្រជាជនកម្ពុជាបានធ្វើដំហានប្រវត្តិសាស្ត្រមួយ ។ តាមរយៈមធ្យោបាយផ្លូវច្បាប់ យើងកំពុងប្រឈមមុខនឹងវប្បធម៌នៃការរួចទោសនិងកំពុងដើរទៅមុខនៅក្នុងដំណើរដ៏វែងរបស់យើង ដើម្បីទាមទារយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍ ។ ដំណើរនេះទាមទារឲ្យយើងរួបរួមគ្នាជាប្រជាជាតិមួយ ។ តុលាការខ្មែរក្រហមគឺមិនមែនសម្រាប់តែយុត្តិធម៌ប៉ុណ្ណោះទេ តុលាការនេះគឺដើម្បី «ការចងចាំរបស់ជាតិយើង» ផងដែរ ។*

*ការវិនិច្ឆ័យទោសរបស់ ឌុច នៅថ្ងៃនេះ ផ្តល់ឱកាសមួយសម្រាប់ជនរងគ្រោះនិងប្រជាជនកម្ពុជាទាំងអស់ដែលកើតក្រោយរបបខ្មែរក្រហមបានរៀនសូត្រអំពីសម័យកាលដ៏ជូរចត់នៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសយើង ពីអ្នកដែលបានជាប់ពាក់ព័ន្ធនៅក្នុងរបបនេះដ៏ផ្ទាល់ ។ អ្វីដែលបានកើតឡើងពិតប្រាកដជាមានចម្លើយលើសពីមួយ ។ ក៏ប៉ុន្តែយើងទាំងអស់គ្នាមានកាតព្វកិច្ចចូលរួមនៅក្នុងតុលាការស្វែងរកការពិត ។ ជាមួយគ្នា យើងអាចបង្កើតឲ្យមានការយល់ដឹងឲ្យកាន់តែច្បាស់អំពីអតីតកាលរួមរបស់យើង ។*

*ប្រទេសកម្ពុជា គឺជាប្រទេសដែលមានរបួសយ៉ាងជ្រៅមួយក្រោយពីបានឆ្លងកាត់សង្គ្រាម និងអំពើប្រល័យពូជសាសន៍អស់រយៈពេលជាច្រើនឆ្នាំ ។ ប្រទេសយើងធ្លាប់ជាប្រទេសដែលបែកបាក់អស់រយៈពេលជាច្រើនទសវត្សរ៍ ដូច្នេះយើងទាំងអស់គ្នាមានការខ្វាយខ្វល់ដូចគ្នាចំពោះអនាគតនៃប្រទេសកម្ពុជារបស់យើងនិងកេរដំណែលដែលយើងនឹងបន្សល់ទុកឲ្យកូនចៅជំនាន់ក្រោយ ។ ប្រទេសកម្ពុជាត្រូវការដំណើរការផ្នែកច្បាប់មួយដែលគួរឲ្យទុកចិត្តបាន ដែលជួយឲ្យយើងមានការជឿជាក់ឡើងវិញទៅលើយុត្តិធម៌ ។ លើសពីនេះ យើងត្រូវការឲ្យមានដំណើរការមួយទៀតដែលជួយឲ្យយើងគិតថា យើងជាអ្នកកំណត់ប្រវត្តិសាស្ត្ររបស់ខ្លួន ។*

*ជនរងគ្រោះមានកាតព្វកិច្ចទទួលខុសត្រូវ និងជួយឲ្យដំណើរការរបស់តុលាការខ្មែរក្រហមទទួលបានជោគជ័យ តាមរយៈការបកស្រាយអំពីអំពើឃោរឃៅដែលខ្លួនបានទទួលនិងតាមរយៈការរៀបរាប់អំពីប្រវត្តិសាស្ត្រដែលខ្លួនបានដឹងឮ ។ ដំណើរការនេះគឺជាជំហានទៅមុខដ៏សំខាន់មួយសម្រាប់ការព្យាបាលរបួសរបស់ជាតិយើង ។ ការផ្សះផ្សាជាតិគឺមិនមែនជាដំណើរការមួយដែលមានតែជនរងគ្រោះ ឬអ្នកដែលឈ្នះសង្គ្រាមតែប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវការឲ្យមានជនដៃដល់ចូលរួមថែមទៀតផង ។ អ្នកដែលធ្លាប់ធ្វើជាសត្រូវនឹងគ្នាអាចផ្សះផ្សាគ្នាបានយ៉ាងពិតប្រាកដ ប្រសិនបើភាគីទាំងពីរមានការស្មោះត្រង់នឹងគ្នា ។*

*ខ្ញុំសង្ឃឹមថា រាជរដ្ឋាភិបាលកម្ពុជានឹងធ្វើយ៉ាងណាឲ្យប្រជាជនកម្ពុជាអាចចូលរួមនៅក្នុងដំណើរការកាត់ក្តី តាមរយៈការជំរុញឲ្យប្រព័ន្ធសារព័ត៌មានទូទាំងប្រទេសចាក់ផ្សាយដំណើរការកាត់ក្តីរបស់តុលាការ ។ ខ្ញុំក៏សង្ឃឹមដែរថា រាជរដ្ឋាភិបាលកម្ពុជានឹងប្រកាសឲ្យមានថៃ្ងសម្រាកជាតិមួយ ដើម្បីអនុញ្ញាតឲ្យប្រជាជនទាំងអស់អាចចំណាយពេលមួយថ្ងៃដើម្បីយុត្តិធម៌និងការចងចាំ ។*

**ឆាំង យុ**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

*វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ http://www.voanews.com/ khmer/democratic-kampuchea.cfm របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។*

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# លឹម លី ប្រធានសេដ្ឋកិច្ចកងពលទី២ភាគពាយ័ព្យ

លឹម លី ជាជនជាតិខ្មែរមានស្រុកកំណើតនៅភូមិយឹង ឃុំអន្លុងខ្ពស់ ស្រុកទ្រាំង តំបន់១៣ ភូមិភាគនិរតី ។ តួនាទីមុនពេលចាប់ខ្លួនជាប្រធានសេដ្ឋកិច្ចកងពលទី២ ភូមិភាគពាយ័ព្យដែលមានឪពុកឈ្មោះ យឹង លឹម ជាអតីតមេភូមិពីសង្គមចាស់ បច្ចុប្បន្នកាន់ខាងសេដ្ឋកិច្ចភូមិភាគពាយ័ព្យ ។

លី បានឈប់រៀនត្រឹមថ្នាក់ទី១១មកធ្វើស្រែនិងរកស៊ីរត់រទេះសេះនៅភូមិផ្សារកំពង់ជ្រៃ ។

នៅឆ្នាំ១៩៧០ លី បានបួសនៅវត្តត្រើយឃ្លោករយៈពេល ៣ខែ ។ ក្រោយមក លី ក៏បានមកធ្វើយោធានៅតំបន់១៣ខេត្តតាកែវតាមរយៈការខុទ្ទេសនាមរបស់ តាអឿង ជាគណៈយោធាតំបន់១៣ ។ នៅឆ្នាំ១៩៧២ តាសោម ដែលជាគណៈតំបន់១៣ បានចាត់តាំង លី ឲ្យធ្វើជានិរសារនិងដឹកជញ្ជូនអីវ៉ាន់ពីតំបន់២៥ ទៅតំបន់១៣ ។ បន្ទាប់មក ប្រធានពាណិជ្ជកម្មឈ្មោះ ផន បានអប់រំ លី ឲ្យចូលធ្វើទាហានសេអ៊ីអាវិញ ដោយណែនាំ លី ឲ្យធ្វើសកម្មភាពយកការណ៍ពីមូលដ្ឋានបដិវត្តន៍និងទាក់ទងឈ្មោះ ព្រំ សាន់ ជាទាហានស័ក្តិ៥មានមូលដ្ឋាននៅលើភ្នំដីររមៀល និន ជាអនុលេខាស្រុកអង្គរជ័យ តំបន់១៣ ស៊ុម អនុប្រធានពាណិជ្ជកម្មតំបន់១៣និង ឈន អ្នកបើកឡានពាណិជ្ជកម្មតំបន់១៣ ។

នៅខែមេសា ឆ្នាំ១៩៧២ និន បានហៅ ផន និង លី ទៅជួបនៅព្រៃខាងត្បូងផ្សារត្រពាំងអណ្តើកដើម្បីប្រជុំណែនាំឲ្យធ្វើសកម្មភាពយកការណ៍ពីកន្លែងបដិវត្តន៍ រួចរាយការណ៍ឲ្យទាហានលន់ នល់ និងបំផុសប្រជាជនឲ្យចូលធ្វើជាទាហានខ្មាំង និងបានដាក់ផែនការឲ្យយកថ្នាំពេទ្យនិងខោអាវខ្មៅចំនួន២០កំផ្លេពីពាណិជ្ជកម្មផ្តល់ឲ្យ ព្រំ សាន់ ដែលបង្កប់ខ្លួនចាំវាយបដិវត្តន៍ ។

នៅឆ្នាំ១៩៧៣ និន បានទាក់ទងជាមួយ លី និង ស៊ុម ដើម្បីយកអង្ករចំនួន១០បាវនៅក្នុងមន្ទីរស្រុកអង្គរជ័យទៅផ្តល់ឲ្យទាហាននៅលើភ្នំដីររមៀល ។ នៅពាក់កណ្តាលឆ្នាំ១៩៧៣ ដោយសារ លី បានធ្វើឲ្យបាត់លុយចំនួន៦០ម៉ឺនរៀល អង្គការក៏បានបួរមកកន្លែងអប់រំនៅមន្ទីរ១៣ជាមួយមិត្ត ផន វិញ ។ ចំណែកមិត្ត ស៊ុម ត្រូវអង្គការដកទៅកន្លែងនេសាទដែរ ។ ចាប់តាំងពីពេលនោះ មក



កម្មាភិបាលខ្មែរក្រហមនិងអ្នកជំនាញការ

លី លែងបានទាក់ទងជាមួយគ្នាមួយរយៈ ។

នៅឆ្នាំ១៩៧៤ លី និង ផន ត្រូវអង្គការដោះលែងពីកន្លែងអប់រំឲ្យទៅកន្លែងផលិតគ្រាប់មីន និងគ្រាប់បែកនៅមន្ទីរ៣១០ស្រុកត្រាំកក់ តំបន់១៣ ។ ក្រោយមក និន បានសរសេរសំបុត្រទៅ លី, ម៉ៅ, ផន និង សាន់ ដើម្បីជួបប្រជុំគ្នានៅខាងត្បូងផ្សារត្រាំកក់ ។

នៅខែឧសភា ឆ្នាំ១៩៧៥ សាន់, និន, ខែម, ជឺន, ម៉េត និង លី ប្រជុំដាក់ផែនការឲ្យធ្វើសកម្មភាពធ្វើមីនចុច ធ្វើគ្រាប់បែកដាក់បញ្ឆេះខ្ទិៗឬគីបឆេះរហ័សដើម្បីធ្វើឲ្យផ្ទុះត្រូវអ្នកដាក់ខ្លួនឯងនិងធ្វើឲ្យរាំងស្ទះដល់សមរភូមិមុខ ។ សាន់ បានហៅ លី មកណែនាំថាមិត្តត្រូវធ្វើសកម្មភាពយករបស់របរប្រើប្រាស់ដោយសេរីដើម្បីបំផ្លាញបដិវត្តន៍ ។ ក្រោយពីរៀបរាប់ លី បានចូលទៅក្នុងរោងចក្រដោះខ្មៅម៉ាស៊ីន ដោះយកដែកបំពង់ទីប រួចហើយបំផុស អ៊ូច និង អឿន ជាយោធានៅភូមិភាគពាយ័ព្យលួចរត់ទៅលេងផ្ទះនិងបានបបួលទៅលេងខេត្តពោធិ៍សាត់ តាមរយៈឡានរបស់ មិត្តខុន ។ នៅពេលនោះ លី អ៊ូច, អឿន ចូលធ្វើកងទ័ពនៅវរសេនាតូច១៩កងពលទី២ ភូមិភាគពាយ័ព្យបានរយៈពេល១០ថ្ងៃក៏រំដោះបានភ្នំពេញ ។ ក្រោយមក អ៊ូច និង អឿន ត្រូវបានអង្គការផ្លាស់ទៅភាគនិរតីហើយ លី ក៏ដាច់ទំនាក់ទំនងចាប់តាំងពីពេលនោះមក ។

នៅពាក់កណ្តាលឆ្នាំ៧៦ អង្គការចាត់តាំង លី ឲ្យទៅបោះទីតាំងនៅត្រែង ។ ប៉ុន្តែ ម៉ន ជាអនុលេខាវរសេនាតូច១៩បានផ្លាស់ លី ឲ្យទៅធ្វើការផ្នែកសេដ្ឋកិច្ចវរសេនាធំ៧០នៅអូរអណ្តូងផ្នែកចិញ្ចឹមជ្រូកវិញ ។ នៅទីនោះ ណាន ប្រធានសេដ្ឋកិច្ចបានសួរប្រវត្តិ លី ថាបើមិត្តធ្វើបដិវត្តន៍តស៊ូតាំងពីឆ្នាំណា? មានតួនាទីធ្វើអ្វីខ្លះ? ពេលនោះ លី បានរៀបរាប់ថាខ្លួនធ្វើជាសមាជិកពាណិជ្ជកម្មមានតួនាទីដឹកជញ្ជូនខោអាវនិងថ្នាំពេទ្យទៅភូមិភាគពាយ័ព្យដែលមាន មិត្តរ៉ែន ជាអនុលេខាកងពលទី២ ភូមិភាគពាយ័ព្យ ទី ប្រធានពេទ្យកងពលទី២ ឡុង កងពលធំសេដ្ឋកិច្ចវរសេនាធំ៧០ ។ នៅអង្គភាព លី និង ឡុង បានធ្វើសកម្មភាពដោយឲ្យបាយជ្រូកស៊ីមិនឆ្អែតនិងបំផុសប្រជាជនឲ្យរត់ទៅប្រទេសថៃ ។ ចំណែក ទី ធ្វើសកម្មភាពដោយមិនចាក់ថ្នាំឲ្យអ្នកជំងឺ ។ នៅពេល លី, ឡុង និង ទី បំផុសប្រជាជនឲ្យរត់ទៅកប្បាស ទៅស្ពោចំនួន៣០គ្រួសារ ទៅស្ទឹង១០គ្រួសារ ទៅពាក់ស្បែក២០គ្រួសារនិងទៅប្រទេសថៃ កងទ័ពក៏ស្ទាក់ចាប់បាន២០គ្រួសារនៅព្រំដែន រួចវាយសម្លាប់ចោលនៅត្រែងទាំងអស់ ។ នៅខែមករា ឆ្នាំ១៩៧៧ លី បង្កកម្លាំងប្រឆាំងបដិវត្តន៍បានចំនួន២នាក់គឺឈ្មោះ ព្រៃ ខាងសេកិច្ចវរសេនាធំ៧០ កងពលទី២ និង ធុច មេក្រុមសេដ្ឋកិច្ចវរសេនាធំ៧០ កងពលទី២ ។ នៅខែមីនា-មេសា ឆ្នាំ១៩៧៧ រ៉ែន ហៅ លី, ទី, អ៊ុន, ឡុង ណាន, អឿន លេខាវរសេនាតូចលេខ១៩ វរសេនាធំ៧០ កងពលទី២ ដើម្បីលើកផែនការវាយនៅបាត់-ដំបង ។

នៅខែឧសភា ឆ្នាំ១៩៧៧ លី និង ណាន បានទៅបើកអង្ករនៅក្រុងបាត់ដំបងដើម្បីយកមកត្រៀមនៅត្រែងបានចំនួន៥០បាវនិងជ្រូក១០០ក្បាល ។

នៅខែកក្កដា ឆ្នាំ១៩៧៧ ក្រុមរបស់ លី មានទំនាក់ទំនងជាមួយកម្លាំងអ៊ិនតាំនិងពួកថៃ ។ មុខសញ្ញាទីមួយ គឺវាយតាមផ្លូវជាតិលេខ១០ក្រុងប៉ៃលិនចូលក្រុងបាត់ដំបងនិងមុខសញ្ញាទី២ វាយតាមប្រកអូរជ្រៅចូលក្រុងបាត់ដំបងដោយប្រើកម្លាំងរបស់អ៊ិនតាំ កម្លាំងថៃសហការជាមួយកងពលទី១ ។ ក្រោយមក រ៉ែន បានប្រគល់ភារកិច្ចឲ្យ លី, អ៊ុន ,ឡុង ត្រៀមស្បៀង ចំណែក ទី មានតួនាទីចែកថ្នាំពេទ្យឲ្យកងទ័ពថៃនិងអ៊ិនតាំ ។ នៅខែកក្កដា ឆ្នាំ១៩៧៧ អង្គការបានចាប់ រ៉ែន និងថ្នាក់ក្រោមជាបន្តបន្ទាប់ ។ ពេលនោះ លី, ណាន, ឡុង, អុន មិនហ៊ានធ្វើសកម្មភាពបន្តទេព្រោះត្រូវអង្គការតាមដាន ។ នៅខែកញ្ញា ឆ្នាំ១៩៧៧ ណាន បានហៅ លី, ឡុង អ៊ុន, ទី, មកណែនាំឲ្យធ្វើសកម្មភាពបន្ត គឺខិតខំបំផុសប្រជាជនឲ្យរត់ទៅប្រទេសថៃឲ្យបានច្រើនដើម្បីប្រមូលកម្លាំងវាយបកពីខាងក្រៅវិញ ។ នៅក្នុងខែដដែល លី និង អ៊ុន បានធ្វើសកម្មភាពបំផុសប្រជាជននៅភូមិបឹងអំពិលឲ្យរត់ទៅថៃអស់ចំនួន១០គ្រួសារ ។ ពេលនោះ សែ លេខាកងពលទី២ ភូមិភាគពាយ័ព្យត្រូវបានដកមកនៅអង្គភាពកកោះនិង លី ផ្លាស់ទៅធ្វើជាជាងដំដែកនិងរោងជាងនៅកងពលទី២ ។ នៅទីនោះ លី ស្រាប់តែមានជំងឺពោះវៀនផុះខ្នែងត្រូវមកដេកពេទ្យនៅបាត់-ដំបង ។ នៅខែមីនា ឆ្នាំ១៩៧៨ ក្រោយពី លី ចាកចេញពីពេទ្យមកវិញ ណាន ក៏ត្រូវបានអង្គការចាប់ខ្លួន ។ ពេលនោះ លី ត្រូវ

ផ្លាស់ឲ្យមកជាំបាយឲ្យ សែ រយៈពេលមួយខែវិញ ។ សែ ប្រាប់ លី ថា «មិត្តធ្វើបដិវត្តន៍សព្វថ្ងៃមានការលំបាកវេទនាណាស់ មិត្តមើលចុះពីសង្គមចាស់និងសង្គមបដិវត្តន៍» ខុសប្លែកពីការផ្សាយតាមវិទ្យុរបស់អង្គការថា កែប្រែជីវភាពប្រជាជនឲ្យមានសិទ្ធិសេរីភាពទាំងអស់គ្នា មានបាយហូប មានសម្លៀកបំពាក់គ្រប់គ្រាន់ តែផ្ទុយទៅវិញប្រជាជននិងកងទ័ពនៅតែអត់ខ្វះខាតនិងរស់នៅមិនបានជួបជុំគ្នាទេ ។

នៅខែមេសា ឆ្នាំ១៩៧៨ សែ ហៅ លី ឲ្យទៅជួបនៅមន្ទីរ ដោយប្រាប់ថា «ឥឡូវខ្ញុំមានការទុកចិត្តណាស់» ប្រសិនបើមិត្តសម្រេចភារកិច្ចនេះបានខ្ញុំនឹងចាត់តាំងធ្វើជាប្រធានសេដ្ឋកិច្ចកងពលទី២នៅទីនេះ ។ ព្ធដូច្នេះ លី ត្រូវទាក់ទងជាមួយកម្លាំងថៃនិងអ៊ិនតាំវាយចូលក្រុងបាត់ដំបង ។ ដោយការសហការជាមួយកម្លាំងថៃ, អ៊ិនតាំបានវ៉ៃចូលប៉ៃលិនតាមផ្លូវជាតិលេខ១០ រួចមកចាប់ដៃនៅបាត់ដំបង ។ ចំណែក លី, សែ ទាក់ទងជាមួយ សុន សាម នៅកន្លែងចម្ការកាហ្វេ ព្រមទាំងដឹកជញ្ជូនស្បៀងនិងសម្ភារៈផ្តល់ឲ្យកម្លាំងថៃនិងអ៊ិនតាំ រួមទាំងជាមួយនិង ភឹម, មាន, ឈឹម, ។

នៅខែ៥ ឆ្នាំ១៩៧៨ បែ និង សុន, បាននាំកម្លាំងថៃពីរនាក់ទៀតឈ្មោះ វ៉ាត និង ហែម ឈន និងពីរនាក់ផ្សេងទៀតមានឈ្មោះ ឆែម និង ចន មកប្រជុំនៅក្នុងមន្ទីររបស់ សែ ។ នៅពេលប្រជុំ សែ ពិភាក្សាគូរផែនទីតាមច្រកបរិលនិងកំរៀងដើម្បីឲ្យកម្លាំងថៃនិងកម្លាំងរបស់អ៊ិនតាំចូលតាមច្រកនេះសហការជាមួយ ហែម និង ចន ។ បន្ទាប់ពីប្រជុំចប់ បែ និង សុន ក៏បាននាំកម្លាំងអ៊ិនតាំត្រឡប់ទៅព្រំដែនវិញ ។

នៅខែចុងខែឧសភា ឆ្នាំ១៩៧៨ សែ បានឲ្យកម្លាំងថៃនិងអ៊ិនតាំចូលមកនៅលើភ្នំខ្យៅដើម្បីត្រៀមផែនការវាយច្រកបរិល ចំណែក សែ បានឲ្យ លី ធ្វើការទាក់ទងជាមួយ សុន, និង សាម នៅចម្ការកាហ្វេដើម្បីយកត្រាក់ទ័រមួយគ្រឿងមកដឹកអង្ករនៅកន្លែង លី ចំនួន៣០បាវយកទៅឲ្យកម្លាំងថៃនិងអ៊ិនតាំនៅលើភ្នំខ្យៅ ។ នៅពេលប្រជុំ សែ បានប្រាប់ លី ដើម្បីបញ្ជាក់ពីផែនទីតាមមុខសញ្ញាដែលត្រូវចូលតាមផ្លូវជាតិលេខ១០ ។ ក្រោយពេលដែល សែ បានរៀបចំផែនការនេះរួចក៏ណែនាំ លី ទៅដឹកអង្ករពីត្រែង ៣០០បាវថែមទៀត ។

នៅដើមខែកក្កដា ឆ្នាំ១៩៧៨ សែ ត្រូវអង្គការដកយកទៅដាក់នៅកន្លែងសមាសភាពកកោះវិញ ។ ចាប់ខ្លួននៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៧៨ ដោយសារប្រឆាំងបដិវត្តន៍ដោយបានចូលរួមជាមួយបក្សពួកក្បត់និងផ្សំគំនិតជាមួយកងកម្លាំងថៃនិងអ៊ិនតាំ ។

**ស៊ិន សុធីតា**


ប្រជាជនកំពុងលើកទំនប់ និងជីកប្រឡាយ

# ជនរងគ្រោះកំពុងរង់ចាំភាពយុត្តិធម៌


សួស សារិន (ស្លាប់នៅចុងឆ្នាំ២០០៨)

សួស សារិន មកពីខេត្តស្វាយរៀង ជាដើមបណ្តឹងរដ្ឋប្បវេណី របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលគេស្គាល់ថា ជាតុលាការខ្មែរក្រហម ។

សារិន មានបងប្អូនប្រាំពីរនាក់ ។ ក្នុងចំណោមបងប្អូនរបស់គាត់មានបីនាក់ដែលត្រូវខ្មែរក្រហមសម្លាប់និងម្នាក់ទៀត ឈ្មោះ សួស មុត បានបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។

សារិន មានបងស្រីម្នាក់ឈ្មោះ សួស សុវណ្ណ ជាអ្នកទោសនៅគុកទួលស្លែង ស-២១ ។ យោងតាមសម្តីរបស់គាត់នៅក្នុងទសវត្សរ៍៧០ សុវណ្ណ ជាសិស្សថ្នាក់ទី៨នៃវិទ្យាល័យសំបួរនៅពេលខ្មែរក្រហមឡើងកាន់អំណាច ។ ក្រោយមក សុវណ្ណ បានចូលបម្រើយោធាខ្មែរក្រហមដោយមានតួនាទីជាបុគ្គលិកពេទ្យនៅក្នុងឃុំសំបួរ រយៈពេលបួនឆ្នាំទើបត្រូវអង្គការចាប់ខ្លួន ។ នៅឆ្នាំ១៩៧៥ សុវណ្ណ ត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើការនៅតំបន់២៣ ។

ពេល សារិន បានជួប សុវណ្ណ នៅក្នុងរបបខ្មែរក្រហម គាត់មានការព្រួយបារម្ភយ៉ាងខ្លាំង ព្រោះសុវណ្ណ ត្រូវអង្គការសង្ស័យថាជាជនក្បត់ ។ សុវណ្ណ បាននិយាយប្រាប់ សារិន ថា «កុំនិយាយអ្វីទាំងអស់» ។ ក្រោយពីជួបគ្នារួច សុវណ្ណ បានបាត់ខ្លួនរហូត ។ សុវណ្ណ ត្រូវចាប់ខ្លួននៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៨នៅតំបន់២៣ ខេត្តស្វាយរៀងភូមិភាគបូព៌ា ។ យោងតាមប្រវត្តិរូបនៅមន្ទីរឃុំឃាំងស-២១ សុវណ្ណ ត្រូវឃុំខ្លួននៅផ្ទះលេខ៣៣ បន្ទប់ធំលេខ៤ ក្នុងមន្ទីរស-២១ ។

នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៨ សារិន បាននិយាយទាំងសំឡេងខ្សោយៗថា «សូមឲ្យតុលាការកាត់ទោសឲ្យបានឆាប់តាមដែលអាចធ្វើទៅបានដើម្បីឲ្យខ្ញុំបានដឹងផង ព្រោះខ្ញុំមិនអាចទៅមើលការកាត់ទោសដោយផ្ទាល់បានទេ ប៉ុន្តែខ្ញុំអាចមើលព័ត៌មានតាមរយៈកញ្ចក់ទូរទស្សន៍បាន ។ ប្រសិនបើគ្មានការកាត់ទោស ឌុច នោះទេ ខ្ញុំប្រហែលជាស្លាប់បិទភ្នែកមិនជិតទេ» ។

ជាអកុសល សារិន បានទទួលមរណភាពកាលពីពីរ-បីខែមុនពេលតុលាការធ្វើការកាត់ទោស ឌុច ជាផ្លូវការដែលបានចាប់ផ្តើមនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ។ សារិន មិនដែលបានមើលការកាត់ទោសរបស់ ឌុច ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅលើបងស្រីនិងសាច់ញាតិរបស់គាត់ទេ ។ តាមពិត សារិន មិនធ្លាប់បានឃើញអតីតមេដឹកនាំខ្មែរក្រហមទទួលការកាត់ទោសចំពោះការទទួលខុសត្រូវដែលមេដឹកនាំទាំងនោះបានប្រព្រឹត្តយ៉ាងព្រៃផ្សៃនិងអមនុស្សធម៌ទេ ។

ប្តីរបស់ សារិន មិនប្រាកដក្នុងចិត្តទេថាតើគាត់អាចនឹងត្រូវអនុញ្ញាតឲ្យធ្វើជាអ្នកតំណាងលើករណីរបស់ប្រពន្ធគាត់នោះទេ ។

ប្រជាជនទូទៅហាក់ដូចជាមានការព្រួយបារម្ភចំពោះអាយុជីវិតរបស់មេដឹកនាំខ្មែរក្រហមទាំងនោះ ពីព្រោះអ្នកទាំងនោះអាចនឹងស្លាប់មុនពេលមានសាលក្រមសម្រេច ប៉ុន្តែចំពោះជនរងគ្រោះទាំងអស់ដូចជា សារិន ដែលបានស្លាប់ឬនឹងត្រូវស្លាប់មុនការទទួលខុសត្រូវរបស់មេដឹកនាំទាំងនោះមិនត្រូវបានទទួលស្គាល់ ហើយព្រលឹងរបស់គាត់នៅតែស្រែកទន្ទឹងរង់ចាំភាពយុត្តិធម៌ តើយើងត្រូវធ្វើដូចម្តេច?

**ជួង សុភារិទ្ធ**

# សវនាការបឋមរបស់ ឌុច កាលពីថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ការចូលរួមរបស់អ្នកនៅរស់ពីរបបខ្មែរក្រហម

បន្ទាប់ពីទន្ទឹងរង់ចាំការចាប់ផ្តើមកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកទទួលខុសខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មយ៉ាងធ្ងន់ធ្ងរដែលកើតឡើងនៅរបបកម្ពុជាប្រជាធិបតេយ្យដ៏យូរ សវនាការសាធារណៈដំបូងមុនពេលអង្គជំនុំជម្រះបានប្រព្រឹត្តទៅនៅថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ។ សវនាការបឋម កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រធានមន្ទីរស-២១ ត្រូវបានបើកដោយមានវត្តមានរបស់អ្នកសារព័ត៌មាន អ្នកតំណាងអង្គការក្រៅរដ្ឋាភិបាល ក្រុមអ្នកភូមិ សិស្ស ព្រះសង្ឃ ដូនជី និង អ្នកផ្សេងៗទៀត ។ នៅក្នុងចំណោមនោះ គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានអញ្ជើញអ្នកតំណាងភូមិ៦៥នាក់មួយក្រុមនិងជនជាតិចាមមូស្លីមដែលមកពីខេត្តតាកែវ កំពត កំពង់ធំ កណ្តាល ព្រៃវែង ព្រះវិហារ និងកំពង់ចាមឲ្យមកចូលរួម ។ ថ្ងៃនេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសម្រាប់ប្រជាជនកម្ពុជាដែលរងគ្រោះដោយផ្ទាល់និងមិនផ្ទាល់នៅក្រោមរបបខ្មែរក្រហម ។ សវនាការសាធារណៈបានលើកឡើងពីប្រធានបទដូចជាយុត្តិសាស្ត្រការពារជនរងគ្រោះ ការអនុញ្ញាតឲ្យមានពាក្យបណ្តឹងដើមបណ្តឹងរដ្ឋប្បវេណីនិងបញ្ជីភាគីសាក្សីនិងអ្នកជំនាញ ។ ការពិភាក្សាភាគច្រើនផ្តោតទៅលើបញ្ជីដែលស្នើដោយក្រុមអ្នកច្បាប់ដើមបណ្តឹងរដ្ឋប្បវេណី ។

### ថ្ងៃទី១៦ ខែកុម្ភៈ ដែលជាថ្ងៃដំបូង ៖ ការបណ្តុះបណ្តាលផ្នែកច្បាប់និងការបង្ហាញភាព យន្តឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា

ថ្ងៃដំបូងសម្រាប់អ្នកចូលរួមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានធ្វើឡើងនៅមជ្ឈមណ្ឌល នៅពេលព្រឹកថ្ងៃទី១៦ ខែកុម្ភៈ ។ នៅពេលថ្ងៃ មានការចាក់ផ្សាយភាពយន្តឯកសារនិងកិច្ចប្រជុំផ្តល់ព័ត៌មានអំពីការដាក់ពាក្យបណ្តឹងទៅអង្គជំនុំជម្រះ ។ អ្នកចូលរួមក្នុងកម្មវិធីមួយចំនួនដែលមកពីតាកែវបានកំពុងរង់ចាំឱកាសដើម្បីដាក់ពាក្យបណ្តឹងទៅកាន់ទៅតុលាការយូរណាស់មកហើយ ។ ដោយមានជំនួយពីក្រុមជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការ អ្នកចូលរួម៤រូបបានបំពេញបែបបទពាក្យបណ្តឹងរបស់តុលាការដើម្បីក្លាយខ្លួនទៅជាអ្នកដាក់ពាក្យបណ្តឹង ។

ក្រុមអ្នកភូមិដែលភាគច្រើននៃអ្នកទាំងនោះមកពីស្រុកស្ទោង ខេត្តកំពង់ធំ ដែលជាទីតាំង ឌុច ចាប់កំណើតនិងធំធាត់ត្រូវបានស្វាគមន៍ដោយក្រុមឯកសាររស់នៅការិយាល័យព័ត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក្រុមអ្នកភូមិបានចូលរួមក្នុងការបណ្តុះបណ្តាលដែលចែកចេញជាពីរផ្នែកពេញមួយព្រឹក ។ នៅក្នុងផ្នែកទីមួយអ្នកចូលរួមត្រូវបានណែនាំអំពីសកម្មភាពរបស់មជ្ឈមណ្ឌលដែលជាគោលបំណងនៃសកម្មភាពនិងមូលហេតុនាំដែលឲ្យមានការចូលរួមនេះ ។ អ្នកភូមិដែលបានស្គាល់ពីប្រវត្តិ ឌុច ដឹងថាឃុំមួយចំនួនដែលត្រូវបានជ្រើសរើសមានទីតាំងនៅជិតកន្លែងកំណើតរបស់ ឌុច រីឯឃុំផ្សេងទៀតមានទីតាំងនៅជិតវាលពិឃាដ រណ្តៅសពរួម និងបូជនីយដ្ឋាន ។ បន្ទាប់មក ក្រុមការងារបានពន្យល់អ្នកភូមិអំពីឯកសារដែលគេបានផ្តល់ឲ្យ ដែលរួមមានតារាងពេលវេលាសម្រាប់កាត់ទោសនៅអង្គជំនុំជម្រះ របាយការណ៍ត្រួតពិនិត្យទៅលើ ឌុច សំណួរស្ទាបស្ទង់និងសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ឌី ខាំបូលី ។ អ្នកភូមិចាប់អារម្មណ៍ជាខ្លាំងចំពោះសៀវភៅ ហើយបានស្នើសុំច្បាប់ចម្លងបន្ថែម ។ អ្នកទាំងនោះក៏ពេញចិត្តនឹងទទួលព័ត៌មានទាក់ទងនឹងប្រវត្តិរូបរបស់ ឌុច ដែរ ។ អ្នកភូមិមួយចំនួនធ្លាប់បានដឹងពី ឌុច និងស្គាល់ពីកន្លែងកំណើតរបស់គាត់ អ្នកភូមិផ្សេងទៀតមានចំណង់ចង់ដឹងថាតើអតីតប្រធានគុកទួលស្លែងនោះមកពីណា ។ អ្នកភូមិម្នាក់បានលើកដៃដើម្បីនិយាយប្រាប់ក្រុមរបស់គាត់អំពីអ្វីដែលគាត់បានដឹងអំពី ឌុច គាត់និយាយថា ឌុច ចាប់កំណើតនិងធំធាត់ឡើងនៅក្នុងភូមិតូចមួយដែលនៅលើទឹក ហើយរស់នៅក្នុងគ្រួសារវណ្ណៈកណ្តាលដែលមានសញ្ជាតិខ្មែរ-ចិន ។ អ្នកភូមិផ្សេងទៀតងក់ក្បាលបញ្ជាក់ថា យល់ស្រប ។

នៅក្នុងផ្នែកទីពីរ ប្រធានក្រុមឆ្លើយតបនឹងតុលាការ លោក វ៉ាន់ ថាន់ពៅដារ៉ា បានពន្យល់អ្នកភូមិអំពីអ្វីដែលគេនឹងបានឃើញ

នៅក្នុងសវនាការនៅថ្ងៃបន្ទាប់ ។ លោកបានណែនាំអ្នកភូមិឲ្យដឹងពីអង្គជំនុំជម្រះ បន្ទាប់មកលោកបាននិយាយពីបញ្ហាសំខាន់ដែលនឹងត្រូវលើកឡើងនៅសវនាការដែលរួមមានពាក្យបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សាក្សីនិងអ្នកជំនាញ និងវិធីសាស្ត្រការពារដែលអ្នកភូមិយល់ឃើញ ។ លោកបានធ្វើកំណត់សម្គាល់ថា នៅអំឡុងពេលសវនាការ បញ្ហាចម្បងឬបញ្ហានីតិវិធីដែលអាចមានឥទ្ធិពលទៅលើការដឹកនាំសវនាការដ៏មានសារសំខាន់នឹងត្រូវយកមកពិភាក្សា ឧទាហរណ៍ ដូចជាបញ្ហាក្មេងដែលរស់រានមានជីវិតពីគុក ស-២១ ដែលទើបតែរកឃើញថ្មីៗនេះ ។ នៅរយៈពេល ១៥នាទីចុងក្រោយនៃការណែនាំបង្ហាញ លោក វ៉ាន់ថាន់ ពោធារ៉ា បានពន្យល់ពីរូបរាងរបស់បន្ទប់សវនាការនិងតួនាទីរបស់ភាគីទាំងអស់ ព្រមទាំងគូររូបបង្ហាញពីទីតាំងដែលភាគីទាំងអស់ត្រូវអង្គុយ ។

បន្ទាប់ពីការណែនាំបង្ហាញអស់រយៈពេលជាងមួយម៉ោង អ្នកភូមិត្រូវបានផ្ដល់ឱកាសឲ្យសួរសំណួរ ។ សំណួរខ្លះមានដូចជា ៖

១) ប្រសិនបើតុលាការនេះវិសាមញ្ញ តើឧក្រិដ្ឋកម្មដែលនឹងត្រូវយកមកចោទប្រកាន់មានលក្ខណៈប្លែកពីឧក្រិដ្ឋកម្មដែលយកមកចោទប្រកាន់នៅក្នុងប្រព័ន្ធតុលាការក្នុងស្រុកឬទេ?

២) ហេតុអ្វីបានជាជនរងគ្រោះទាំងអស់មិនអាចចូលរួមក្នុងការអង្គជំនុំជម្រះនេះ?

៣) ហេតុអ្វីបានជាលោកប្រើពាក្យ «ប្រល័យពូជសាសន៍» ដើម្បីហៅរបបខ្មែរក្រហម? ខ្ញុំគិតថាពាក្យនេះ ធ្ងន់ធ្ងរមិនដល់ពាក្យ «ខ្មែរសម្លាប់ប្រជាជនខ្លួនឯង» ទេ ។

៤) តើតុលាការនឹងផ្ដល់យុត្តិធម៌ឬទេ?

៥) តើនៅក្នុងតុលាការនៅតែមានអំពើពុករលួយឬទេ?

៦) ហេតុអ្វីបានជាត្រូវមានមេធាវីការពារជនត្រូវចោទ?

៧) ប្រសិនបើតុលាការនៅតែពន្យារពេល តើគេនឹងដោះស្រាយចំពោះមេដឹកនាំខ្មែរក្រហមវ័យចំណាស់ដែលនៅជាប់ឃុំឃាំងដោយរបៀបណា?

នៅពេលថ្ងៃត្រង់ អ្នកចូលរួមបានមើលភាពយន្តឯកសារ *«ក្រោយជញ្ជាំងស-២១ ៖ ប្រវត្តិសាស្ត្រផ្ទាល់មាត់ពីគុកទួលស្លែង»* ។ ភាពយន្តនេះបានចងក្រងអំពីប្រវត្តិពិតរបស់អតីតអ្នកទោសពីរនាក់ និងអ្នកយាមម្នាក់ដែលរៀបរាប់ពីរបៀបដែលគេមកដល់គុកទទួលទារុណកម្ម និងរួចរស់ជីវិត ។ វាមានសភាពស្ងៀមស្ងាត់ទាំងស្រុងនៅអំឡុងពេលបង្ហាញខ្សែភាពយន្ត ។ នៅពេលដែលភាពយន្តចប់ ក្រុមការងារបានពិភាក្សាអំពីសាច់រឿងនៅក្នុងភាពយន្តនោះជាមួយអ្នកភូមិ ហើយសួរទៅកាន់អ្នកភូមិថា តើគេទាំងអស់គ្នាអាចតាមទាន់សាច់រឿងឬទេ ភាគច្រើននៃអ្នកភូមិឆ្លើយថាទាន់ ។ ចំពោះអ្នកភូមិ ភាពយន្តបានធ្វើឲ្យគេឃើញការចងចាំដ៏រស់រវើកនៅរបបខ្មែរក្រហម ។ លោកស្រី សម ហាន ដែលមកពីខេត្តតាកែវ បានទទួលរងការភ័យតក់ស្លុតយ៉ាងខ្លាំងនៅក្នុងគុកទួលស្លែង និងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយលោកស្រីត្រូវបានលើកទឹកចិត្តឲ្យនិយាយអំពីដំណើររឿងរបស់គាត់នៅពីមុខម៉ាស៊ីនថតនិងចំពោះមុខមហាជន ។ ក្រោយមកទៀត លោកស្រីបាននិយាយអំពីគុកក្រាំងតាចាន់ ក្នុងស្រុកត្រាំកក់ ដែលជាកន្លែងជនរងគ្រោះរាប់ពាន់នាក់ត្រូវឃុំឃាំងនិងសម្លាប់ ។

ក្រោយពីកុនបញ្ចាំងរួច អ្នកចូលរួមចំនួន៤នាក់ដែលសំណូមពរឲ្យមានជំនួយនៅក្នុងការបំពេញទម្រង់បែបបទជនរងគ្រោះត្រូវបានជួយដោយក្រុមចុះជួយជនរងគ្រោះដាក់ពាក្យបណ្ដឹងទៅតុលាការ ។ ក្នុងចំណោមអ្នកចូលរួមទាំង៤នាក់ មានតែម្នាក់ប៉ុណ្ណោះបានយកអត្តសញ្ញាណប័ណ្ណមក ដែលវាមានសារសំខាន់ណាស់ក្នុងការបំពេញទម្រង់បែបបទ ។ ចំណែកអ្នកផ្សេងទៀតបានសន្យាថានឹងប្រគល់លេខអត្តសញ្ញាណប័ណ្ណរបស់ខ្លួនទៅដល់ក្រុមចុះជួយជនរងគ្រោះដាក់ពាក្យបណ្ដឹងទៅតុលាការ បន្ទាប់ពីពួកគាត់ត្រឡប់ទៅភូមិវិញ ។ ការរៀបចំដាក់ពាក្យបណ្ដឹងចំណាយអស់រយៈពេលមួយម៉ោងនិងសាមសិបនាទី ។ អ្នកដាក់ពាក្យបណ្ដឹងទាំងបួនរូបនេះបានស្ដាប់ព្រះនៅតាមវិទ្យុអំពីតុលាការនេះ និងឱកាសក្នុងការបំពេញពាក្យបណ្ដឹង ប៉ុន្តែមិនបានដឹងអំពីរបៀបបំពេញពាក្យបណ្ដឹងនៅឡើយទេ ។ មានតែក្រោយពីអ្នកចូលរួមទាំងនោះបានចូលរួមនៅក្នុងកម្មវិធីនេះ នឹងបានទទួលព័ត៌មានដែលបានមកពីការជួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងការប្រមូលទម្រង់បែបបទជនរងគ្រោះប៉ុណ្ណោះ ទើបអ្នកចូលរួមទាំងនោះអាចបំពេញទម្រង់បែបបទជនគ្រោះជាមួយតុលាការបាន ។ លោកស្រី យឹម ម៉ាយ៉ានី អាយុ៥៨ឆ្នាំ ដែលគាត់កំពុងរង់ចាំទទួលការជួយដើម្បីបំពេញទម្រង់បែបបទជនរងគ្រោះបាននិយាយថា *«ខ្ញុំចង់បំពេញទម្រង់*

បែបបទជនរងគ្រោះ ពីព្រោះខ្ញុំចង់ឲ្យតុលាការនេះស្វែងរកយុត្តិធម៌សម្រាប់ខ្ញុំនិងជនរងគ្រោះដទៃទៀត» ។ លោកស្រី យឹម បានពន្យល់ថា «ភាពយុត្តិធម៌មានន័យខុសៗពីគ្នាសម្រាប់ខ្ញុំ វាអាចមានន័យថាជាតុលាការយុត្តិធម៌ ឬក៏តុលាការមួយដ៏ស្អាតស្អំ ឬបើនិយាយឲ្យសាមញ្ញគឺការចូលរួមរបស់ជនរងគ្រោះដោយមិនលម្អៀងនៅក្នុងដំណើរការក្តី» ។ លោកស្រី យឹម បានបំពេញទម្រង់បែបបទជនរងគ្រោះមួយ ដោយសង្ឃឹមថា អ្នកជិតខាងរបស់គាត់និងជនរងគ្រោះដទៃទៀតនឹងបានទទួលដំណឹងអំពីដំណើរការក្តីរបស់តុលាការ និងព័ត៌មានផ្សេងទៀតដែលទាក់ទងនឹងការវិវឌ្ឍរបស់តុលាការ ។

## ថ្ងៃ១៧ ខែកុម្ភៈ សវនាការបឋមរបស់ ឌុច

នៅថ្ងៃទីពីរនៃកម្មវិធី ក្រុមអ្នកភូមិបានធ្វើដំណើរដោយរថយន្តក្រុងទៅកាន់បន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានទីតាំង១៦គីឡូម៉ែត្រពីទីក្រុងភ្នំពេញដើម្បីចូលរួមបើកសវនាការបឋម ។ យើងសង្កេតឃើញថា តុលាការនេះបានទទួលចំនួនមួយដាក់លាក់អំពីអ្នកដែលមកចូលរួមដោយរួមមានក្រុមអ្នកសារព័ត៌មានដ៏ច្រើន ក្រុមអ្នកភូមិ សិស្ស អង្គការក្រៅរដ្ឋាភិបាល និងបុគ្គលផ្សេងៗដែលមកពីគ្រប់ទិសទី ។ ក្រុមដែលមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា បានឈរតម្រង់ជាជួរយ៉ាងវែងដើម្បីឲ្យសន្តិសុខត្រួតពិនិត្យមុនពេលចូលមកដល់កន្លែងតុលាការ ។ ក្រោយពីឈរតម្រង់ជួររង់ចាំអស់រយៈពេលប្រហែល៣០នាទី ក្រុមនេះបានចូលមកក្នុងបន្ទប់ទស្សនា ដែលកន្លែងអង្គុយស្ទើរតែជិតពេញទៅហើយ ។

បន្ទប់នេះមានសម្ភារៈល្អៗជាមួយនឹងកញ្ចក់ទស្សនាចំនួនពីរនៅចំកណ្តាលខាងមុខកន្លែងអង្គុយ ដែលអាចឲ្យទស្សនិកជននៅជួរកណ្តាលមើលសវនាការដែលខិតជិតមកដល់ ។ សវនាការនេះក៏ស្រដៀងនឹងសវនាការលើកចុងក្រោយដែលបានធ្វើឡើងនៅខែធ្នូ ឆ្នាំ២០០៨ដែរ គឺមានឧបករណ៍ស្តាប់ថ្មី ។ សមាជិកអ្នកទស្សនាដែលចូលចិត្តភាសាខ្មែរអាចស្តាប់តាមរយៈឧបករណ៍ស្តាប់សំឡេងថ្មីនេះដោយមិនចាំបាច់ពាក់កាសត្រចៀកនោះទេ ។ ប៉ុន្តែអ្នកដែលត្រូវការបកប្រែជាភាសាអង់គ្លេសនិងបារាំងនៅតែត្រូវប្រើឧបករណ៍ស្តាប់ត្រចៀកដដែល ។ កន្លែងអង្គុយរបស់ភ្ញៀវដែលចូលស្តាប់មានបិទស្លាកសម្គាល់ ដើម្បីទុកឲ្យក្រុមអ្នកសារព័ត៌មាន និងអង្គការក្រៅរាជរដ្ឋាភិបាល ហើយត្រូវបានដាក់នៅពេលសវនាការចាប់ផ្តើម ។

មុនពេលសវនាការចាប់ផ្តើម ចំនួនអ្នកថតរូបនិងអ្នកថតវីដេអូដែលបានកំណត់ត្រូវបានអនុញ្ញាតឲ្យថតរូបចុងចោទនៅបន្ទប់សវនាការដែលជាកន្លែងសវនាការធ្វើឡើង ។ ឌុច និងវិនតាថ្មីរបស់គាត់ មើលទៅមានសុខភាពល្អជាងរូបរាងគាត់ពីមុន ។ គាត់បានអង្គុយនៅកន្លែងដែលបានរៀបចំទុកជាមុន ស្ថិតនៅខាងក្រោយសហចុងចោទរបស់គាត់ គឺលោក កា សាវុធ និង លោក ហ្វ្រង់ស័រ រូ ។ គាត់មានឱកាសបាននិយាយទៅកាន់មេធាវីរបស់គាត់ដោយមិនបានខ្វល់អំពីអ្នកព័ត៌មានដែលបានបញ្ចាំងម៉ាស៊ីនថតទៅមុខរបស់គាត់ ។ បន្ទាប់មក អ្នកថតរូបត្រូវអង្គបុរេជំនុំជម្រះបញ្ជាឲ្យចាកចេញពីក្នុងបន្ទប់ ហើយភ្លាមនោះសវនាការក៏ចាប់ផ្តើម ។

ប្រធានចៅក្រម និល ណុន បានចាប់ផ្តើមដំបូងដោយស្នើសុំឲ្យភាគីទាំងសងខាងសម្តែងនូវចំណាប់អារម្មណ៍របស់ខ្លួន ។ ភាគីនីមួយៗត្រូវបានស្នើដោយអង្គជំនុំជម្រះឲ្យលើកអំពីការព្រួយបារម្ភរបស់ខ្លួនទាក់ទងទៅនឹងបញ្ហាច្បាប់ដែលទំនងជាត្រូវបានលើកយកមកពិភាក្សាមុនពេល ឬក៏ពេលកំពុងបើកសវនាការសំខាន់ ។

សហព្រះរាជអាជ្ញាបរទេស រ៉ូបឺត ពើទិត គឺជាបុគ្គលដំបូងដែលបានចាប់ផ្តើមនិយាយដំបូង ។ គាត់បាននិយាយថាគាត់មានគោលបំណងលើកឡើងនូវគំនិតចូលរួមក្នុងឧក្រិដ្ឋកម្មដែលវាជាការទទួលខុសត្រូវមួយដែលគាត់ចង់ដាក់បន្ទុកទៅលើ ឌុច ។ សំណើពីមុនមករបស់សហព្រះរាជអាជ្ញាគឺបញ្ចូលការចូលរួមនៅក្នុងបទឧក្រិដ្ឋនេះនៅក្នុងដីកាដំណោះស្រាយប្រឆាំងនឹង ឌុច ដែលពីមុនមកត្រូវបានបដិសេធដោយអង្គបុរេជំនុំជម្រះ ។ បន្ទាប់មកមេធាវីសហចុងចោទអន្តរជាតិរបស់ចុងចោទ គឺលោក ហ្វ្រង់ស័រ រ៉ូ បាននិយាយថា គាត់មានគោលបំណងលើកឡើងពីការឃុំខ្លួនបណ្តោះអាសន្នរបស់ ឌុច នៅក្នុងគុកយោធារបស់កម្ពុជាក្នុងអំឡុងពេលសវនាការជនុំជម្រះសំខាន់ ។ គាត់លើកឡើងថាកូនក្តីរបស់គាត់ត្រូវឃុំខ្លួនអស់រយៈពេល៩ឆ្នាំមកហើយដោយគ្មានការជំនុំជម្រះទោសអ្វីទាំងអស់ ដែលគាត់យល់ថាមិនអាចទទួលយកបាន ។ អ្នកការពារក្តីក៏បានប្រមូលនូវការប្រឆាំងទាំងអស់ទៅដល់ឧក្រិដ្ឋកម្មជាតិ

សម្រាប់ការសម្លាប់និងធ្វើទារុណកម្មដាក់នៅក្នុងដីកាបញ្ជូន ដោយយោងទៅតាមការផុតកំណត់នៃការកំណត់លក្ខន្តិកៈរបស់ឧក្រិដ្ឋកម្មទាំងនោះ ។

ភាគីដើមបណ្តឹងរដ្ឋប្បវេណីយ បានបែងចែងជាបួនក្រុម តំណាងឲ្យមេធាវីកម្ពុជានិងមេធាវីអន្តរជាតិ ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីប្រហែល៦០រូប ត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងសវនាការបឋម ហើយ៦រូបនៃភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ ត្រូវបានអនុញ្ញាតឲ្យអង្គុយនៅក្នុងបន្ទប់តុលាការ ។ ចំណែកអ្នកដទៃទៀតអង្គុយនៅកន្លែងអង្គុយសាធារណៈ ។ យោងទៅតាមរបាយការណ៍ដែលអានដោយចៅក្រម ពាក្យបណ្តឹងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីយចំនួន២៨ត្រូវបានទទួលយកនៅករណីនេះ ៨៥ពាក្យបណ្តឹងត្រូវបានទទួលយកជាបណ្តោះអាសន្ន និង២១ពាក្យបណ្តឹងទៀតកំពុងស្ថិតក្នុងការពិចារណា ។ ទាក់ទងទៅនឹងវិធីសាស្ត្រការពារសាក្សីដ៏ច្រើនលើសលប់បានស្នើឲ្យមានវិធីសាស្ត្រការពារអត្តសញ្ញាណរបស់គេពីសាធារណជន ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏មានដើមបណ្តឹងរដ្ឋប្បវេណីតែ៧នាក់ប៉ុណ្ណោះដែលបានស្នើសុំឲ្យមានការការពារ ។ ដើមបណ្តឹងរដ្ឋប្បវេណីនិងសាក្សីនីមួយៗដែលបានធ្វើសំណើឲ្យមានការការពារ ត្រូវបានបង្ហាញអត្តសញ្ញាណ ដោយឈ្មោះហៅក្រៅឬលេខ ដើម្បីការពារអត្តសញ្ញាណពិតប្រាកដរបស់គេ ។

ការពិភាក្សាអស់រយៈពេលពេញមួយព្រឹកនេះ គឺផ្តោតទៅលើបញ្ហាសំខាន់ពីរ ។ ទីមួយ គឺស្នើឲ្យប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ដែលបានស្លាប់ចូលរួមជំនួសគាត់ ។ ទីពីរ គឺពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្មេងប្រុសម្នាក់នៅមន្ទីរស-២១ដែលយឺតជាងគេ គឺលោក នង ចាន់ផល ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលោក ការីម ខាន់ បានស្នើទៅកាន់អង្គជំនុំជម្រះដើម្បីអនុញ្ញាតឲ្យប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់នេះបានចូលរួមនិងទទួលយកពាក្យបណ្តឹងរបស់លោក នង ចាន់ផល ដើម្បីឲ្យគាត់បានក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ទោះបីជាគាត់បានបំពេញពាក្យបណ្តឹងក្រោយថ្ងៃផុតកំណត់២ថ្ងៃក៏ដោយ ។ មានការតវ៉ាយ៉ាងខ្លាំងមួយពីមេធាវីការពារក្តី គឺលោក ហ្វ្រង់ស័រ រ៉ូ ដែលបានលើកឡើងថាការទទួលយកពាក្យបណ្តឹងដែលយឺតនេះនឹងបំផ្លាញសិទ្ធិរបស់ចុងចោទ ។ លោក រ៉ូ បានបញ្ជាក់ទៀតថា ឌុច បានទទួលស្គាល់កំហុសរបស់គាត់រួចហើយ និងបានលើកឡើងទៀតថា គាត់មិនគួរប្រឈមមុខជាមួយនឹងភស្តុតាងថ្មីនិងចម្លើយកសិណសាក្សីនេះនៅថ្ងៃដែលផុតកំណត់នោះទេ ។ ការស្នើសុំទាំងពីរនេះនឹងត្រូវបញ្ជាក់ដោយអង្គជំនុំជម្រះដែលនឹងធ្វើការសម្រេចចិត្តលើបញ្ហាទាំងនេះមុនពេលចាប់ផ្តើមសវនាការសំខាន់ ។

ក្រោយមក ទស្សនិកជននិងភាគីទាំងអស់បានបំបែកគ្នាទៅបរិភោគអាហារថ្ងៃត្រង់ ។ ក្រុមនេះក៏មានឱកាសធ្វើការសម្ភាសន៍ខ្លីមួយ ។ អេ សុវណ្ណា គឺជានិសិត្សម្នាក់ដែលមានអាយុ១៩ឆ្នាំ ហើយដែលបានស្នើឲ្យក្រុមឯកសាររស់យកគាត់ទៅកាន់សវនាការបឋមបាននិយាយថា គាត់សង្ឃឹមថាសវនាការនេះអាចឲ្យយើងរកឃើញហេតុអ្វីបានជាខ្មែរសម្លាប់ខ្មែរ ។ សុវណ្ណា មិនទាន់បានសិក្សាពីចម្លើយនៃសំណួរនេះនៅឡើយទេ ។ ខណៈនោះ គាត់ក៏បាននិយាយប្រាប់ក្រុមនេះថា *«ខ្ញុំតែងតែចង់ស្តាប់ការពិតពី ឌុច ដោយផ្ទាល់ ទោះបីជាខ្ញុំបានឮថាគាត់បានទទួលស្គាល់នូវកំហុសរបស់គាត់តាមរយៈប្រព័ន្ធផ្សព្វផ្សាយយ៉ាងណាក៏ដោយ»* ។ សុវណ្ណា សព្វថ្ងៃរស់នៅជាមួយឪពុកម្តាយរបស់គាត់នៅទីក្រុងភ្នំពេញ ហើយសិក្សានៅសកលវិទ្យាល័យជាតិគ្រប់គ្រងនិងវិទ្យាស្ថានភាសាបរទេស ។ គាត់ជឿជាក់ថា ជនរងគ្រោះជំនាន់ឪពុកម្តាយរបស់គាត់ជាច្រើននាក់នៅតែព្យាយាមចង់ដឹងការពិតពីអតីតកាល ។ គាត់ខ្លួនឯងផ្ទាល់បានសិក្សាពីប្រវត្តិសាស្ត្រក្នុងអំឡុងពីឆ្នាំ១៩៧៥-១៩៧៩ ពីសៀវភៅនិងកម្មវិធីវិទ្យុ ។ គាត់មានការព្រួយបារម្ភថាប្រវត្តិសាស្ត្រនេះនឹងមិនច្បាស់លាស់សម្រាប់ជនរងគ្រោះក៏ដូចជាក្មេងៗជំនាន់ក្រោយដូចជារូបគាត់ ។ គាត់បាននិយាយទៀតថា បើសិនជាគាត់មានឱកាសតាមដានសវនាការកាត់ទោសសំខាន់នេះ គាត់សង្ឃឹមថាវានឹងអាចផ្តល់ពន្លឺខ្លះទាក់ទងទៅនឹងប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនេះ ។ សុវណ្ណា បាននិយាយប្រាប់យើងថា *«ការកាត់ទោសនេះគឺសម្រាប់ខ្ញុំ ជំនាន់របស់ខ្ញុំ និងអនាគតរបស់យើង»* ។

បន្ទាប់ពីសម្រាកអស់រយៈពេល១ម៉ោងនិង៣០នាទីសម្រាប់អាហារថ្ងៃត្រង់ អ្នកចូលរួមបានត្រឡប់មកកាន់កន្លែងទស្សនាសាធារណៈជាថ្មីម្តងទៀតដើម្បីតាមដានដំណើរការក្តីបន្តទៀត ។ មានការកត់សម្គាល់សំខាន់មួយគឺមានចំនួនមនុស្សតិចជាងមុននៅ

កន្លែងទស្សនាសាធារណៈ ។ ដំណើរការកាត់ក្តីនេះបានបន្តដោយពិភាក្សាទៅលើតារាងឈ្មោះសាក្សីនិងអ្នកជំនាញ ។ សហព្រះរាជអាជ្ញាបានបង្ហាញនូវតារាងឈ្មោះសាក្សីចំនួន៣៥នាក់ និងអ្នកជំនាញទៅកាន់អង្គជំនុំជម្រះ ។ រ៉ូ បានប្រឆាំងទៅនឹងការដាក់បញ្ចូលសាក្សីចំនួន៣នាក់ដែលទាក់ទងនឹងគុកម-១៣ ។ គាត់បានលើកឡើងថា គុកនេះគឺស្ថិតនៅក្រៅយុត្តាធិការរបស់តុលាការ ពីព្រោះគុកនេះលែងមាននៅក្នុងឆ្នាំ១៩៧៥ ហើយដូច្នេះសុំស្នើឲ្យដកឈ្មោះអ្នកទាំងបីចេញពីក្នុងតារាង ។ លោក រ៉ូ ក៏បានសុំឲ្យអ្នកជំនាញផ្នែកវិកលចរិកចំនួនពីរនាក់ដែលបានព្យាបាល ឌុច មួយឆ្នាំមកហើយ និងដែលត្រូវហៅមកធ្វើជាកសិណសាក្សីមុនពេលតុលាការ ជួប ឌុច ជាថ្មីម្តងទៀត មុនពេលបើកសវនាការ ។

បន្ទាប់មកទៀត ភាគីដទៃទៀតត្រូវបានសុំឲ្យប្រគល់បញ្ជីឈ្មោះសាក្សីនិងអ្នកជំនាញ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញឈ្មោះសាក្សីចំនួន១៥រូប ហើយអ្នកការពារយល់ព្រមទទួលតែ១៣ឈ្មោះប៉ុណ្ណោះ ។ សហព្រះរាជអាជ្ញាគឺលោក រូបឺត ពើទីត បានជំទាស់ទៅនឹងបញ្ជីឈ្មោះអ្នកជំនាញដែលបានស្នើសុំដោយអ្នកការពារ ។ អ្នកការពារបានលើកឡើងថា អ្នកជំនាញរបស់គេនឹងអាចពន្យល់អំពីចរិកលក្ខណៈរបស់ ឌុច បាន ។

នៅចុងបញ្ចប់ថ្ងៃទីមួយនៃសវនាការបឋម ក្រុមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចាកចេញពីបន្ទប់តុលាការជាមួយនឹងអារម្មណ៍ខុសៗគ្នា ។ បុរសម្នាក់នៅក្នុងក្រុមបានប្រាប់ក្រុមរបស់គាត់ថា អ្វីដែលគាត់ចង់មើលបំផុតនៅក្នុងសវនាការនេះគឺការប្រមូលភ័ស្តុតាង ។ គាត់បានសង្កត់ធ្ងន់អំពីសារសំខាន់នៃការប្រមូលភ័ស្តុតាងនិងចម្លើយរបស់កសិណសាក្សីដើម្បីនាំយកមកកាត់ទោសចុងចោទ ។ យ៉ាងណាក៏ដោយ គាត់នៅមិនទាន់ច្បាស់ក្នុងចិត្តទេថាតើយុត្តិធម៌អាចធ្វើទៅបានទេ បើសិនជាឯកសារសំខាន់ៗនិងភ័ស្តុតាងត្រូវប្រមូលបាន ។ គាត់ចង់ឲ្យភាគីនីមួយៗនៅក្នុងបន្ទប់តុលាការធ្វើតួនាទីរបស់គេឲ្យមានប្រសិទ្ធភាពដើម្បីភាពយុត្តិធម៌ក្នុងការកាត់ក្តី ។

អ្នកចូលរួមមួយចំនួនទៀតគិតថា សកម្មភាពរបស់ចុងចោទក្នុងរបបនោះគឺធ្វើឡើងដោយការភ័យខ្លាច និងការគំរាមកំហែងពីអ្នកមានអំណាច ។ ឧទាហរណ៍ដូចជានៅពេលសួរអំពី ឌុច ស្ត្រីម្នាក់ដែលមកពីខេត្តកំពង់ធំ បានបង្ហាញនូវអារម្មណ៍របស់គាត់ថាដោយបន្ទោសរាល់កំហុសរបស់គាត់ទៅលើអ្នកដែលមានអំណាចលើគាត់ ។ គាត់និយាយថា «បើសិនជា ឌុច មិនធ្វើតាមការបញ្ជាគាត់និងគ្រួសាររបស់គាត់ប្រហែលជាត្រូវគេសម្លាប់ដូចគ្នា» ។

អៃ សា មានអាយុ៥០ឆ្នាំ ជាស្ត្រីជនជាតិចាមមកពីស្រុកបារាយណ៍ ខេត្តកំពង់ធំ បានបាត់បងប្អូនស្រីរបស់គាត់និងសមាជិកគ្រួសារ៩នាក់ទៀតនៅក្នុងសម័យនោះ ព្រោះគ្រួសាររបស់គាត់ត្រូវគេចាត់ទុកថាជា «ប្រជាជនថ្មី» ។ គ្រួសារបងប្អូនស្រីរបស់គាត់ត្រូវជម្លៀសទៅរស់នៅក្នុងខេត្តកំពង់ចាមជាមួយគ្រួសារប្រជាជនមូលដ្ឋាន ។ ខ្មែរក្រហមបានឲ្យគាត់ចិញ្ចឹមជ្រូកប្រហែល៤ខែ នៅអំឡុងពេលដែលខ្មែរក្រហមធ្វើសាច់ឆ្កែឲ្យគាត់ហូប ហើយគំរាមគាត់ថា «បើមិនហូប គាត់នឹងត្រូវបញ្ជូនឲ្យទៅរស់នៅភូមិថ្មី» ។ គាត់មិនដឹងថាភូមិថ្មីនោះនៅទីណានោះទេ ។ នៅពេលសួរថាតើគាត់ចង់បានអ្វីពីការកាត់ទោសនេះ គាត់បាននិយាយថា «ខ្ញុំចង់បានសំណងសមូហភាព ខ្ញុំចង់ឲ្យគេសង់វិហារឥស្លាមមួយ អណ្តូងទឹកមួយ និងវត្ថុជានិមិត្តរូបផ្សេងៗទៀតដើម្បីឧទ្ទិសទៅដល់អ្នកដែលបាន


ហ្វ្រង់ស័រ រ៉ូ

បាត់បង់ជីវិតនៅក្នុងរបបនោះ» ។

## ថ្ងៃទី១៨ ខែកុម្ភៈ ជាថ្ងៃទីពីរនៃសវនាការដំបូងរបស់ ឌុច

ក្រុមអ្នកភូមិបានត្រឡប់មកកាន់បន្ទប់សវនាការសារជាថ្មីនៅព្រឹកថ្ងៃពុធ ដើម្បីបន្តតាមដានដំណើរការក្តីនេះ ។ ដំណើរការក្តីនេះត្រូវបានបិទអស់រយៈពេលប្រហែលជា៣០នាទី បន្ទាប់ពីការពិភាក្សានេះត្រូវធ្វើឡើងដើម្បីបង្កើតច្បាប់សម្រាប់សវនាការសំខាន់នេះ ។ អ្នកការពារពីដំបូងបានប្រកែកពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងការកាត់ទោស ។ នេះត្រូវបានប្រឆាំងទាំងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិងព្រះរាជអាជ្ញា ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលោក ហុង គឹមសួន បានស្នើថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីគួរតែត្រូវបានអនុញ្ញាតឲ្យនិយាយមុនពេលដែលតុលាការចាប់ផ្តើមពិភាក្សាលើបញ្ហានេះ ។

សវនាការនេះក៏ទាក់ទងទៅនឹងភស្តុតាងថ្មីដែលប្រមូលដោយព្រះរាជអាជ្ញា ដោយរួមមានការបញ្ចាំងខ្សែភាពយន្តដែលថតនៅមន្ទីរស-២១ ដោយជនជាតិវៀតណាមនៅក្នុងខែមករា ឆ្នាំ១៩៧៩ គឺមានរយៈពេលពីរបីថ្ងៃក្រោយថ្ងៃរំដោះទីក្រុងភ្នំពេញ ។ ព្រះរាជអាជ្ញាកម្ពុជាលោកស្រី ជា លាង បានចាត់ទុកខ្សែភាពយន្តនេះថាមានសារសំខាន់ខ្លាំងណាស់ ពីព្រោះវាបានបង្ហាញពីស្ថានភាពនៅមន្ទីរស-២១ ដែលក្មេងប្រុសម្នាក់នៅរស់ ហើយអ្នកថតភាពយន្តនេះនៅរស់នៅឡើយដែរ ។ ខ្សែភាពយន្តនេះត្រូវផ្តល់ទៅឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាដោយរាជរដ្ឋាភិបាលវៀតណាមនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៨ ប៉ុន្តែត្រូវបានបញ្ជាក់ដោយលោកស្រី ជា លាង ថា ព្រះរាជអាជ្ញាមិនបានដឹងពីខ្សែភាពយន្តនេះទេ រហូតដល់រយៈពេលមួយសប្តាហ៍ក្រោយថ្ងៃផុតកំណត់ក្នុងការប្រមូលភស្តុតាង ។ មេធាវីការពារកម្ពុជាគឺលោក កា សាវុធ បានប្រឆាំងទៅនឹងការស្នើសុំរបស់ព្រះរាជអាជ្ញា ដោយអះអាងថាវាជាខ្សែភាពយន្តឃោសនា ហើយការចោទសួរប្រហែលជាមិនត្រូវទៅតាមខ្សែភាពយន្តនេះទេ ។ គាត់បានបង្ហាញពីភាពភ្ញាក់ផ្អើលថាអ្នកនៅរស់ចំនួន១៥នាក់ពីមន្ទីរស-២១ រួមទាំងពីរនាក់ប្តីប្រពន្ធដែលឥឡូវនេះបានក្លាយទៅជាដើមបណ្តឹងរដ្ឋប្បវេណី គឺមិនត្រូវបានបង្ហាញនៅក្នុងខ្សែភាពយន្តនេះទេ ។ ដូចគ្នាដែរ ក្មេងប្រុសម្នាក់នៅក្នុងខ្សែភាពយន្តនេះមិនបានបង្ហាញពីការមានសុខភាពមិនល្អក្រោយពីរស់ដោយគ្មានអាហារអស់រយៈពេលបួនប្រាំថ្ងៃ ។ ជាចុងក្រោយ គាត់មានការងឿងឆ្ងល់អំពីការចងចាំពីអ្វីដែលបានកើតឡើងនៅក្នុងមន្ទីស-២១ របស់ក្មេងប្រុសម្នាក់នេះដែលនៅរស់ ។ មេធាវីការពារអន្តរជាតិគឺលោក ហ្វ្រង់ស័រ រ៉ូ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងថា ភស្តុតាងថ្មី៥២សន្លឹកត្រូវបានផ្តល់មកកាន់តុលាការយឺតពេល ហើយលើកឡើងថា ការទទួលយករបស់គេនឹងធ្វើឲ្យដំណើរការក្តីយឺត ។ ការមិនយល់ព្រមរបស់គាត់ ត្រូវបានប្រឆាំងដោយព្រះរាជអាជ្ញាអន្តរជាតិ ដែលបានសង្កត់ធ្ងន់ថាភស្តុតាងនេះមានសារសំខាន់ខ្លាំងណាស់សម្រាប់ស្វែងរកការពិត ។



សវនាការបឋមក្នុងការជំនុំជម្រះក្តីរឿង ឌុច ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩

សវនាការនេះបានបញ្ចប់រយៈពេលកន្លះថ្ងៃ ជាមួយនឹងការសម្រេចចិត្តរបស់អង្គជំនុំជម្រះទៅលើការមិនយល់ព្រមដែលបានលើកឡើងថានឹងលើកយកបញ្ហានេះនៅថៃ្ងបើកសវនាការសំខាន់ ។

អែ សា ដែលបានជួបការលំបាកនៅក្នុងរបបខ្មែរក្រហមនិងបានដឹងពីទារុណកម្មដែលសាច់ញាតិរបស់គាត់បានទទួលក្រោយពី

បានស្តាប់សវនាការនេះរហូតដល់ចប់ ។ គាត់មានការចាប់អារម្មណ៍ទៅលើបញ្ហាខុសប្លែកគ្នាជាច្រើនដែលបានលើកឡើងក្នុងពេលបើកសវនាការ ហើយមានភាពរីករាយត្រង់ថាដំណើរការក្តីនេះបានឆ្ពោះទៅមុខ ។ កិច្ចពិភាក្សាទៅលើភស្តុតាងនិងសាក្សីបានទាក់ទាញអារម្មណ៍របស់គាត់ខ្លាំងជាងគេ ទោះបីជាសវនាការនេះមិនបានផ្តល់ឱកាសឲ្យគាត់បានឃើញសាក្សីយ៉ាងណាក៏ដោយ ។ អៃ សា បាននិយាយថាគាត់សប្បាយចិត្តដែលបានឃើញការកាត់ទោសដែលល្អបំផុតសម្រាប់ប្រជាជនកម្ពុជា ហើយគាត់បាននិយាយទៀតថា គាត់នឹងនាំយកព័ត៌មាននេះទៅប្រាប់សហគមន៍របស់គាត់ ។

នួន មុំ ដែលមកពីខេត្តតាកែវ បានទទួលរងការធ្វើទារុណពីសំណាក់ខ្មែរក្រហមដោយសារឃ្លានខ្លាំងពេក គាត់ក៏បានលួចម្ហូប ។ សព្វថ្ងៃនេះ គាត់ជាសមាជិកនៅក្នុងឃុំដែលធ្វើការបម្រើឲ្យប្រជាជននៅក្នុងឃុំរបស់គាត់ ។ គាត់សង្ឃឹមថា ការចូលរួមនៅក្នុងដំណើរការក្តីនេះនឹងជួយឲ្យគាត់អាចដោះស្រាយនូវបទពិសោធន៍នៅក្រោមសម័យខ្មែរក្រហម ។ នេះជាលើកទីពីរហើយដែលអ្នកស្រីនួន បានចូលរួមនៅក្នុងកម្មវិធីនេះ ។ គាត់ចង់ឃើញដំណើរការក្តីនេះឆ្ពោះទៅមុខ ពីព្រោះវាជាមេរៀនមួយដែលជួយគាត់បំបាត់គំនុំពីខ្មែរក្រហម ។ គាត់មានការជឿជាក់នៅក្នុងដំណើរវិនិច្ឆ័យរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទោះបីជាវាមិនបានឆ្លើយតបទៅនឹងការចង់ឲ្យមានដំណើរការនេះឲ្យបានឆាប់យ៉ាងណាក៏ដោយ ។ គាត់បានសង្កត់ធ្ងន់ថា គាត់ចង់ឃើញលទ្ធផលពីដំណើរការកាត់ទោសនេះឲ្យបានឆាប់ដើម្បីឲ្យគាត់បានធូរស្រាលក្នុងចិត្ត ។

សិន យូសរ ជាបុរសម្នាក់ដែលមានអាយុ៤៨ឆ្នាំ មកពីខេត្តកំពង់ធំ ដោយមានអាយុត្រឹមតែ១៨ឆ្នាំប៉ុណ្ណោះ នៅក្នុងរបបខ្មែរក្រហម ។ គាត់និងគ្រួសារត្រូវបានគេជម្លៀសទៅរស់នៅក្នុងភូមិមួយនៅក្នុងស្រុកបារាយ ។ ម្តាយរបស់គាត់បានស្លាប់បន្ទាប់ពីសម្រាលកូនមួយបានរយៈពេលពីរខែ ដោយសារតែបរិភោគអាហារមិនបានគ្រប់គ្រាន់និងធ្វើហួសកម្លាំង ។ យូសរ បានបន្តទៀតថាគ្រួសាររបស់គាត់ជាគ្រួសារមួយដែលមានជីវភាពមធ្យម ហើយអាចនៅរស់បានដោយសារការប្តូរម្ហូប ។ គាត់បាននិយាយប្រាប់ក្រុមរបស់យើងនៅក្នុងបទសម្ភាសន៍ថា គ្រួសាររបស់គាត់បានរក្សាទុករបស់មានតម្លៃមួយចំនួនដើម្បីប្តូរអង្ករជាមួយប្រជាជនមូលដ្ឋាន ។ ក្រោយមកគាត់បានបង្ហាញអំពីគំនិតរបស់គាត់ទាក់ទងទៅនឹងការកាត់ទោសដែលថាលទ្ធផលមកពីតុលាការនេះមិនអាចសងទៅលើអ្វីដែលគាត់បានបាត់បង់នៅក្នុងរបបនេះបានទេ ។ ទោះបីជាយ៉ាងណាក៏ដោយ វាគឺជាអ្វីដែលតុលាការអាចធ្វើបានដោយបម្រើភាពយុត្តិធម៌សម្រាប់ជនរងគ្រោះកម្ពុជា ។ ក្នុងខណៈនោះដែរ គាត់បានប្រាប់ក្រុមនេះថា «ខ្ញុំចង់ឃើញតើតុលាការនេះអាចជួយកាត់បន្ថយកំហឹងរបស់ជនរងគ្រោះដោយវិធីណា» ។ ពីមុនមក សរ អាចបានត្រឹមតែស្តាប់ព័ត៌មានស្តីពីតុលាការខ្មែរក្រហមតាមរយៈកម្មវិធីវិទ្យុប៉ុណ្ណោះ ។ ប៉ុន្តែឥឡូវគាត់សប្បាយចិត្តណាស់ដែលមានឱកាសអង្គុយមើលដំណើរការក្តីនេះនៅក្នុងបន្ទប់សវនាការ ។ ការធ្វើបែបនេះ អាចជួយឲ្យគាត់ផ្តល់ព័ត៌មាននិងពន្យល់ទៅកាន់អ្នកភូមិរបស់គាត់អំពីអ្វីដែលបានកើតឡើងនៅក្នុងតុលាការ ។ គាត់បានសង្កត់ធ្ងន់ថា «ព័ត៌មានដ៏មានតម្លៃនេះគួរតែបានពុទៅដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហមទាំងអស់» ។ នៅពេលសួរថាតើគាត់មានអារម្មណ៍ដូចម្តេចនៅពេលគាត់ឃើញមុខរបស់ ឌុច? សរ បានឆ្លើយដោយគ្មានការស្ទាក់ស្ទើរថា រូបរាងរបស់ ឌុច មិនបានធ្វើឲ្យគាត់ខឹងទេ ប៉ុន្តែការធ្វើទារុណកម្មនិងការសម្លាប់ដែលបានកើតឡើងនៅមន្ទីរស-២១ គឺមិនមែនជាអ្វីដែល ឌុច គួរតែត្រូវអត់ឱនទោសទេ ។ ជាចុងក្រោយគាត់បានបន្តទៀតថា សវនាការនេះប្រហែលជាវិធីតែមួយក្នុងការផ្សះផ្សាសម្រាប់អ្នកនៅរស់ពីរបបខ្មែរក្រហម ។

បីបួនថៃបន្ទាប់ពីសវនាការបឋម អង្គជំនុំជម្រះដំបូងបានចេញនូវការវិភាគមួយសម្រាប់សវនាការសំខាន់ ។ វានឹងចាប់ផ្តើមធ្វើឡើងនៅថ្ងៃទី៣០ ខែមីនា ហើយបន្តធ្វើរហូតក្នុងរយៈពេល៣ខែ ។ សវនាការនេះធ្វើឡើងជារៀងរាល់សប្តាហ៍ គឺចាប់ពីថ្ងៃចន្ទរហូតដល់ថ្ងៃព្រហស្បតិ៍ ។ វាត្រូវបានគេសង្ឃឹមថាសេចក្តីប្រកាសព័ត៌មាននេះនឹងធ្វើឲ្យសាធារណជនកាន់តែយកចិត្តទុកដាក់បន្ថែមទៀតទៅលើដំណើរការក្តីរបស់អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជាដើម្បីបន្ថែមការទាក់ទងនិងជំនឿជឿជាក់របស់ប្រជាជនកម្ពុជាទាំងអស់នៅក្នុងអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា ។

**ស៊ីរ៉ សាទីណា**

# មួយពាន់សំលេង:
# របាយការណ៍អំពីការស្ទាបស្ទង់មតិប្រជាជនជុំវិញ
# ការកាត់ទោសមនុស្សបន្ថែម ដោយតុលាការកាត់ទោសខ្មែរក្រហម

*ការស្ទាបស្ទង់មតិនេះគឺដើម្បីកំណត់ថាតើមនុស្សច្រើនជាងមួយពាន់នាក់មកពីគ្រប់ទិសទីនៅក្នុងប្រទេសកម្ពុជាចង់ឲ្យមានការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមតែចំនួន៥ នាក់ដែលកំពុងត្រូវឃុំខ្លួនបណ្តោះអាសន្នសព្វថ្ងៃឬក៏ចង់ឲ្យមានការស៊ើបអង្កេតមនុស្សបន្ថែមប្រមាណពី៥ ទៅ១០ នាក់បន្ថែមទៀត ។*

*សំណួរទីបី នៅក្នុងចំណោមសំណួរចំនួន៧ បានសួរថាៈ «តើអ្នកយល់ថាតុលាការខ្មែរក្រហមគួរកាត់ទោសមេដឹកនាំខ្មែរក្រហមតែចំនួន៥រូបដែលកំពុងស្ថិតនៅក្រោមការឃុំឃាំងនេះឬគួរតែកាត់ទោសមនុស្សចំនួន៥ - ១០រូបបន្ថែមទៀត?» ។ នៅក្នុងចម្លើយដែលទទួលបាន មានមនុស្សចំនួន៤១,៤ភាគរយបានឆ្លើយតបថាពួកគេមិនចង់ឃើញតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមកាត់ទោសមនុស្សលើសពី៥ នាក់ដែលកំពុងស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នសព្វថ្ងៃនេះទេ ។ ដោយឡែកមនុស្សចំនួន៥៦,៨ភាគរយបានឆ្លើយតបថា ពួកគេចង់ឃើញតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមធ្វើការកាត់ទោសមនុស្សពី៥ ទៅ១០ នាក់បន្ថែមទៀត ។ ចំណែកឯ១,៧ភាគរយនៃចំនួនមនុស្សទាំងអស់មិនមានយោបល់ឬមិនព្រមបញ្ចេញការយល់ឃើញរបស់ខ្លួនទេ ។*

***សំណួរ***

*១) តើអ្នកធ្លាប់បានដឹងអំពីតុលាការខ្មែរក្រហមឬទេ? ប្រសិនបើអ្នកធ្លាប់ដឹង តើអ្នកដឹងអំពីតុលាការនេះកម្រិតណា?*

*២) តើអ្នកយល់ថា អតីតមេដឹកនាំខ្មែរក្រហមគួរតែត្រូវកាត់ទោសដោយតុលាការខ្មែរក្រហមឬទេ?*

*៣) តើអ្នកយល់ថាតុលាការខ្មែរក្រហមគួរកាត់ទោសមេដឹកនាំខ្មែរក្រហមតែចំនួន៥រូបដែលកំពុងស្ថិតនៅក្រោមការឃុំឃាំងនេះឬគួរតែកាត់ទោសមនុស្សចំនួន៥ - ១០រូបបន្ថែមទៀត?*

*៤) តើអ្នកគិតថា បញ្ហាថវិការបស់តុលាការគួរតែជាកត្តាសំខាន់មួយនៅក្នុងការសម្រេចកាត់ទោសមនុស្សចំនួនប៉ុន្មានរូបឬទេ?*

*៥) ប្រសិនបើតុលាការខ្មែរក្រហមកាត់ទោសមនុស្សច្រើនជាង៥រូបដែលកំពុងត្រូវឃុំឃាំងបណ្តោះអាសន្នសព្វថ្ងៃ តើអ្នកយល់ថាអាចបង្កឲ្យមានអស្ថិរភាព ឬអំពើហិង្សានៅក្នុងសង្គមឬទេ?*

*៦) តើអ្នកគិតថា មុននឹងធ្វើការសម្រេចថាតើគួរកាត់ទោសមនុស្សបន្ថែមទៀតឬអត់ តុលាការកាត់ទោសខ្មែរក្រហមគួរតែកាត់ទោសអ្នកទាំង៥រូបដែលកំពុងត្រូវឃុំខ្លួនបណ្តោះអាសន្ននេះឲ្យរួចសិន?*

*៧) ប្រសិនបើតុលាការខ្មែរក្រហមកាត់ទោស តែមេដឹកនាំខ្មែរក្រហមចំនួន៥រូបតើអ្នកយល់ថា តុលាការខ្មែរក្រហមបាននាំមកនូវយុត្តិធម៌គ្រប់គ្រាន់សម្រាប់កម្ពុជាឬទេ?*

***លទ្ធផលនៃការស្ទាបស្ទង់មតិ***

***ការយល់ដឹងអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម***

*មជ្ឈមណ្ឌលឯកសារកម្ពុជាមិនធ្វើការវាយតម្លៃទៅលើកម្រិតយល់ដឹងរបស់មនុស្សម្នាក់ៗអំពីព័ត៌មានតុលាការខ្មែរក្រហមនោះទេ ។ ការវាយតម្លៃទៅលើកម្រិតយល់ដឹងព័ត៌មានអំពីតុលាការនេះគឺត្រូវធ្វើឡើងដោយអ្នកឆ្លើយតបទៅនឹងសំណួររបស់យើងរៀងៗខ្លួន ។ មនុស្សស្ទើរតែពាក់កណ្តាល ៤៤,២ ភាគរយបានឆ្លើយថាពួកគេដឹងព័ត៌មានតិចតួចអំពីតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ មនុស្សចំនួន២៦,៨ភាគរយមានអារម្មណ៍ថាពួកគេទទួលបានព័ត៌មានច្រើនគួរសម ។ មនុស្សចំនួនតែ១១,៦ភាគរយប៉ុណ្ណោះដែលបានប្រាប់ថា ពួកគេទទួលបានព័ត៌មានច្រើនជុំវិញបញ្ហាតុលាការខ្មែរក្រហមនេះ ។ ចំណែកមនុស្សចំនួន១៧,៣ភាគរយបាននិយាយថា ពួកគាត់មិន*

ដែលទទួលបានព័ត៌មានទាល់តែសោះអំពីតុលាការខ្មែរក្រហម ។

## ការគាំទ្រតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

នៅពេលដែលសួរថាតើមេដឹកនាំខ្មែរក្រហមគួរតែត្រូវកាត់ទោសដោយតុលាការខ្មែរក្រហមឬទេ មនុស្សភាគច្រើនលើសលប់ (៩២,៧ភាគរយ) បានសម្តែងនូវការគាំទ្រចំពោះតុលាការនេះ ហើយមានមនុស្សតែចំនួន៦,១ភាគរយប៉ុណ្ណោះដែលបញ្ចេញយោបល់ផ្ទុយពីនេះ ។ លទ្ធផលនេះសមស្របទៅនឹងការស្ទាបស្ទង់មតិលើកមុនៗជុំវិញការគាំទ្រតុលាការខ្មែរក្រហមនេះ ។ នៅក្នុងការសិក្សាមួយកាលពីឆ្នាំ២០០៨ ដោយវិទ្យាស្ថានសាធារណៈអន្តរជាតិ (International Republican Institute) មនុស្សចំនួន៦៩ភាគរយបានគាំទ្រយ៉ាងខ្លាំងក្លាចំពោះការកាត់ទោសមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហម ។ នៅក្នុងការស្ទាបស្ទង់មតិមួយទៀតដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងចំណោមអ្នកដែលអានទស្សនាវដ្តីស្វែងរកការពិតមនុស្សប្រមាណ ៥៦,៥៩ភាគរយបានចង្អុលបង្ហាញអំពីឆន្ទៈរបស់ពួកគេដែលចង់ឃើញការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ការស្ទាបស្ទង់មតិមួយទៀតដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមកាលពីឆ្នាំ២០០២ បានឲ្យដឹងថា មនុស្សចំនួន៦៨ភាគរយចង់ឲ្យមេដឹកនាំខ្មែរក្រហមទទួលខុសត្រូវចំពោះមុខច្បាប់នៅក្នុងតុលាការ ។

## ចំនួនមនុស្សត្រូវកាត់ទោស

ការយល់ឃើញរបស់ប្រជាជនខុសប្លែកគ្នាជុំវិញសំណួរទាក់ទងនឹងចំនួនមនុស្សត្រូវកាត់ទោស ។ មនុស្សច្រើនជាងពាក់កណ្តាល (៥៦,៨ភាគរយ) យល់ឃើញថាតុលាការខ្មែរក្រហមគួរតែកាត់ទោសមនុស្សច្រើនជាង៥នាក់ ។ មនុស្សតិចជាងពាក់កណ្តាល (៤១,៤ភាគរយ) ចង់ឃើញតុលាការខ្មែរក្រហមកាត់ទោសមនុស្សតែ៥នាក់ដែលកំពុងស្ថិតនៅក្នុងមន្ទីរឃុំឃាំងប៉ុណ្ណោះ អាសន្ន ។

ប៉ុន្តែគួរឲ្យកត់សម្គាល់ថាមនុស្សប្រមាណ៣០ភាគរយនៃអ្នកដែលចូលរួមនៅក្នុងការស្ទាបស្ទង់មតិនេះគឺជាក្មេងៗដែលកើតនៅក្រោយពេលរបបខ្មែរក្រហមដួលរលំ ។ ស្ទើរតែពីរភាគបីនៃមនុស្សជំនាន់ក្រោយនេះ (៦៧,៥ភាគរយ) យល់ស្របទៅនឹងគំនិតរបស់សហព្រះរាជអាជ្ញាបរទេស ដែលតាមរយៈនេះបានបង្ហាញឲ្យឃើញថាមនុស្សជំនាន់ក្រោយនេះមានការយល់ឃើញចំពោះយុត្តិធម៌ខុសប្លែកពីឪពុកម្តាយរបស់ពួកគេដែលជាជនរងគ្រោះដោយផ្ទាល់ ។

## ថវិកា

មនុស្សជាច្រើនយល់ថា បញ្ហាថវិកាគឺជាកត្តាសំខាន់មួយនៅក្នុងដំណើរការរបស់តុលាការខ្មែរក្រហម ។ បើពិនិត្យមើលអំពីការដែលថាថវិកាគឺជាបញ្ហាចម្បងរបស់តុលាការខ្មែរក្រហមចាប់តាំងពីពេលបង្កើតតុលាការនេះមកនោះ លទ្ធផលនៃការសិក្សានេះមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេ ។ រដ្ឋដែលជាម្ចាស់ជំនួយមានការស្ទាក់ស្ទើរក្នុងការផ្តល់ជំនួយហិរញ្ញវត្ថុទៅឲ្យខាងកម្ពុជាដោយសារតែមានការចោទប្រកាន់ពីអំពើពុករលួយនិងកង្វះតម្លាភាពដែលមិនទាន់បានដោះស្រាយ ។ ជាញឹកញាប់ខាងកម្ពុជាបានអំពាវនាវឲ្យមានការផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមទៀត ហើយនៅពេលមួយនោះបុគ្គលិកខាងកម្ពុជាត្រូវបង្ខំចិត្តធ្វើការមិនមានកម្រៃទៀតផង ដោយសារតែការខ្វះខាតថវិកា ។ នៅពេលកំពុងសរសេររបាយការណ៍នេះ ខាងកម្ពុជាបានប្រាប់អ្នកកាសែតជាថ្មីម្តងទៀតថាខ្លួនកំពុងមានបញ្ហាថវិកា និង មិនមានថវិកាសម្រាប់បើកបៀវត្សរ៍ឲ្យបុគ្គលិកកម្ពុជាទេនៅក្នុងខែមីនា ឆ្នាំ២០០៩ នេះ ។

ការសិក្សានេះបានរកឃើញថា៧៧,១ភាគរយក្នុងចំណោមអ្នកដែលចូលរួមធ្វើការស្ទាបស្ទង់មតិនេះជឿជាក់ថាតុលាការខ្មែរក្រហមគួរតែថ្លឹងថ្លែងចំនួនមនុស្សត្រូវកាត់ទោសជាមួយនឹងចំនួនថវិកាដែលមាន ។

## សណ្តាប់ធ្នាប់សាធារណៈ

ការស្ទាបស្ទង់មតិនេះបានស្រង់យកយោបល់របស់ប្រជាជនអំពីស្ថិរភាពសាធារណៈ ។ ដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាជាតិបានលើកឡើងថា ការកាត់ទោសមនុស្សបន្ថែមអាចបណ្តាលឲ្យប៉ះពាល់ដល់សុវត្ថិភាពនិងសន្តិភាពរបស់ប្រទេសកម្ពុជា ។ ប៉ុន្តែបើតាមលទ្ធផលដែលទទួលបានពីការស្ទាបស្ទង់មតិនេះវិញ មនុស្សច្រើនជាងពាក់កណ្តាល (៥៦,៦ភាគរយ) មិនយល់ស្របថាការកាត់ទោសមនុស្សបន្ថែមអាចបណ្តាលឲ្យមានអសណ្តាប់ធ្នាប់ឬអំពើហិង្សានៅក្នុងប្រទេសទេ ។ ដោយឡែកមនុស្សចំនួន

៣៧,៦ភាគរយជឿជាក់ថា ការកាត់ទោសមនុស្សបន្ថែមអាចបង្កឲ្យមានអស្ថិរភាពសង្គម ។ ចំណែកឯមនុស្សចំនួន៥,៩ភាគរយមិនមានយោបល់ ឬ មិនចង់បញ្ចេញយោបល់របស់ខ្លួនទេ ។

បើទោះបីជាមនុស្សភាគច្រើនជឿថាខ្មែរក្រហមមិនអាចវិលត្រឡប់មកវិញក៏ដោយ ក៏អ្នកខ្លះបានសម្តែងនូវការព្រួយបារម្ភថាការកាត់ទោសមនុស្សបន្ថែមអាចបង្ករអស្ថិរភាពសង្គមឬអំពើហិង្សាដែរ ។ អ្នកខ្លះបានសម្តែងប្រាប់នូវការព្រួយបារម្ភរបស់ខ្លួនទៅអ្នកនិពន្ធនិងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាថាការកាត់ទោសមនុស្សបន្ថែមឬការស៊ើបអង្កេតបន្ថែមនេះអាចមានការប៉ះពាល់ដល់អតីតព្រះមហាក្សត្រឬអ្នកកាន់ដំណែងខ្ពស់សព្វថ្ងៃ ហើយប្រសិនបើនេះជាការពិត វាអាចបង្កការប៉ះពាល់ដល់បញ្ហាសន្តិភាព ។

## ការផ្តល់អាទិភាពទៅលើការកាត់ទោសអ្នកដែលមានស្រាប់

ជនរងគ្រោះម្នាក់បានផ្តួចផ្តើមនូវគំនិតក្នុងការផ្តល់អាទិភាពកាត់ទោសទៅលើជនសង្ស័យដែលមានស្រាប់ឲ្យរួចរាល់សិនទើបតុលាការគួរពិភាក្សាគ្នាអំពីការស៊ើបអង្កេតបន្ថែមនេះ ។ សំណួរនេះមិនមែនផ្តួចផ្តើមដោយមជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ ។ ជនរងគ្រោះម្នាក់នេះមានចំណាប់អារម្មណ៍ចំពោះដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនិងបានលើកឡើងនូវគំនិតនេះក្នុងគោលបំណងចៀសវាងការពន្យារពេលកាត់ទោសដែលអាចកើតមានពីការមិនចុះសម្រុងគ្នានេះ ។ គាត់បានលើកឡើងថាសហព្រះរាជអាជ្ញាគួរតែផ្តល់អាទិភាពទៅលើជនសង្ស័យទាំង៥នាក់ដែលកំពុងជាប់ឃុំឃាំងសព្វថ្ងៃ ហើយការផ្តោតទៅលើការកាត់ទោសបន្ថែមគួរតែធ្វើឡើងនៅពេលក្រោយ ។ ការព្រួយបារម្ភធំបំផុតរបស់គាត់គឺថា ការមិនចុះសម្រុងគ្នានេះអាចបណ្តាលឲ្យមានការពន្យារពេលបន្ថែមទៀតនិងថាអ្នកដែលត្រូវយកមកកាត់ទោសឬអ្នកដែលរង់ចាំការកាត់ទោសអាចរួចផុតពីសំណាញ់យុត្តិធម៌ ដោយសារពួកគេចាស់ពេក ឈឺធ្ងន់ពេកឬករណីអាក្រក់បំផុតនោះគឺពួកគេអាចស្លាប់មុនពេលតុលាការរកឃើញអំពីទោសកំហុស ឬ ភាពគ្មានកំហុសរបស់ពួកគេ ។

ការសិក្សានេះបានរកឃើញថាប្រជាជន៤នាក់ក្នុងចំណោមប្រជាជន៥នាក់ដែលបានចូលរួមនៅក្នុងការស្ទាបស្ទង់មតិនេះមានការព្រួយបារម្ភដូចគ្នាទៅនឹងជនរងគ្រោះខាងលើនេះដែរ ។ មនុស្សស្ទើរតែ៨០ភាគរយ (៧៨,៥ភាគរយ) ចង់ឲ្យតុលាការខ្មែរក្រហមផ្តល់អាទិភាពទៅលើការកាត់ទោសមនុស្ស៥នាក់ដែលកំពុងត្រូវឃុំឃាំងខ្លួនសព្វថ្ងៃ និងចាំសម្រេចអំពីថាតើត្រូវស៊ើបអង្កេតលើជនសង្ស័យបន្ថែមនៅពេលក្រោយ ។ ប៉ុន្តែដោយសារតែថវិកានិងរយៈកាលមានការកំណត់នេះមិនទំនងជាជម្រើសដែលអាចទៅរួចនោះទេ ។

◆ ផ្តល់អាទិភាពលើជនសង្ស័យទាំង៥ដែលកំពុងជាប់ឃុំឃាំង
យល់ស្រប ៧៨,៥ភាគរយ
មិនយល់ស្រប ១៩,៦ភាគរយ
មិនដឹង ១,៩ភាគរយ
សរុប ១០០ភាគរយ

## កម្រិតនៃការពេញចិត្ត

សំណួរចុងក្រោយដែលសួរទៅកាន់អ្នកចូលរួមនៅក្នុងការស្ទាបស្ទង់មតិនេះគឺថាតើពួកគេមានអារម្មណ៍ថាយុត្តិធម៌ទទួលបានគ្រប់គ្រាន់ឬទេប្រសិនបើតុលាការខ្មែរក្រហមកាត់ទោសមនុស្សតែ៥នាក់ដែលកំពុងត្រូវឃុំខ្លួនបណ្តោះអាសន្នសព្វថ្ងៃនេះ ។ សំណួរនេះស្រដៀងគ្នាទៅនឹងសំណួរទី៣ដែរអំពីចំនួនមនុស្សដែលត្រូវយកមកកាត់ទោស ។ ប៉ុន្តែសំណួរនេះគឺដើម្បីស្រង់យកយោបល់របស់អ្នកចូលរួមស្ទាបស្ទង់មតិជុំវិញកម្រិតនៃការពេញចិត្តរបស់ពួកគេ ។ គួរឲ្យចាប់អារម្មណ៍ លទ្ធផលដែលទទួលបានគឺស្រដៀងគ្នាមែន ។ មនុស្សចំនួន៥៣ភាគរយមានអារម្មណ៍ថាពួកគេទទួលបានយុត្តិធម៌មិនគ្រប់គ្រាន់ទេ ប្រសិនបើគេកាត់ទោសមនុស្សតែ៥នាក់ដែលជា «មេដឹកនាំជាន់ខ្ពស់» និង «អ្នកទទួលខុសត្រូវខ្ពស់បំផុត» នេះ ។ មនុស្សចំនួន៤៤,៣ភាគរយជឿជាក់ថាយុត្តិធម៌គឺគ្រប់គ្រាន់បើទោះបីជាកាត់ទោសតែមនុស្ស៥នាក់នោះក៏ដោយ ។ មនុស្សចំនួន២,៧ភាគរយមិនបញ្ចេញយោបល់ ឬ មិនដឹង ។

## សេចក្តីសន្និដ្ឋាន

មនុស្សជាច្រើនមើលឃើញថា ការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញានេះជាបញ្ហានយោបាយ ។ រដ្ឋាភិបាលបានប្រកែកយ៉ាងខ្លាំងចំពោះការចោទប្រកាន់នេះ ។ ថ្មីៗនេះនៅក្នុងពិធីប្រគល់

សញ្ញាបត្រមួយកាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ នៅភ្នំពេញ ដែលត្រូវបានចាក់ផ្សាយនៅស្ថានីយប៉ុស្តិ៍បាយ័ន សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានរំឭកឡើងវិញនូវជ័យជម្នះមួយចំនួនដែលរដ្ឋាភិបាលសម្រេចបាន។ ជ័យជម្នះទាំងនោះរួមមាន ការធ្វើឲ្យដួលរលំរបបខ្មែរក្រហមយុទ្ធនាការយ៉ាងជោគជ័យប្រឆាំងទៅនឹងការវិលត្រឡប់មកវិញនូវរបបខ្មែរក្រហម ការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនិងការចាប់ខ្លួនអ្នកដែលតុលាការខ្មែរក្រហមសព្វថ្ងៃកំពុងកាត់ទោស ។ ជាងនេះទៅទៀត គាត់បានច្រានចោលនូវការមន្ទិលសង្ស័យមកលើឆន្ទៈនយោបាយរបស់រដ្ឋាភិបាលក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស និងបានបដិសេធថា ការខ្វែងគំនិតគ្នានៅតុលាការខ្មែរក្រហមមិនមានអ្វីពាក់ព័ន្ធនឹងរដ្ឋាភិបាលរបស់លោកនោះទេ។ បើទោះបីជាយ៉ាងណាក៏ដោយ ពាក្យសម្តីនេះប្រហែលជាមិនអាចធ្វើឲ្យជ្រះស្រឡះនូវមន្ទិលសង្ស័យនេះនោះទេ។ ចុងក្រោយបំផុត បើទោះបីជាសារជាតិនៃការខ្វែងគំនិតគ្នានេះជាអ្វីក៏ដោយ ក៏ការសម្រេចស្ថិតនៅលើចៅក្រមរបស់អង្គបុរេជំនុំជម្រះដោយយោងទៅលើឆន្ទានុសិទ្ធិនិងហេតុផលតាមផ្លូវច្បាប់ ។

បើយោងទៅតាមលទ្ធផលនៃការសិក្សានេះ មនុស្សច្រើនជាងពាក់កណ្តាលនៃចំនួនមនុស្ស១.១១០នាក់ (៥៦,៨ភាគរយ) ចង់ឲ្យតុលាការខ្មែរក្រហមជំនុំជម្រះជនសង្ស័យបន្ថែមទៀតដែលគេជឿថាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមដែរ ។ លទ្ធផលនេះគឺសមស្របទៅនឹងវេទិកាសាធារណៈមួយដែលធ្វើឡើងកាលពីពេលថ្មីៗនេះនៅខេត្តបន្ទាយមានជ័យ ដែលនៅទីនោះអ្នកចូលរួមប្រមាណ១០០នាក់ត្រូវបានសួរសំណួរថាតើពួកគេចង់ឲ្យមានការជំនុំជម្រះលើជនសង្ស័យបន្ថែមទៀតឬទេ? មនុស្សភាគច្រើនបានគាំទ្រឲ្យមានការជំនុំជម្រះបន្ថែមនេះ ។ ជាលទ្ធផលល្អ ការស្ទាបស្ទង់មតិនេះបានឲ្យដឹងថាប្រជាជនគិតថា ការគោរពនីតិរដ្ឋគឺជារឿងសំខាន់ ។ ប្រជាជនកម្ពុជាទាមទាឲ្យបញ្ចប់នូវនិទណ្ឌភាពយូរមកហើយរបស់របបខ្មែរក្រហមនិងបានទាមទារឲ្យមានការកាត់ទោសមនុស្សបន្ថែមទៀតដែលជឿជាក់ថាទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ តាមរយៈនេះចំនួនមនុស្សដែលត្រូវកាត់ទោសហាក់ដូចជាមិនសូវសំខាន់នោះទេ។ ប៉ុន្តែ ការស្ទាបស្ទង់មតិនេះបានបង្ហាញថា ប្រជាជនមានការព្រួយបារម្ភអំពីបញ្ហាធនធានថវិកានិងភាពចាស់ជរារបស់អតីតមេដឹកនាំខ្មែរក្រហមដែលជាជនត្រូវចោទ។ ជាក់ស្តែង កាសែត **AFP** កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ នេះបានរាយការណ៍ថា អៀង ធីរិទ្ធ អាយុ៧៦ឆ្នាំ បានប្រាប់ចៅក្រមតុលាការខ្មែរក្រហមនៅក្នុងសវនាការជំនុំជម្រះលើបណ្តឹងជំទាស់នឹងការឃុំខ្លួនជាបន្តថា មេធាវីរបស់គាត់នឹងនិយាយជំនួសគាត់ដោយសារគាត់ «ខ្សោយពេក»។ ពីរថ្ងៃក្រោយមក នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ សវនាការលើបណ្តឹងជំទាស់របស់ អៀង សារី ប្រឆាំងនឹងការឃុំខ្លួនបន្តត្រូវលើកទៅធ្វើនៅថ្ងៃទី២ ខែមេសា ដោយសារ អៀង សារី ឈឺមិនអាចបង្ហាញខ្លួននៅក្នុងសវនាការបាន។ ជាងនេះទៅទៀត នួន ជា



ពេលនេះមានអាយុ៨៤ឆ្នាំ ចំណែកឯ ខៀវ សំផន មានអាយុ ៧៩ឆ្នាំហើយ ។ ថ្មីៗនេះ មនុស្សម្នាក់ក្នុងចំណោមមនុស្ស៦នាក់ ដែលសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យធ្វើការស៊ើបអង្កេត នោះបានស្លាប់ទៅហើយសូម្បីតែនៅមុនពេលដែលជម្លោះរបស់ សហព្រះរាជអាជ្ញាទាំងពីរត្រូវបានដោះស្រាយទៅទៀត ។

ក្រៅពី ឌុច ដែលបានសារភាពទទួលស្គាល់អ្វីដែលបានកើតឡើងនៅក្នុងមន្ទីរស-២១ ជនសង្ស័យផ្សេងទៀតមិនដែលទទួលស្គាល់នូវកំហុសនោះទេ ។ បើយើងពិនិត្យមើលអំពីការដែលថា ការជំនុំជម្រះនឹងត្រូវចំណាយពេលច្រើនទៀត និងថាអ្នកទាំងនេះអាចប្តឹងជំទាស់បន្ថែមទៀតក្នុងករណីដែលត្រូវសាលាដំបូងរកឃើញថាមានទោស នោះវាទំនងណាស់ថាការជំនុំជម្រះនេះ ប្រហែលជានឹងត្រូវចំណាយពេលជាច្រើនបន្ថែមទៀតយ៉ាងហោចណាស់ក៏៣ឆ្នាំទៀតដែរ ។ លើសពីនេះទៀត បើពិនិត្យមើលអំពីអាយុចាស់ជរានិងសុខភាពមិនល្អរបស់អតីតមេដឹកនាំខ្មែរក្រហមវិញ ជនត្រូវចោទខ្លះអាចត្រូវដោះលែងដោយសារគាត់ចាស់ជរាពេកមិនអាចជំនុំជម្រះបានឬអាចស្លាប់ទៀតផង ។

ប្រឈមមុខនឹងកាលៈទេសៈនេះ តុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមគួរតែពិចារណាអំពីការព្រួយបារម្ភរបស់ប្រជាជននៅក្នុងរបាយការណ៍នេះ ។ ជំនឿចិត្តទៅលើតុលាការនេះអាចស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ណាស់ ប្រសិនបើជនត្រូវចោទខ្លះឬច្រើនមិនអាចកាត់ទោសបានដោយសារតែភាពចាស់ជរាឬដោយសារសុខភាពទ្រុឌទ្រោមពេកឬអាចស្លាប់មុនពេលតុលាការចេញសាលក្រមចុងក្រោយ ។

**ដី ខេមរិទ្ធិ**



រូបភាពនេះត្រូវបានថតនៅក្នុងប្រាសាទគក់ទ្រូង នៅក្នុងប្រាសាទអង្គរវត្ត ។ ប្រាសាទនេះមានឈ្មោះដូច្នេះ គឺដោយសារតែពេលដែលគក់ទ្រូងនៅក្នុងប្រាសាទនេះធ្វើឲ្យមានសំឡេងខ្ទរ ។ នៅក្នុងប្រទេសកម្ពុជា ប្រជាជននាំគ្នាគក់ទ្រូងនៅពេលដែលពួកគេចង់សម្តែងចេញនូវការព្រួយបារម្ភខ្លាំងដែលមិនអាចពណ៌នាបានរបស់ពួកគេ ។ មនុស្សនៅក្នុងរូបថតនេះគឺជាសិស្សថ្នាក់ទីប្រាំពីរដែលធ្វើទស្សនកិច្ចសិក្សាទៅកាន់ខេត្តសៀមរាប ។ សិស្សទាំងនេះមកពីស្រុកភ្នំស្រុក ខេត្តបាត់ដំបង ។ សម្រាប់សិស្សខ្លះ នេះគឺជាលើកទីមួយដែលពួកគេបានមកទស្សនាប្រាសាទអង្គរវត្ត ។ ថតដោយ អេង កុកថាយ ខែកុម្ភៈ ឆ្នាំ២០០៩

# ព័ត៌មានជ័យជម្នះដែលឈ្នះដោយកងទ័ពបដិវត្តន៍និងប្រជាជន របស់កម្ពុជាលើកងទ័ពឈ្លានពានវៀតណាម

ចាប់តាំងពីខែកញ្ញា ឆ្នាំ១៩៧៧ កងទ័ព «សាធារណរដ្ឋសង្គមនិយមវៀតណាម» រួមមានកងទ័ពជើងគោកជាច្រើនដែលត្រូវបានបញ្ជូនពីហាណូយជាមួយនឹងរថក្រោះរាប់រយគ្រឿងនិងកាំភ្លើងធំរាប់រយដើម ដូនកាលមានការខបត្ថម្ភផ្នែកកងទ័ពអាកាសដែលជាជំនួយពីក្រុមប្រឹក្សាបរទេសបានបង្កើតការវាយប្រហារដែលមានលក្ខណៈជាប្រព័ន្ធនិងធំសម្បើមនៃការរំលោភឈ្លានពានក្នុងគោលបំណងយុត្តិសាស្ត្រចង់ដាក់រដ្ឋកម្ពុជានៅក្រោមការគ្រប់គ្រងរបស់វៀតណាមនៅក្នុង «សហព័ន្ធឥណ្ឌូចិន» ។ ប៉ុន្តែកងទ័ពបដិវត្តន៍និងប្រជាជនក្លាហានរបស់កម្ពុជាស្ថិតនៅក្រោមការដឹកនាំដែលប្រកបដោយភាពទៀងត្រង់ យុត្តិធម៌និងឈ្លាសវៃរបស់បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តន៍នូវមាគ៌ាសង្គ្រាមនយោបាយប្រជាជនជាមួយនឹងគំនិតច្នៃប្រឌិតនិងប្រសិទ្ធភាពដល់កម្រិតកំពូលហើយបានទទួលបាននូវជ័យជម្នះដ៏ជោគជ័យស្ពារ្យលើសត្រូវវៀតណាម ដែលជាពួកឈ្លានពាន ពួកវាទទីនិយមនិងពួកចង់លេបយកទឹកដីកម្ពុជា ។

ការវាយតម្លៃទៅលើជ័យជម្នះទាំងនេះអាចសរុបសេចក្តីដូចខាងក្រោម ៖

**នៅទីតាំងស្រុកស្នួលខេត្តក្រចេះ**

ចាប់ពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៧ ដល់ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៨ យើងបានបញ្ឈប់សកម្មភាពរបស់សត្រូវចំនួន៦០០នាក់ដែលអ្នកទាំងនោះត្រូវបានសម្លាប់និងរងរបួស ។

ចំណែកខាងយើងមាន៩នាក់ស្លាប់ដោយកិត្តិយសនៅក្នុងសមរភូមិនិង១០២នាក់បានរងរបួស ដែលក្នុងនោះរួមមាន១០នាក់រងរបួសធ្ងន់ ។

**ភូមិភាគនិរតី**

ចាប់ពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៧ ដល់ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៨ ៖

១) ទីតាំងខេត្តតាកែវៈ យើងបានបញ្ឈប់សកម្មភាពរបស់សត្រូវចំនួនជិត៣០០០នាក់ ដែលអ្នកទាំងនោះត្រូវបានសម្លាប់និងរងរបួស ។ យើងបានបំផ្លាញនិងកម្ទេចរថក្រោះចំនួន២៤


រូបថតឆ្នាំ១៩៧៩


រូបថតឆ្នាំ១៩៧៩

គ្រឿងចោល ។ ចំណែកខាងយើងមាន៨០នាក់បានស្លាប់ដោយកិត្តិយសក្នុងសមរភូមិ និង៣០០នាក់ទៀតបានរងរបួស ។

២) ទីតាំងខេត្តកំពតៈ យើងបានបញ្ឈប់សកម្មភាពរបស់សត្រូវចំនួន២.១០០នាក់ ដែលអ្នកទាំងនោះត្រូវបានសម្លាប់និងរងរបួស ។ យើងបានបំផ្លាញនិងកម្ទេចរថក្រោះចំនួន១២គ្រឿង ។ ចំណែកខាងយើងមាន៦០នាក់បានស្លាប់ដោយកិត្តិយសក្នុងសមរភូមិ និង១៨០នាក់ទៀតបានរងរបួស ។

៣) ទីតាំងស្រុកបាសាក់ កោះធំៈ យើងបានបញ្ឈប់សកម្មភាពរបស់សត្រូវលើសពី៩០០នាក់ ដែលអ្នកទាំងនោះត្រូវបានសម្លាប់និងរងរបួស ។ ចំណែកខាងយើងមាន១២នាក់បានស្លាប់ដោយកិត្តិយសក្នុងសមរភូមិ និង៤០នាក់ទៀតបានរងរបួស ។

## ភូមិភាគខាងកើត

ចាប់ពី ខែកញ្ញា ឆ្នាំ១៩៧៧ ដល់ថ្ងៃទី៥ មករាឆ្នាំ១៩៧៨ៈ

១) ទីតាំងផ្លូវជាតិលេខ៧ៈ យើងបានបញ្ឈប់សកម្មភាពរបស់សត្រូវលើសពី១៨.០០០នាក់ដែលអ្នកទាំងនោះត្រូវបានសម្លាប់និងរងរបួស ។ យើងបានបំផ្លាញនិងកម្ទេចរថក្រោះចំនួន៦៣គ្រឿង ។ ចំណែកខាងយើងមាន៣០៩នាក់បានស្លាប់ដោយកិត្តិយសក្នុងសមរភូមិ និង៦០០នាក់ទៀតបានរងរបួស ។

២) ទីតាំងខេត្តស្វាយរៀងៈ យើងបានបញ្ឈប់សកម្មភាពរបស់សត្រូវលើសពី៦.០០០នាក់ដែលអ្នកទាំងនោះត្រូវបានសម្លាប់និងរងរបួស ។ យើងបានបំផ្លាញនិងកម្ទេចរថក្រោះចំនួន១៨គ្រឿងចោល ។

នៅទីតាំងស្រុកក្រែកគេឃើញមានជនជាតិអឺរ៉ុបពីរនាក់ត្រូវបានសម្លាប់នៅក្នុងរថក្រោះរបស់ពួកគេដែលត្រូវបានបំផ្លាញដោយកងទ័ពរបស់យើង ។ ពួកគេមានច្រមុះស្រួច សក់ពណ៌ក្រហម ពាក់ខោអាវការពារកម្តៅពណ៌សដូចពួកកម្មករផ្ទើដែកថែប ។ នៅទីតាំងនេះភាសារុស្ស៊ីត្រូវបានប្រើប្រាស់សម្រាប់ការសន្ទនារវាងប្រជាជនពីសហភាពអឺរ៉ុបសូវៀតនិងប្រជាជនវៀតណាម ។

យើងបានចាប់ខ្លួនប្រជាជនវៀតណាមខាងជើងមួយចំនួនពីតំបន់វៀតណាមកងពលលេខ៣២០, ៩, ៧ និងលេខ ៥ ។

នៅគ្រប់ទីកន្លែងទាំងអស់ សត្រូវវៀតណាមជាច្រើនដែលជាពួកចង់លេបយកទឹកដីកម្ពុជាបានចូលលុកលុយនិងឈ្លានពានព្រមទាំងបំផ្លាញស្រូវ ស្រែ និងវប្បធម៌ ហើយបានដុតបំផ្លាញភូមិជាច្រើនរបស់សហករណ៍យើង ដែលអ្នកទាំងនោះត្រូវបានសម្លាប់យ៉ាងសាហាវដោយការបាញ់កាំភ្លើងយន្តរបស់ពួកវាមកលើប្រជាជនយើង ។ ស្របពេលជាមួយគ្នានេះផងដែរ ពួកវាបានចាប់រំលោភលើកងចល័តនារីផ្នែកផលិតកម្មស្រូវរបស់យើងយ៉ាងព្រៃផ្សៃ ប្រកបដោយឥរិយាបថផ្តាច់ការ ពួកវាបានប្លន់យកស្រូវ





ប្រជាជនអបអរសាទរថ្ងៃជ័យជម្នះលើរបបខ្មែរក្រហម ឆ្នាំ១៩៧៩

ជាច្រើនពាន់តោននិងលួចយកទ្រព្យសម្បត្តិ រទេះ សត្វ មាន់ ទា ក្ងាន ជាច្រើនក្បាលពីប្រជាជនក្នុងតំបន់ ។ ពួកសត្រូវឈ្លានពានវៀតណាមដែលចង់លេបយកទឹកដីកម្ពុជាបានដុតបំផ្លាញចម្ការដំណាំនិងរោងចក្រកៅស៊ូជាច្រើនកន្លែងនៅមេមុតនិងក្រែក ព្រមទាំងបានប្លន់យកជ័រកៅស៊ូនិងកៅស៊ូក្រែបជាច្រើនតោនទៀតផង ។ ស្ថានភាពបច្ចុប្បន្ននិងជាក់ស្តែងនៅតាមទីតាំងគឺមានដូចខាងក្រោមៈ

កងទ័ពបដិវត្តន៍ក្លាហានរបស់កម្ពុជាបានអនុវត្តគំនិតច្នៃប្រឌិតនូវមាគ៌ាសង្គ្រាមនយោបាយប្រជាជន ដោយធ្វើការហ៊ុមព័ទ្ធសត្រូវ ធ្វើការវាយប្រហារពីខាងមុខនិងវាយបំបែកមូលដ្ឋានវាយប្រហារពីគ្រប់ទិសដៅទាំងអស់និងចូលទៅក្នុងមូលដ្ឋានរបស់សត្រូវដែលស្ថិតនៅក្នុងទឹកដីរបស់យើង ហើយនឹងកម្ទេចសត្រូវជាបំណែកៗ បង្ខំសត្រូវឲ្យប្រមូលកងកម្លាំងរបស់ពួកវាទាំងអស់បន្ទាប់មកកម្ចាត់ពួកវាចោល ។

**ទីតាំងភូមិភាគនិរតីៈ**

១) ទីតាំងខេត្តកំពតៈ នៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៨ យើងបានកម្ចាត់ចោលនិងបោសសម្អាតរាល់សត្រូវទាំងអស់ចេញពីតំបន់ទាំងនេះ ។

២) ទីតាំងខេត្តតាកែវៈ នៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៨ យើងបានកម្ចាត់និងបោសសម្អាតរាល់សត្រូវទាំងអស់នៅកោះណ្តែតចម្ងាយ៣០គីឡូម៉ែត្រពីព្រំដែននិងនៅឯគីរីវង្សចម្ងាយ១៥គីឡូម៉ែត្រពីព្រំដែន ។ យើងបានបំផ្លាញកងពលធំពីរកន្លែងរបស់សត្រូវ រួមមានកងពលធំលេខ៩ ។ យើងបានកម្ចាត់ចោលនិងបោសសម្អាតរាល់សត្រូវទាំងអស់ចេញពីតំបន់ទាំងនេះ ។

**ទីតាំងភូមិភាគខាងកើតៈ**

១) ទីតាំងផ្លូវជាតិលេខ៧ៈ នៅថ្ងៃទី៥ ខែមករា យើងបានកម្ចាត់ចោលសត្រូវរបស់យើងទាំងអស់នៅឯបាធាយចម្ងាយ៣០គីឡូម៉ែត្រពីព្រំប្រទល់ ។ នៅគោកស្រុកចម្ងាយ១០គីឡូម៉ែត្រខាងជើងបាធាយ, កណ្តោលជ្រុំ, ភូមិស្មោង ដែលមានចម្ងាយ២០គីឡូម៉ែត្រពីព្រំប្រទល់ ។ ចំណែកនៅក្រែកនិងមេមត់ យើងបានកម្ចាត់និងបោសសម្អាតរាល់សត្រូវទាំងអស់ចេញពីតំបន់ទាំងនេះ ។

២) ទីតាំងខេត្តស្វាយរៀងៈ

ក) ទីតាំងផ្លូវជាតិលេខ១៣ និងខាងជើងផ្លូវជាតិលេខ១ៈ

នៅពេលព្រឹកថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ យើងបានកម្ចាត់និងបោសសម្អាតរាល់សត្រូវទាំងអស់ដែលស្ថិតនៅតាមដងផ្លូវជាតិលេខ១៣ ។ បច្ចុប្បន្ននេះ កងកម្លាំងរបស់យើងកំពុងតែបន្តធ្វើការបោសសម្អាតសត្រូវទាំងអស់នៅតាមព្រំដែន ។

ខ) ទីតាំងផ្លូវជាតិលេខ១ៈ

នៅពេលល្ងាចថ្ងៃទី៥ ខែមករា យើងបានកម្ចាត់សត្រូវនៅពោធិ៍សាត់ដែលមានចម្ងាយ៣០គីឡូម៉ែត្រពីព្រំដែន ។

នៅព្រឹកថ្ងៃទី៦ ខែមករា វេលាម៉ោង៩ព្រឹក យើងបានកម្ចាត់សត្រូវនៅជីពរកំពង់រោទិ៍ និងបានបន្តដំហានវិវត្តន៍ទៅមុខរបស់យើង ។ យើងកំពុងតែធ្វើការបោសសម្អាតសត្រូវរបស់យើងនៅបាវិត ។

៣) ទីតាំងខេត្តក្រចេះៈ នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ យើងបានធ្វើការវាយប្រហារទៅលើសត្រូវរបស់យើងនៅគ្រប់គោលដៅទាំងអស់ ដោយធ្វើការប្រយុទ្ធដែលនាំឲ្យមានការខូចខាតយ៉ាងខ្លាំងលើពួកវា ។ ពួកសត្រូវត្រូវបានទទួលបរាជ័យយ៉ាងអាម៉ាស់ ។ មេដឹកនាំរបស់ពួកវាបានភៀសខ្លួនទៅកែវសីមា (ខេត្តមណ្ឌលគិរី) ។ យើងកំពុងតែបន្តធ្វើការកម្ចាត់ពួកសត្រូវទាំងអស់នេះចោល ។ មូលដ្ឋានទ័ពរបស់ពួកវាត្រូវកម្ទេចចោល ហើយយើងក៏កំពុងបន្តកម្ចាត់ពួកវាចោលផងដែរ ។ បច្ចុប្បន្ននេះ យើងបានគ្រប់គ្រងទាំងស្រុងទៅលើទីតាំងផ្លូវជាតិលេខ៧ និងលេខ៨ ។ ពួកសត្រូវបានទទួលរងនូវភាពបរាជ័យដ៏អាម៉ាស់ ។

នៅគ្រប់ទីតាំងទាំងអស់ កងទ័ពបដិវត្តន៍ក្លាហានរបស់កម្ពុជាកូនប្រុសនិងកូនស្រីដ៏ល្អរបស់ប្រជាជនក្លាហានកម្ពុជាកំពុងតែបន្តការប្រយុទ្ធប្រឆាំងយ៉ាងហ្មត់ចត់របស់ខ្លួនលើពួកកងទ័ពឈ្លានពានវៀតណាមដែលនៅសេសសល់ជាពួកចង់លេបយកទឹកដីនិងធ្វើការកម្ចាត់ពួកវាចោលទាំងស្រុងចេញពីទឹកដីកម្ពុជាជាទីស្រឡាញ់របស់យើង ។

ជាសរុប យើងបានបញ្ឈប់សកម្មភាពសត្រូវរបស់យើងចំនួន២៩.២០០ដែលអ្នកទាំងនោះត្រូវបានសម្លាប់និងរងរបួស ។ បន្ទាប់មក យើងបានបញ្ឈប់សកម្មភាពកងពលធំរបស់សត្រូវចំនួនប្រាំកន្លែងផងដែរ ។

**ឯកសារD២៩០៨៣**

# ការស៊ើបអង្កេតរបស់តុលាការលើករណី ឌុច និងការពិនិត្យ នៅលើដំណើរការអង្គជំនុំជម្រះ

កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រហែលជាសមាជិកនៃរបបខ្មែរក្រហមដែលត្រូវបានស្គាល់ជាអន្តរជាតិនិងត្រូវបានចាប់ខ្លួនមុនពេលអង្គជំនុំជម្រះ ។ ឌុច ជាមនុស្សទីមួយដែលត្រូវបានចោទប្រកាន់និងឃុំខ្លួនដោយតុលាការ ហើយក៏ជាមនុស្សទីមួយដែលនឹងត្រូវបានកាត់ទោសជាផ្លូវការដែរ ។ ការកាត់ទោស ឌុច នឹងចាប់ផ្តើមនៅខែមីនា ឆ្នាំ២០០៩ ។

## ១) ជីវប្រវត្តិសង្ខេប

ឌុច កើតនៅឆ្នាំ១៩៤២ នៅប្រទេសកម្ពុជា ជាជនត្រូវចោទដែលមានវ័យក្មេងជាងគេមុនពេលមានសវនាការអង្គជំនុំជម្រះ ។ ឌុច ជាគ្រូបង្រៀនគណិតវិទ្យាដែលទទួលការបណ្តុះបណ្តាល ហើយគាត់ចូលរួមជាមួយខ្មែរក្រហមនៅទសវត្សរ៍៦០ ។ ឌុច ត្រូវបានឃុំខ្លួនដោយរដ្ឋាភិបាលកម្ពុជា ប៉ុន្តែ ត្រូវដោះលែងវិញ ដោយសារផ្នែកមួយនៃការលើកលែងទោសទូទៅ ខណៈពេលរដ្ឋប្រហារ លន់ នល់ ឆ្នាំ១៩៧០ ។ បន្ទាប់ពីជ័យជម្នះខ្មែរក្រហមនៅឆ្នាំ១៩៧៥ ឌុច ត្រូវបានចូលរួមក្នុងការបង្កើតគុកនៅភ្នំពេញដែលត្រូវបានរំដោះថ្មីៗ ។ ពីរឆ្នាំក្រោយមក ឌុច បានក្លាយទៅជាប្រធានមន្ទីរសន្តិបាលនគរបាលសម្ងាត់របស់ខ្មែរក្រហមនិងមេបញ្ជាការគុកស-២១ (ដែលស្គាល់ជាទួលស្លែង) ។ ឌុច គៀសខ្លួនពីភ្នំពេញនៅឆ្នាំ១៩៧៩ នៅពេលរបបខ្មែរក្រហមដួលរលំ ។

ខណៈពេលដែលចលនាខ្មែរក្រហមត្រូវបានបែកខ្ញែក ឌុច បាត់បង់ទំនាក់ទំនងជាមួយមេដឹកនាំរបស់ខ្លួននិងចលនាខ្មែរក្រហម ។ នៅឆ្នាំ១៩៩៦ ឌុច បានប្តូរទៅកាន់សាសនាគ្រិស្ត ។ គាត់ត្រូវបានចាប់ខ្លួននិងឃុំឃាំងដោយអាជ្ញាធរកម្ពុជា នៅឆ្នាំ១៩៩៩ បន្ទាប់ពីអ្នកការសែតដឹងពីអត្តសញ្ញាណរបស់គាត់ ។

## ២) ផ្ទេរទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងទទួលការស៊ើបអង្កេតដោយតុលាការ

ការគ្រប់គ្រងនិងនីតិវិធីរបស់អង្គជំនុំជម្រះយោងតាមប្រពៃណីច្បាប់ខុំមិនឡនិងស៊ីវិលឡ និងរួមបញ្ចូលលក្ខណៈខ្លះដែលមនុស្សមួយចំនួនប្រហែលជាមិនដឹងដោយសារគេមិនដឹងពីប្រព័ន្ធតុលាការអាមេរិក ។ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សហព្រះរាជអាជ្ញាសំដៅទៅលើមនុស្សដែលធ្វើការចោទប្រកាន់ជនសង្ស័យនិងបទល្មើសទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ការិយាល័យសហចៅក្រមស៊ើបអង្កេតដើរតួនាទីដូចជាគណៈវិនិច្ឆ័យនៅអាមេរិក ទោះបីជាវាមានឯករាជ្យភាពច្រើនជាងក៏ដោយ ។ ការិយាល័យសហចៅក្រមស៊ើបអង្កេតដឹកនាំការស៊ើបអង្កេតជនត្រូវចោទដោយខ្លួនឯង ហើយនៅទីបញ្ចប់ធ្វើការសម្រេចថាតើគួរតែចេញដីការៀបរាប់ពីបទឧក្រិដ្ឋ ដែលនឹងត្រូវធ្វើការអះអាងនៅពេលកាត់



សវនាបឋមក្នុងការជំនុំជម្រះក្តីរឿងឌុច ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩

ទោស ។ ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនមានយុត្តាធិការស៊ើបអង្កេតទៅលើសកម្មភាព ល្គិកណាសហព្រះរាជអាជ្ញាបានស្នើឲ្យធ្វើការស៊ើបអង្កេត ប៉ុន្តែសហព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់ទេ ប្រសិនបើមិនមានការអនុញ្ញាតពីការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ការកាត់ទោសនឹងចាប់ផ្តើមបន្ទាប់ពីការិយាល័យសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយសង្ស័យដែលហៅថាជនត្រូវចោទ ។ នៅអំឡុងពេលស៊ើបអង្កេតប្រសិនបើមានករណីដាក់លាក់ ការិយាល័យសហចៅក្រមស៊ើបអង្កេតអាចសម្រេចឃុំខ្លួនជនត្រូវចោទដែលហៅថាការឃុំខ្លួនបណ្តោះអាសន្នបាន ។

នៅខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញាបានដាក់ដីកាបញ្ជូនរឿងទៅស៊ើបសួរ ឌុច និងជនត្រូវចោទទាំង៤រូបដោយសម្ងាត់ទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ការិយាល័យសហចៅក្រមស៊ើបអង្កេតសម្រេចឃុំខ្លួន ឌុច បណ្តោះអាសន្ននៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ អាស្រ័យហេតុនេះ ឌុច ត្រូវបានផ្ទេរពីមន្ទីរឃុំឃាំងតុលាការយោធាកម្ពុជាទៅអង្គជំនុំជម្រះ ។ មេធាវីរបស់ ឌុច ធ្វើការប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចឃុំឃាំង ឌុច ដោយអះអាងថា ដំណោះស្រាយតែមួយគត់នៅក្រោមច្បាប់អន្តរជាតិចំពោះការបំពានទៅលើ ឌុច ដោយឃុំខ្លួនគាត់រយៈពេល ៨ឆ្នាំ ដោយមិនមានការកាត់ទោសដោយតុលាការយោធាកម្ពុជា គឺការដោះលែង ឌុច ភ្លាមៗ ហើយម៉្យាងទៀត ឌុច មិនស័ក្តិសមនឹងវិធានផ្ទៃក្នុង៦៣(៣) ដែលចែងអំពីការឃុំខ្លួនបណ្តោះអាសន្នទេ ។ អង្គបុរេជំនុំជម្រះដែលមានចៅក្រមកម្ពុជា៣រូបនិងចៅក្រមអន្តរជាតិ២រូបបានបើកសវនាការលើបណ្តឹងឧទ្ធរណ៍នេះ ។ ចៅក្រម ន័យ ថុល បានដកខ្លួនចេញពីសវនាការបណ្តឹងឧទ្ធរណ៍ ហើយត្រូវបានជំនួសដោយចៅក្រមបម្រុងគឺចៅក្រម ប៉ែន ពេជ្រសាលី ។ អង្គបុរេជំនុំជម្រះយល់ស្របនឹងសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលសម្រេចឃុំខ្លួន ឌុច នៅអំឡុងពេលស៊ើបអង្កេតដោយមូលហេតុថាការឃុំឃាំងគាត់ពីមុនដោយតុលាការយោធាមិនជាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះឡើយ អាស្រ័យហេតុនេះ ចៅក្រមនៃអង្គជំនុំជម្រះមិនអាចដោះលែងគាត់បានឡើយ ។ ដោយសារ ឌុច ស្របនឹងលក្ខណៈនៃវិធានផ្ទៃក្នុង៦៣(៣) ការិយាល័យសហចៅក្រមស៊ើបអង្កេតសម្រេចឃុំខ្លួន ឌុច នៅអំឡុងពេលស៊ើបអង្កេត ។

នៅខែកញ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេតបានបំបែកការទទួលខុសត្រូវរបស់ ឌុច ចំពោះឧក្រិដ្ឋកម្មដែល ឌុច បានប្រព្រឹត្តនៅមន្ទីរស-២១ចេញពីបទល្មើសដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ដែលស្ថិតនៅក្រោមការស៊ើបអង្កេតរបស់តុលាការ ។ ឌុច សហការជាមួយការស៊ើបអង្កេតរបស់តុលាការហើយយល់ស្របនឹងបទសម្ភាសន៍ចំនួន២១ ។ នៅខែឧសភា ឆ្នាំ២០០៨ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួន ។ នៅខែកក្កដា មេធាវីការពារក្តីនិងព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពរនិងអនុស្សរណៈឆ្លើយតបជាបន្តបន្ទាប់ ។

នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ការិយាល័យសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយចោទប្រកាន់ ឌុច ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ ។ ឌុច ត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តបញ្ជា រៀបចំផែនការញុះញង់ ជួយនិងជំរុញឲ្យមានបទល្មើសទាំងនោះ ។ គាត់ក៏ត្រូវបានចោទប្រកាន់នៅក្រោមគោលការណ៍នៃការទទួលខុសត្រូវក្រោមបទបញ្ជា ។ ទោះបីជាព្រះរាជអាជ្ញាបានស្នើឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេត ឌុច ចំពោះបទល្មើសមនុស្សឃាតនិងទារុណកម្មដែលជាបទល្មើសក្នុងស្រុកក៏ដោយ ក៏ការិយាល័យសហចៅក្រមស៊ើបអង្កេតបានបដិសេធនឹងសំណើនោះដែរ ហើយលុបចោលបទល្មើសទាំងនោះពីដីកាដំណោះស្រាយថ្ងៃទី៨ ខែសីហា ដោយមូលហេតុថាបទល្មើសទាំងនោះបានដាក់បញ្ចូលក្នុងបទល្មើសអន្តរជាតិដែលយកមកចោទប្រកាន់ ឌុច រួចទៅហើយ ។

### ៣) បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាដំណោះស្រាយ

ដោយមិនពេញចិត្តនឹងការខកខានរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលមិនចោទប្រកាន់ ឌុច ចំពោះបទល្មើសមនុស្សឃាតនិងទារុណកម្មដែលជាបទល្មើសក្នុងស្រុកនិងការខកខានមិនបានដាក់ឲ្យ ឌុច ទទួលខុសត្រូវជាសហចារី សហ-

ព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ។ បណ្តឹងឧទ្ធរណ៍ត្រូវបានបើកសវនាការដោយចៅក្រម៥រូបនៅអង្គបុរេជំនុំជម្រះ ទោះបីជាចៅក្រម ន័យ ថុល បានដកខ្លួន ហើយត្រូវបានជំនួសដោយចៅក្រម ប៉ែន ពេជ្រសាលី ក៏ដោយ ។

ចំពោះមូលហេតុទីមួយនៃបណ្តឹងឧទ្ធរណ៍គឺការមិនរាប់បញ្ចូលបទល្មើសក្នុងស្រុកសហព្រះរាជអាជ្ញាបានអះអាងថាការបកស្រាយពន្យល់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលថាបទល្មើសអន្តរជាតិបានដាក់បញ្ចូលបទល្មើសក្នុងស្រុករួចទៅហើយនឹងរារាំងមិនឲ្យមានការចោទប្រកាន់បទល្មើសក្នុងស្រុកនៅតុលាការ ។ ជាងនេះទៅទៀតសហព្រះរាជអាជ្ញាបានអះអាងថាបទល្មើសអន្តរជាតិមានធាតុផ្សំដែលមិនមាននៅក្នុងបទល្មើសក្នុងស្រុកហើយបទល្មើសក្នុងស្រុកនីមួយៗមានធាតុផ្សំដែលមាននៅក្នុងបទល្មើសអន្តរជាតិ ។ មេធាវីការពារក្តីមិនមានយោបល់អ្វីចំពោះបញ្ហានេះទេ ប៉ុន្តែបានអះអាងថាវាគួរតែត្រូវយកមកពិចារណានៅតុលាការហើយការកែប្រែដីកាដំណោះស្រាយនឹងបង្កឲ្យមានការពន្យារពេលដោយមិនសមហេតុសមផល ។

ចំពោះមូលហេតុទីពីរនៃបណ្តឹងឧទ្ធរណ៍ការខកខានមិនចោទប្រកាន់ ឌុច ឲ្យទទួលខុសត្រូវជាសហចារីនៅក្រោមទម្រង់នៃការទទួលខុសត្រូវជាសហកម្មឧក្រិដ្ឋកម្មរួមសហព្រះរាជអាជ្ញាបានអះអាងថាទម្រង់នៃការទទួលខុសត្រូវចំពោះការបញ្ជាញុះញង់និងមានផែនការដែលមាននៅក្នុងការចោទប្រកាន់មិនទូលាយគ្រប់គ្រាន់សម្រាប់គ្របដណ្តប់លើសកម្មភាពឧក្រិដ្ឋកម្មរបស់ ឌុចហើយទម្រង់នៃការទទួលខុសត្រូវពីរផ្សេងទៀតរបស់ការចោទប្រកាន់ដែលជាការសមគំនិតនិងរួមគំនិត និងការទទួលខុសត្រូវជាអ្នកដឹកនាំមិនបានបង្ហាញពីតួនាទីឧក្រិដ្ឋកម្មមជ្ឈិមដែល ឌុច បានប្រព្រឹត្តនៅមន្ទីរ ស-២១ ។ សហព្រះរាជអាជ្ញាអះអាងថាសហកម្មឧក្រិដ្ឋកម្មរួមស័ក្តិសមបំផុតសម្រាប់យកមកបង្ហាញពីភាពពិតនៃការចូលរួមរបស់ ឌុច នៅក្នុងឧក្រិដ្ឋកម្មដែលកើតឡើងនៅមន្ទីរស-២១ ហើយបានធ្វើកំណត់សម្គាល់ថាដីកាដំណោះស្រាយរួមមានអង្គហេតុសម្រាប់ចោទប្រកាន់ថាឌុចត្រូវទទួលខុសត្រូវនៅក្រោមសកម្មភាពឧក្រិដ្ឋកម្ម ។

នៅទីបញ្ចប់សហព្រះរាជអាជ្ញាបានអះអាថាសកម្មភាពឧក្រិដ្ឋកម្មស័ក្តិសមនឹងគ្រប់លក្ខខណ្ឌទាំង៤ដែលតម្រូវឲ្យយកមកប្រើប្រាស់នៅអង្គជំនុំជម្រះ ។ ទី១ វាមានចែងនៅក្នុងច្បាប់បង្កើតអង្គជំនុំជម្រះ ទី២ វាជាផ្នែកមួយនៃទំនៀមទម្លាប់ច្បាប់អន្តរជាតិនៅពេលដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងទី៣ជនត្រូវចោទអាចដឹងពីទម្រង់នៃការទទួលខុសត្រូវនៅពេលដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងនិងទី៤ជនត្រូវចោទអាចស្មានដឹងថាខ្លួនត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន ។ មេធាវីការពារក្តីមិនបានឆ្លើយតបនឹងបញ្ហាអស់រយៈពេលជាយូរ ប៉ុន្តែធ្វើកំណត់សម្គាល់ថា ឌុច បានបង្ហាញពីការចូលរួមរបស់ខ្លួននៅក្នុងឧក្រិដ្ឋកម្មរួមដែលកើតឡើងនៅមន្ទីរស-២១ហើយបញ្ហានោះត្រូវបានលើកឡើងជាលទ្ធភាពនៃការប្រើប្រាស់សហកម្មភាពឧក្រិដ្ឋកម្មរួមនៅអង្គជំនុំជម្រះដោយមិនរំលោភទៅលើការដាក់កំហិតប្រឆាំងនឹងច្បាប់ក្រោយអង្គហេតុ(ដែលស្គាល់ជាគោលការណ៍គ្មានបទល្មើសគ្មានច្បាប់ចែង) ជាពិសេសចំពោះសេចក្តីតែងនៃគោលការណ៍ដែលមានភាពអន់ថយ ។

សហកម្មឧក្រិដ្ឋកម្មរួមជាមធ្យោបាយចម្រូងចម្រាស់នៃការបង្កើតការទទួលខុសត្រូវនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ វាមានភាពខុសគ្នាបី ទីមួយ និងជាទម្រង់មូលដ្ឋានបំផុតសហកម្មឧក្រិដ្ឋកម្មរួម១) យកប្រើនៅពេលដែលអ្នកចូលរួមក្នុងឧក្រិដ្ឋកម្មធ្វើសកម្មភាពតាមមូលដ្ឋាននៃផែនការទូទៅនិងមានការប៉ុនប៉ងទូទៅ ។ ទីពីរប្តូទម្រង់ជា “ប្រព័ន្ធ”សហកម្មឧក្រិដ្ឋកម្មរួម ២) យកមកប្រើនៅពេលដែលក្រុមមនុស្សធ្វើសកម្មភាពតាមផែនការទូទៅដូចជាករណីដែលកងយោធាធ្វើប្រតិបត្តិការមន្ទីរឃុំឃាំង ។ ទីបីប្តូជាទម្រង់“ពង្រីក” សហកម្មឧក្រិដ្ឋកម្មរួម ៣) យកមកប្រើក្នុងស្ថានភាពដែលអ្នកចូលរួមម្នាក់ជាប់ពាក់ព័ន្ធនឹងសកម្មភាពដែលហួសពីផែនការទូទៅដែលជាផលវិបាកនៃគម្រោងនោះដែលអាចគិតទុកមុនបាន ។

ដោយមិនច្បាស់ថាភាពផ្សេងគ្នានៃគោលការណ៍នេះគឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិហើយថាតើអាចយកមកអនុវត្តន៍នៅអង្គជំនុំជម្រះបានឬអត់ អង្គបុរេជំនុំជម្រះបានស្នើឲ្យអ្នកជំនាញច្បាប់អន្តរជាតិនិងអង្គការបីគឺ លោកសាស្ត្រាចារ្យអេមបូសនៅមជ្ឈមណ្ឌលសិទ្ធិមនុស្សនិងលោកសាស្ត្រាចារ្យអេនថូនី

ខេស៊ីសនៅ*LegaPluralism* ដែលស្ថិតនៅសាកលវិទ្យាល័យ ម៉ាក់ហ្គីល និង សមាជិកផ្សេងទៀតនៃ *Journal of International Criminal Law* ដាក់សារណាដោយសង្ខេបស្តីពីបញ្ហានេះ ។ លោកសាស្ត្រាចារ្យអេមបូសអះអាងថាមានតែសហកម្មឧក្រិដ្ឋកម្មរួមគឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅអំឡុងពេលរបបខ្មែរក្រហមហើយសហកម្មឧក្រិដ្ឋកម្មរួម២អាចត្រូវបានចាត់ទុកជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិបច្ចុប្បន្នប្រសិនបើយកមកបកស្រាយឲ្យតូចចង្អៀត ។ ផ្ទុយពីសាស្ត្រាចារ្យ អេមបូស សាស្ត្រាចារ្យ ខេស៊ីស និងក្រុមការងារមកពីសាកលវិទ្យាល័យម៉ាក់ហ្គីលអះអាងថាទម្រង់នៃការទទួលខុសត្រូវដែលស្រដៀងគ្នាទៅនឹងសហកម្មឧក្រិដ្ឋកម្មរួម១,២និង៣គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅអំឡុងរបបខ្មែរក្រហម ហើយភាពខុសគ្នានៃសហកម្មឧក្រិដ្ឋកម្មរួមទាំងបីស័ក្តិសមនឹងទម្រង់នៃការទទួលខុសត្រូវនៅតុលាការ ។ ទោះជាយ៉ាងណាក៏ដោយក្រុមម៉ាក់ហ្គីលធ្វើកំណត់សម្គាល់ថាករណីច្បាប់ដែលគាំទ្រសហកម្មឧក្រិដ្ឋកម្មរួម៣មានសភាពខ្សោយជាងករណីច្បាប់ដែលគាំទ្រសហកម្មឧក្រិដ្ឋកម្មរួម១និង២ ។

ដោយជឿថាសេចក្តីសម្រេចឲ្យអនុវត្តន៍សហកម្មឧក្រិដ្ឋកម្មរួមនឹងផ្តល់ផលប្រយោជន៍ដល់សំណុំរឿងរបស់ខ្លួនមេធាវីការពារជនត្រូវចោទមានបំណងដាក់សារណាបន្ថែមពីទស្សនៈរបស់ខ្លួន ។ មេធាវីរបស់ អៀង សារី ជាអ្នកទីមួយដែលសុំដាក់សារណាទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួមដោយសំអាងលើមូលហេតុថា អៀង សារី ត្រូវបានចោទប្រកាន់ថាបានចូលរួមក្នុងរៀបចំផែនការឧក្រិដ្ឋកម្មទូទៅដូចជា ឌុច អាស្រ័យហេតុនេះ អៀង សារី អាចទទួលផលប្រយោជន៍ពីលទ្ធផលនៃបណ្តឹងឧទ្ធរណ៍ ។ អង្គបុរេជំនុំជម្រះបានបដិសេធនឹងបណ្តឹងឧទ្ធរណ៍ដោយអះអាងថា វិធានផ្ទៃក្នុងអនុញ្ញាតឲ្យតែភាគីធ្វើសារណាប៉ុណ្ណោះហើយការទទួលខុសត្រូវចំពោះសហកម្មឧក្រិដ្ឋកម្មរួមអាចនឹងមិនយកប្រើជាមួយ អៀង សារី ប្រសិនបើយកមកប្រើជាមួយ ឌុច រួចហើយនោះ ។ បន្ទាប់មកមេធាវីរបស់ អៀង សារី បានប្រឆាំងនឹងសាស្ត្រាចារ្យខេស៊ីសមិនឲ្យដាក់សារណាដោយសំអាងលើមូលហេតុថាគាត់បានសរសេរពីទស្សនៈដែលណែនាំឲ្យសហកម្មឧក្រិដ្ឋកម្មរួមគឺជាទម្រង់នៃការទទួលខុសត្រូវនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិខណៈពេលដែលលោកគឺជាមន្ត្រីយុត្តិធម៌នៅសាលាឧទ្ធរណ៍នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនៅឆ្នាំ១៩៩៩ ។ ដោយយោងទៅតាមសេចក្តីសម្រេចពីមុនអង្គបុរេយល់ថាមេធាវី អៀង សារី ខ្វះខាតជំហរចំពោះការស្នើនេះ ។ នៅទីបញ្ចប់ជនត្រូវចោទដែលនៅសល់ទាំង៤នាក់ បានស្នើធ្វើអន្តរាគមន៍ទាក់ទងនឹងបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម ។ អង្គបុរេជំនុំជម្រះនៅតែមិនយល់ស្របហើយបដិសេធនឹងសំណើនោះដោយសំអាងទៅលើសេចក្តីសម្រេចពីរពីមុនដែលទាក់ទងនឹងបញ្ហានេះ ។

អង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាកាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៨ ។ ដោយសារតែវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះមិនបានបញ្ជាក់ពីវិសាលភាពនៃអំណាចរបស់អង្គបុរេដើម្បីធ្វើសេចក្តីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍នៅក្នុងដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចលើកទីមួយដោយមួយចំនួនទាក់ទងនឹងបញ្ហានីតិវិធី ។ សេចក្តីសម្រេចបានលើកឡើងថាវិសាលភាពនៃការពិនិត្យដីកាដំណោះស្រាយរបស់អង្គបុរេជំនុំជម្រះមានកំណត់ចំពោះមូលហេតុដែលលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍អង្គបុរេជំនុំជម្រះមានអំណាចធ្វើសេចក្តីសម្រេចដោយឯករាជ្យទៅលើចរិតលក្ខណៈច្បាប់នៃបទល្មើសនិងទម្រង់នៃការទទួលខុសត្រូវដែលមាននៅក្នុងដីកាដំណោះស្រាយដោយមិនសំដៅទៅដីការបស់កយាល័យសហចៅក្រមស៊ើបអង្កេត ។ ជាងនេះទៅទៀតបញ្ហាដែលលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍មិនអាចយកមកដោះស្រាយនៅពេលកាត់ក្តីដូចដែលមេធាវីការពារក្តីបានអះអាងពីព្រោះបទដ្ឋានអន្តរជាតិនិងមាត្រា៣៥ថ្មីនៃច្បាប់អង្គជំនុំជម្រះតម្រូវថាជនត្រូវចោទត្រូវតែទទួលបានព័ត៌មានដោយសង្ខេបពីចរិតលក្ខណៈនិងមូលហេតុនៃការចោទប្រកាន់ ។

ចំពោះមូលហេតុទីមួយនៃបណ្តឹងឧទ្ធរណ៍គឺការខកខានមិនបានចោទប្រកាន់បទល្មើសជាតិអង្គបុរេជំនុំជម្រះលើកឡើងថាការសម្លាប់ដែលបានប៉ុនប៉ងទុកមុននិងការធ្វើទារុណកម្មដែលបទល្មើសជាតិគួរតែត្រូវបានរួមបញ្ចូលនៅក្នុងដីកាដំណោះស្រាយពីព្រោះបទល្មើសទាំងនោះរួមមានធាតុផ្សំដែលមិនមាននៅក្នុងអត្ត

ន័យនៃបទល្មើសអន្តរជាតិដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ហើយនៅក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិគេអាចចោទប្រកាន់បទល្មើសលើសពីមួយចំពោះអង្គហេតុនោះ ។

ចំពោះមូលហេតុទីពីរនៃបណ្តឹងឧទ្ធរណ៍គឺការខកខានមិនបានរួមបញ្ចូលសហកម្មឧក្រិដ្ឋមួយរួមជាទម្រង់នៃការទទួលខុសត្រូវ អង្គបុរេជំនុំជម្រះទុកចោលបញ្ហាលំបាកដែលថាតើគួរតែយកសហកម្មឧក្រិដ្ឋមួយរួមមកប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះឬអត់ ។ អង្គបុរេជំនុំជម្រះបែរជាលើកឡើងថាសហកម្មឧក្រិដ្ឋមួយរួមមិនអាចយកមកប្រើក្នុងករណីឌុចពីព្រោះឌុចមិនត្រូវបានជូនដំណឹងពីការចោទប្រកាន់ពីសហកម្មឧក្រិដ្ឋមួយរួមមុនពេលសហព្រះរាជអាជ្ញាដាក់ដីកាសន្និដ្ឋានស្ពាពរដោយយោងទៅតាមមាត្រា២១(១)(ឃ) ។

### ៤) អង្គហេតុនៃដីកាដំណោះស្រាយនិងការចោទ ប្រកាន់

ដីកាដំណោះស្រាយផ្តោតទៅលើតួនាទីរបស់ឌុចដែលជាមេបញ្ជាការមន្ទីរស-២១ត្រូវបានស្គាល់ជាគុកទួលស្លែងដែលមានទីតាំងនៅភ្នំពេញ ។ ដីកានោះបាននិយាយរៀបរាប់ពីសាច់រឿងប្រវត្តិសាស្ត្រនិងនយោបាយនៃរបបខ្មែរក្រហមដោយចាប់ផ្តើមពីការរំដោះភ្នំពេញនៅខែមេសាឆ្នាំ១៩៧៥ ។ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចគេចាប់ផ្តើមបេសកម្មដែលគាត់តែងឡើងដើម្បីជំនួសរចនាសម្ព័ន្ធសេដ្ឋកិច្ចនិងនយោបាយទៅជារចនាសម្ព័ន្ធបដិវត្តន៍ថ្មី ។ ការបញ្ជូនប្រជាជនពីភ្នំពេញទៅធ្វើការនៅក្នុងសហករណ៍កសិកម្មនៅជនបទនិងការចាប់ផ្តើមបង្កើតការអប់រំការសួរចម្លើយនិងមន្ទីរសន្តិសុខដែលគាត់តែងឡើងដើម្បីស្វែងរកនិងបោសសម្អាតអ្នកក្បត់បក្សត្រូវបានសម្រេចបានដោយជោគជ័យ ។ ខ្មែរក្រហមមានជម្លោះជាមួយវៀតណាមចាប់តាំងពីខ្លួនបានឡើងកាន់អំណាចនៅខែមេសា ឆ្នាំ១៩៧៥ រហូតដល់វៀតណាមវាយបែកភ្នំពេញនៅខែមករា ឆ្នាំ១៩៧៩ ។

យោងទៅតាមដីកាដំណោះស្រាយមន្ទីរស២១និងសម្ភារៈគ្រប់គ្រងនៅភ្នំពេញត្រូវបានបង្កើតឡើងដើម្បីពង្រីកគោលដៅនៃការបង្កើតសង្គមថ្មី ។ គោលបំណងរបស់គេគឺដើម្បីសម្លាប់សត្រូវបក្ស ។ អ្នកទោសដែលមកដល់មន្ទីរស-២១ត្រូវបានកំណត់ថាស្លាប់ទោះបីជាពួកគេត្រូវបានបញ្ជូនទៅទីនោះដោយសារទោសកំហុសក៏ដោយ ។ ដូចដែលពេលវេលាកន្លងទៅសមាជិកខ្មែរក្រហមដែលត្រូវបានសង្ស័យថាមិនស្មោះត្រង់ត្រូវបានបញ្ជូនទៅមន្ទីរស-២១ដើម្បីសួរចម្លើយនិងសម្លាប់មានចំនួនកាន់តែច្រើន ។ អ្នកទោសដែលបញ្ជូនទៅស-២១តែងតែត្រូវបានបញ្ជូនទៅទាំងគ្រួសារ ។ ឯកសារបង្ហាញឲ្យឃើញថាយ៉ាងហោចណាស់អ្នកទោសចំនួន១២.៣៨០នាក់ ដែលមានគ្រប់វ័យនិងភេទត្រូវបានដាប់ឃុំឃាំងនៅទួលស្លែងហើយមានតែប៉ុន្មាននាក់ប៉ុណ្ណោះដែលនៅរស់ ។ ដីកាដំណោះស្រាយបានសង្ខេបពីតួនាទីរបស់ ឌុច នៅក្នុងឋានានុក្រមខ្មែរក្រហមនិងនៅស-២១ព្រមទាំងការគ្រប់គ្រងរដ្ឋបាលនៅក្នុងគុករបស់ឌុច ។ ដីកានោះបានរៀបរាប់ពីវិធីសាស្ត្រដែលប្រើដើម្បីស្រង់យកចម្លើយសារភាពនៅស-២១ការប្រើប្រាស់ចម្លើយសារភាពទាំងនោះស្ថានភាពនៃការដាប់ឃុំឃាំងនិងនីតិវិធីនៃការសម្លាប់ ។ វាបង្កើតជាបទល្មើសស្របច្បាប់ដែលកើតឡើងពីអង្គហេតុទាំងនិងទម្រង់នៃការទទួលខុសត្រូវទាំងនេះ ។ ដីកាដំណោះស្រាយបានធ្វើការសន្និដ្ឋានដោយមានរៀបរាប់ពីចរិតលក្ខណៈរបស់ ឌុច រួមទាំងការផ្លាស់ប្តូរទៅប្រកាន់សាសនាគ្រិស្តរបស់គាត់នៅឆ្នាំ១៩៩៦និងការសហការរបស់គាត់ជាមួយការស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។

### ៥) ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ជនរងគ្រោះនៃរបបខ្មែរក្រហមប្រហែលជាចូលរួមដោយផ្ទាល់នៅក្នុងដំណើរការនីតិវិធីដោយតាំងនាមជាដើមបណ្តឹងរដ្ឋប្បវេណីដែលជាលក្ខណៈមួយដកស្រង់ចេញពីនីតិវិធីកម្ពុជា ប៉ុន្តែ មិនដែលត្រូវបានអនុម័តដោយតុលាការដែលប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីនឹងចូលរួមគ្រប់ដំណើរការសូម្បីតែអង្គបុរេដែលវិសាលភាពនៃការចោទប្រកាន់និងការការពារក្តីមានលក្ខណៈខុសគ្នា ។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៨រូបបានចូលរួមក្នុងដំណើរការនីតិវិធីប្រឆាំងនឹង ឌុច មុនពេលចេញដីកាដំណោះស្រាយ ។ មេធាវីសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីពីរបានដាក់សារណាអំពីបញ្ហាសហកម្មឧក្រិដ្ឋកម្មរួមមុនអង្គបុរេ ។ បច្ចុប្បន្នដើមបណ្តឹងរដ្ឋប្បវេណី៩៤រូបបានស្នើចូលរួមក្នុងដំណើរការកាត់ក្តី ។

**ទីលី នីម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ភ្នំពេញ ថ្ងៃទី ០៣ មីនា ២០០៩

ថ្ងៃនេះសហចៅក្រមស៊ើបអង្កេតបានចេញដីកាមួយ សម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ ( http://www.eccc.gov.kh/english/cabinet/courtDoc/248/D138_EN.pdf ) បន្ទាប់ពីមានការផ្សព្វផ្សាយដោយក្រុមមេធាវីការពារក្តី នូវឯកសារសម្ងាត់ នៅលើ គេហទំព័ររបស់ពួកគេ។

ជាការឆ្លើយតបទៅនឹងការរំលោភបំពានដ៏ច្បាស់លាស់និងជាដដែលៗ លើការណែនាំរបស់សហចៅក្រមស៊ើបអង្កេតនេះ សហចៅក្រមស៊ើបអង្កេតបានបញ្ជាឲ្យក្រុមមេធាវីការពារក្តីធ្វើការ បញ្ឈប់ជាបន្ទាន់នូវការផ្សព្វផ្សាយរាល់ឯកសារដែលពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ លើកលែងតែឯកសារ ដែលមានផ្សព្វផ្សាយរួចហើយនៅលើគេហទំព័ររបស់ អ.វ.ត.ក. និង ធ្វើការដកឯកសារទាំងនោះចេញពីគេហទំព័ររបស់ក្រុមមេធាវីការពារក្តីនោះវិញក្នុងរយៈពេល ៤៨ ម៉ោង បើមិនដូច្នោះទេ នឹងទទួលរងទណ្ឌកម្ម ដោយការប្រព្រឹត្តបទល្មើសថ្មីមួយទៀត។ ក្នុងពេលជាមួយគ្នានោះដែរ សហចៅក្រមស៊ើបអង្កេត ក៏បានបញ្ជូនអត្ថបទថតចម្លងនៃដីកាខាងលើទៅអង្គភាពវិជ្ជាជីវៈដែលពាក់ព័ន្ធ រួមទាំងអង្គភាពគាំពារការការពារក្តីដើម្បីធ្វើការពិចារណាលើវិធានការដែលត្រូវអនុវត្តបន្ត។

សេចក្តីសម្រេចនេះ ត្រូវបានធ្វើឡើងដោយយោងលើវិធាន ៥៦.១ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក. ដែលចែងថា *"ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី ការស៊ើបសួរមិនត្រូវធ្វើឡើងជា សាធារណៈឡើយ។ បុគ្គលទាំងអស់ ដែលចូលរួមក្នុងការស៊ើបសួរត្រូវរក្សាឲ្យបាននូវការសម្ងាត់។"* វិធាននេះត្រូវអនុវត្តចំពោះគ្រប់បុគ្គលទាំងអស់ ដែលចូលរួមក្នុងកិច្ចស៊ើបសួរ ជាពិសេសមេធាវីរបស់ ភាគីទាំងឡាយ និងលើគ្រប់ប្រភេទនៃភស្តុតាងទាំងអស់។ វិធានផ្ទៃក្នុង (វិធាន ៥៦.២) បញ្ជាក់បន្ថែមទៀតថា គឺមានតែសហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះ ដែលមានសមត្ថកិច្ចក្នុងការសម្រេចផ្សព្វផ្សាយ នូវព័ត៌មានដែលទាក់ទងនឹងកិច្ចស៊ើបសួរដែលកំពុងតែដំណើរការ ឬធ្វើការអនុញ្ញាតឲ្យប្រព័ន្ធផ្សព្វ ផ្សាយណាមួយ ឬតតិយជនណាមួយទទួលបាននូវព័ត៌មានទាក់ទងនឹងកិច្ចស៊ើបសួរ។ ក្នុងករណីដែល មិនគោរពលក្ខខណ្ឌនានា ដែលកំណត់ដោយចៅក្រម វិធាន ៣៥ ដល់ ៣៨ នឹងត្រូវយកមកអនុវត្ត។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

សហចៅក្រមស៊ើបអង្កេតសូមធ្វើការពន្យល់បកស្រាយអំពីហេតុផលនានា ដែលនាំឲ្យឈាន ទៅដល់ការចេញសេចក្តីសម្រេចនេះ។

មុននឹងមានការរៀបចំសវនាការជំនុំជម្រះជាសាធារណៈ គ្រប់នីតិវិធិតុលាការទាំងអស់ តែង តែចាប់ផ្តើមដោយដំណាក់កាលនៃការស៊ើបអង្កេត ដែលមានរយៈពេលវែង ឬខ្លីអាស្រ័យតាមទំហំ នៃការងារនេះ។ ចរិតលក្ខណៈសម្ងាត់នៃដំណាក់កាលនេះ មានសារៈសំខាន់ខ្លាំងណាស់ចំពោះ គុណភាពនៃដំណើរការតុលាការ ជាពិសេសដើម្បីធានាការការពារជីវិតឯកជនរបស់បុគ្គល ដែលមាន ឈ្មោះនៅក្នុងសំណុំរឿង និងការធានាអំពីគោលការណ៍សច្ចាធារណ៍និរទោស និងក៏ដើម្បីធានាប្រសិទ្ធិ ភាពនៃកិច្ចស៊ើបសួរផងដែរ។

សហចៅក្រមស៊ើបអង្កេត ដឹងថា ដំណាក់កាលនៃកិច្ចស៊ើបសួរជាសម្ងាត់ នឹងមិន អនុញ្ញាតឲ្យអ្នកសង្កេតការណ៍ខាងក្រៅតុលាការ អាចមានលទ្ធភាពយល់ដឹងឥតខ្ចោះអំពីដំណើរការទៅ មុខនៃនីតិវិធីនោះទេ។ ហេតុដូច្នេះហើយបានជាសហចៅក្រមស៊ើបអង្កេតព្យាយាមកំរិតថេរៈវេលានៃ កិច្ចស៊ើបសួរឲ្យខ្លីបំផុតតាម ដែលអាចធ្វើទៅបាន។ សហចៅក្រមស៊ើបអង្កេត រំលឹកថា នៅក្នុងករណី ឌុច កិច្ចស៊ើបសួរមានរយៈពេលមិនលើសពីមួយឆ្នាំទេ (ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ដែលមាន បញ្ជាក់យ៉ាងលំអិតអំពីបទចោទនានា ត្រូវបានផ្សព្វផ្សាយជាសាធារណៈ កាលពីថ្ងៃទី ០៨ សីហា ឆ្នាំ ២០០៨) ដែលនេះមិនអាចត្រូវបានចាត់ទុកថាយូរហួសហេតុពេកទេ បើពិនិត្យទៅលើភាពស្មុគស្មាញនៃសំណុំរឿង។ ដូចគ្នានេះដែរ សហចៅក្រមស៊ើបអង្កេត កំពុងព្យាយាមអស់លទ្ធភាព ដើម្បីឲ្យកិច្ចស៊ើបសួរ បច្ចុប្បន្ននៅក្នុងសំណុំរឿងទី ០២ ដំណើរការទៅដោយមិនមានភាពយឺតយ៉ាវ។

ដើម្បីបង្កើន តាមដែលអាចធ្វើទៅបាន នូវការយល់ដឹងជាសាធារណៈ សហចៅក្រមស៊ើប អង្កេត រំលឹកថា ជារៀងរាល់ខែ គេអាចរកបានព្រឹត្តិប័ត្រព័ត៌មាន ដែលបរិយាយជាសង្ខេបនូវសកម្ម ភាពរបស់អង្គភាពផ្សេងៗនៃ អ.វ.ត.ក. នៅលើគេហទំព័ររបស់ អ.វ.ត.ក. ដែលក្នុងនោះព័ត៌មានរបស់ ការិយាល័យសហចៅក្រម ស៊ើបអង្កេតមាននៅក្នុង៖ (http://www.eccc.gov.kh/english/publications.courtReport.aspx) ។ បន្ថែមលើសនេះ ទៀត ដើម្បីធានាបាននូវប្រសិទ្ធិភាពនៃគោលការណ៍ទាំងអស់ខាងលើ សហចៅក្រមស៊ើបអង្កេតនឹង ធ្វើការផ្សព្វផ្សាយ ឲ្យបានច្រើនជាងមុនអំពីសកម្មភាពនានារបស់ខ្លួន និងធ្វើការបោះផ្សាយឯកសារ ដែលទាក់ទងនឹងកិច្ចស៊ើបសួរក្នុងចំនួនច្រើនជាងមុនផងដែរ។

ជាចុងបញ្ចប់ សហចៅក្រមស៊ើបអង្កេត សូមធ្វើការរំលឹកថា ទោះបីជារាល់សេចក្តីសម្រេច របស់តុលាការ អាចត្រូវបានជំទាស់ដោយសារបណ្តឹងឧបាស្រ័យក៏ដោយ ក៏សេចក្តីសម្រេចទាំងនេះ មិនអាចត្រូវបានមិនគោរព ដោយមិនអើពើនោះដែរ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

## សេចក្តីប្រកាសព័ត៌មានបិទកិច្ចប្រជុំពេញអង្គលើកទី៥ របស់ចៅក្រម និងសហព្រះរាជអាជ្ញា ថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៩

ចាប់ពីថ្ងៃច័ន្ទទី២ ដល់ ថ្ងៃសុក្រទី៦ ខែមីនា ឆ្នាំ២០០៩ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានរៀបចំកិច្ចប្រជុំពេញអង្គលើកទី៥របស់ខ្លួន នៅសណ្ឋាគារ កាំបូឌីយ៉ាណា នារាជធានីភ្នំពេញ។

កិច្ចប្រជុំពេញអង្គនេះ មានគោលបំណងសំខាន់ដើម្បីពិភាក្សាសំណើវិសោធនកម្មលើវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា ចំនួន៣០ វិធាន។ វិធាន ចំនួន ២៧ ត្រូវបានអនុម័ត។ ភាគច្រើននៃវិសោធនកម្មទាំងនេះ គឺឆ្លុះបញ្ចាំងពីកិច្ចខំប្រឹងប្រែងជួយសម្រួលឱ្យរលូន ឬការធ្វើឱ្យប្រសើរឡើងនូវបញ្ហាបច្ចេកទេសមួយចំនួនតូចផងដែរ។

វិសោធនកម្មទាំងនេះត្រូវបានរៀបចំក្នុងគោលបំណងបង្កើនប្រសិទ្ធិភាព និងពន្លឿននីតិវិធីចំពោះមុខអង្គជំនុំជម្រះទាំងអស់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ រួមមាន៖

- ការពន្លឿនការផ្តល់នីតិសម្បទាដល់អ្នកស៊ើបអង្កេត
- ការពន្លឿននីតិវិធីសម្រាប់កោះហៅសាក្សី កាលពីមុនមានរយៈពេលអប្បបរមា សម្រាប់ការកោះហៅ និងបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះមានចំនួន៥ថ្ងៃ។
- ការសម្រេចថា ពេលចៅក្រមបម្រុងមានជម្ងឺ ឬពុំអាចចូលរួមក្នុងកិច្ចដំណើរការ នីតិវិធីបាន គឺមិនអាចរារាំងដល់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំ ជម្រះទេ។
- ការបញ្ជាក់ឱ្យច្បាស់អំពីអំណាចរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងសាក្សី ឬ ភស្តុតាងបន្ថែម។
- ការដកចេញនូវលក្ខខណ្ឌតម្រូវដែលថាសាលក្រមស្ថាបពរត្រូវចេញក្នុងរយៈ ពេល៩០ថ្ងៃ គិតចាប់ពីថ្ងៃសវនាការចុងក្រោយ ដោយពិចារណាដល់ភាពស្មុគស្មាញ និងទំហំនៃរឿងក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។
- ការបញ្ជាក់ឱ្យច្បាស់ថានៅពេលណាភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបាន តំណាងដោយមេធាវី គឺមេធាវីជាអ្នកត្រូវធ្វើសារណាតាមផ្លូវច្បាប់នៅចំពោះមុខអង្គជំនុំជម្រះ មិនមែនភាគីដើមបណ្តឹងរដ្ឋប្បវេណីខ្លួនឯងទេ។ វិសោធនកម្មនេះ ពុំបានកម្រិតសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទេ ប៉ុន្តែបានកែប្រែរបៀបនៃការអនុវត្តសិទ្ធិទាំងនេះ ដោយហេតុថា នៅចំពោះមុខកិច្ចដំណើរការនីតិវិធីនៃអង្គជំនុំជម្រះវិសាមញ្ញ

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

ក្នុងតុលាការកម្ពុជា មានភាគីដើមបណ្តឹងរដ្ឋប្បវេណីច្រើន សន្ទឹកសន្ធាប់ និងថាការជំនុំជម្រះនឹងមិនបញ្ចប់បានលឿនទេ ប្រសិនបើភាគីដើមរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឱ្យធ្វើអន្តរាគមន៍នៅគ្រប់រឿងនៅគ្រប់តំណាក់កាលនៃកិច្ចដំណើរការនីតិវិធីទាំងអស់នោះ។

- វិសោធនកម្មទាំងនេះមិនអនុវត្តចំពោះករណីដែលភាគីដើមបណ្តឹងរដ្ឋប្បវេណី កំពុងត្រូវបានសួរ និងពុំរារាំងភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការឆ្លើយសំណួរ ដែលអង្គជំនុំជម្រះសួរគាត់នោះទេ។
- ការបញ្ជាក់ឱ្យបានច្បាស់ និងសម្រួលបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះ សាលាកំពូល។ វិសោធនកម្មទាំងនេះ ត្រូវបានធ្វើឡើងនៅមុនពេលអង្គ ជំនុំជម្រះសាលាកំពូលចាប់ផ្តើមបំពេញមុខងាររបស់ខ្លួន។ ការរៀបចំដូច្នេះគឺ ដើម្បីធានាឱ្យបាននូវភាពត្រៀមខ្លួនរួចរាល់ជាមុននៃអង្គជំនុំជម្រះសាលាកំពូល ដើម្បីឱ្យអង្គជំនុំជម្រះនេះអាចគ្រប់គ្រងទំហំនៃសំណុំរឿងរបស់ខ្លួនបាន។

នៅថ្ងៃចុងក្រោយនៃកិច្ចប្រជុំពេញអង្គ ប្រធានស្តីទីនៃការិយាល័យរដ្ឋបាល និងមន្ត្រី ជាន់ខ្ពស់ផ្នែកគ្រប់គ្រងតុលាការ ព្រមទាំងប្រធានអង្គភាពជនរងគ្រោះ បានធ្វើបទឧទ្ទេសនាមគ្រួសៗជូនកិច្ចប្រជុំពេញអង្គអំពីបញ្ហាប្រឈមជាច្រើននៃការគ្រប់គ្រងការ ជំនុំជម្រះក្តី ដែលបញ្ហាទាំងនេះបណ្តាលមកពីការចូលរួមពីជនរងគ្រោះដែលមានចំនួនច្រើន នៅក្នុងកិច្ចដំណើរការនីតិវិធីនៃអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា។ ការចូលរួមរបស់ជនរងគ្រោះគឺជាលក្ខណៈពិសេសមួយនៃកិច្ចដំណើរការនីតិវិធីនៃ អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា។ ការអនុវត្តដែលពាក់ព័ន្ធនឹងការចូលរួមរបស់ ជនរងគ្រោះនេះ កំពុងត្រូវបានឃ្លាំមើលយ៉ាងជិតដិតបំផុត ដោយសាលាក្តីអន្តរជាតិនានា ជាពិសេសគឺតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលមានលក្ខន្តិកៈនិងវិធានស្រដៀង គ្នានឹងវិធានរបស់អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា។ ប្រធានផ្នែកកិច្ចការ សាធារណៈបានធ្វើបទបង្ហាញជូនកិច្ចប្រជុំពេញអង្គអំពីសកម្មភាពចុះផ្សព្វផ្សាយដល់ មូលដ្ឋានរបស់ផ្នែកកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ផងដែរ។



*ប្រជាជនចូលរួមស្តាប់ការពន្យល់របស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាអំពីដំណើរការរបស់តុលាការខ្មែរក្រហម*

# គម្រោងដំណើរការកាត់សេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញសម្រាប់ ឆ្នាំ២០០៨

*ពេញមួយឆ្នាំដំបូងនៃដំណើររឿងក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញបានបញ្ចប់ ។ នេះជាឆ្នាំប្រកបដោយភាពមមាញឹកដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញមុខជាលើកដំបូងនៅក្នុងដំណើរការកាត់សេចក្តីក្រោមច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ អង្គបុរេជំនុំជម្រះបានផ្តល់ភាពលម្អិតយ៉ាងច្រើនដល់អង្គច្បាប់ដែលគ្របដណ្តប់លើនីតិវិធីទំនាក់ទំនងរវាងអង្គភាពតុលាការនិងសិទ្ធិរបស់ជនត្រូវចោទព្រមទាំងមនុស្សម្នាក់ក្នុងចំណោមប្រាំនាក់ដែលបច្ចុប្បន្នស្ថិតនៅក្នុងការឃុំខ្លួនត្រូវបានជំនុំជម្រះទោស ។*

*ខ្លឹមសារសង្ខេបនេះនឹងពិពណ៌នាត្រួសលើវិធានឆ្នាំ២០០៨របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនិងអង្គបុរេជំនុំជម្រះ ។ សេចក្តីសម្រេចនិងដីកាទាំងឡាយត្រូវបានរៀបចំតាមប្រភេទ ។ នៅក្នុងអង្គភាពនីមួយៗ សេចក្តីសម្រេចនិងដីកាត្រូវបានរាយតាមលំដាប់កាលបរិច្ឆេទចាប់តាំងពីដើមបំផុតរហូតដល់ពេលថ្មីៗបំផុត ។*

*សេចក្តីសម្រេចចំពោះការបកប្រែភាសាដែលអនុវត្តបានចំពោះជនត្រូវចោទនិងជនត្រូវបានចោទប្រកាន់ទាំងអស់ ។*

*១) ការិយាល័យសហចៅក្រមស៊ើបអង្កេត(ក.ស.ច.ក) ដីកាស្តីពីសិទ្ធិនិងកាតព្វកិច្ចបកប្រែភាសា(ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨)ក្នុងគោលបំណងដោះស្រាយបញ្ហាបកប្រែភាសាដែលបានប៉ះពាល់ដល់ដំណើរការកាត់សេចក្តីជំទាស់នឹងជនត្រូវចោទទាំងប្រាំនាក់ការិយាល័យសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថាជនត្រូវចោទមានសិទ្ធិទទួលបានការបកប្រែជាភាសាខ្មែរនូវរាល់ដីកាចោទប្រកាន់នានាព្រមទាំងដីកាបញ្ជូនរឿងឲ្យស៊ើបសួរបឋមនិងចុងក្រោយរបស់សហព្រះរាជអាជ្ញា ។ រាល់សេចក្តីសម្រេចចិត្តនិងដីកាទាំងអស់របស់សាលាក្តីនឹងត្រូវបកប្រែជា ភាសាខ្មែរ អង់គ្លេសនិង បារាំង ដែលភាសាទាំងបីប្រើប្រាស់នៅក្នុងតុលាការ ។ គ្រប់ឯកសារទាំងអស់ត្រូវតែជាភាសាខ្មែរនិងភាសាមួយក្នុងចំណោមភាសាប្រើប្រាស់ចំនួនពីរទៀត ។ ការបកប្រែភាសាចាំបាច់ផ្សេងៗទៀតនៅក្នុងសំណុំរឿងក្តីត្រូវតែមានការសហការគ្នារវាងអ្នកបកប្រែរបស់សេវាកម្មគ្រប់គ្រងសំណុំរឿងនិងបុគ្គលិកគាំទ្រការការពារក្តី ។*

*២) ឥឡូវនេះអង្គបុរេជំនុំជម្រះកំពុងពិចារណាលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាស្តីពីសិទ្ធិបកប្រែភាសា ។ សវនាការផ្ទាល់មាត់ត្រូវបានធ្វើឡើងនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៨ទោះបីជាមិនមានសេចក្តីសម្រេចណាមួយអាចសម្រេចបានក៏ដោយ ។ ខៀវ សំផន បានផ្តល់ទឡ្ហីករណ៍ថាការខកខានមិនបានបកប្រែឯកសារនៅក្នុងសំណុំរឿងក្តីទាំងអស់ទៅជាភាសាបារាំងដែលជាភាសារបស់មេធាវីអន្តរជាតិរបស់គាត់ ផ្ទុយពីសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ ។ គាត់ក៏បានបញ្ជាក់ដែរថាគាត់គ្មានកាតព្វកិច្ចក្នុងការសហការជាមួយសេវាកម្មគ្រប់គ្រងការបកប្រែដើម្បីបកប្រែឯកសារចាំបាច់ដោយសារតែមួយផ្នែកនោះគឺការបញ្ជូនបញ្ជីឯកសារដើម្បីបកប្រែរំលោភទៅលើការកិច្ចរបស់មេធាវីក្នុងការរក្សាការសម្ងាត់ ។ សូមចុចត្រង់នេះដើម្បីអានរបាយការណ៍ត្រួតពិនិត្យដែលពិពណ៌នាអំពីតួនាទីរបស់ភាគីនីមួយៗ ។*

## ***សេចក្តីសម្រេចរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលអនុវត្តន៍ចំពោះដំណើការកាត់សេចក្តីទាំងអស់***

*១) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចស្តីពីការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបណ្តឹងឧទ្ធរណ៍ឃុំខ្លួនបណ្តោះអាសន្ន (នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨) យោងតាមវិធានផ្ទៃក្នុង (២៣(១) និងទិសដៅផ្សះផ្សាជាតិដែលវត្តមានកត្តាទាំងនេះត្រូវសម្រេចបាននោះភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមនៅក្នុងដំណើរការកាត់សេចក្តីបទឧក្រិដ្ឋកម្មទាំងអស់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) ។*

*២) អង្គបុរេជំនុំជម្រះទិសដៅស្តីពីដីកាបញ្ជូនរឿងឲ្យស៊ើបសួរផ្ទាល់មាត់របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងសវនាការលើបណ្តឹងឧទ្ធរណ៍ឃុំខ្លួនបណ្តោះអាសន្ន(ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨) ដោយទាមទារថាដីកាបញ្ជូនរឿងឲ្យស៊ើបសួរផ្ទាល់*

មាត់របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើឡើងដោយមេធាវី អនុលោមតាមវិធានផ្ទៃក្នុងទី៧៧(១០)(សូមមើលលេខ៤និង៥ខាងក្រោម) ។

៣) អង្គបុរេជំនុំជម្រះសេចក្តីសម្រេចលើសំណើរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំពោះសេវាកម្មបកប្រែភាសា(ថ្ងៃទី១៩ខែមិថុនាឆ្នាំ២០០៨) ដោយយល់ឃើញថាសំណើរបស់សហមេធាវីបរទេសរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះសេវាកម្មបកប្រែមិនអាចអនុញ្ញាតដោយសារមានលក្ខណៈអរូបិយខ្លាំងពេក ហើយខកខានមិនបានបញ្ជាក់ឲ្យមានច្បាស់អំពីសេចក្តីត្រូវការបកប្រែថាតើការប៉ុនប៉ងត្រូវបានធ្វើឡើងដើម្បីធានាឲ្យមានសេវាកម្មបកប្រែភាសាមកពីអង្គភាពផ្សេងៗរបស់តុលាការដែរឬអត់ ហើយថាតើអង្គបុរេជំនុំជម្រះជាអង្គភាពដ៏ត្រឹមត្រូវក្នុងការកាត់សេចក្តីលើបញ្ហានេះឬអត់ ។

៤ (អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចលើបញ្ហាបឋមលើកឡើងដោយមេធាវីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី(ថ្ងៃទី១ខែកក្កដាឆ្នាំ២០០៨) ដោយបានគូសបញ្ជាក់នៅក្នុងការពិភាក្សាខាងដើមដែលថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាមានពេលសម្រាប់ការផ្តល់ទឡ្ហីករណ៍ផ្ទាល់មាត់តិចជាងព្រះរាជអាជ្ញានិងមេធាវីការពារក្តី ហើយដោយបានបដិសេធចោលនូវសំណើរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងដោយមេធាវីមួយរូបសម្រាប់បុគ្គលម្នាក់ៗ(សូមមើលលេខ២ខាងលើ) ។

៥) អង្គបុរេជំនុំជម្រះ--ទម្រង់ជាលាយលក្ខណ៍អក្សរនៃការពិភាក្សាផ្ទាល់មាត់ស្តីពីសំណើរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីនិយាយនៅក្នុងអង្គបុរេជំនុំជម្រះជាបុគ្គល(ថ្ងៃទី៣ខែកក្កដា ឆ្នាំ២០០៨) ដោយបានបដិសេធសំណើររបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលបានបណ្តេញមេធាវីរបស់គាត់ចេញដើមនិយាយនៅក្នុងសាលាក្តីដោយខ្លួនឯងដោយឈរលើមូលដ្ឋានដែលថាវិធានផ្ទៃក្នុងទី៧៧(១០) បានចែងថាមានតែមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះអាចធ្វើការអធ្កេតផ្ទាល់មាត់ក្នុងអំឡុងពេលមានសវនាការរបស់អង្គបុរេជំនុំជម្រះ ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការពិនិត្យពិចារណាសាចុះសារឡើង(សូមមើលេខ២និង៤ខាងលើ) ។

៦) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចលើសំណើរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំពោះវិធានការការពារ(ថ្ងៃទី៨ខែកក្កដាឆ្នាំ២០០៨) ដោយផ្តល់សំណើមកពីភាគីដើមបណ្តឹងរដ្ឋប្បវេណីឲ្យរក្សាឈ្មោះជាការសម្ងាត់) ។

៧) អង្គបុរេជំនុំជម្រះ--សេចក្តីណែនាំបន្ថែមទាក់ទងទៅនឹងពាក្យសុំឲ្យមានការពិចារណាសារឡើងវិញចំពោះសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីនិយាយទៅកាន់អង្គជំនុំជម្រះ(ថ្ងៃទី១៤ខែកក្កដា ឆ្នាំ២០០៨) ដោយអនុញ្ញាតឲ្យភាគីដើមបណ្តឹងរប្បវេណីនិងភាគីផ្សេងៗទៀតធ្វើការឆ្លើយតបតាមសំណុំបែបបទមានការពិនិត្យពិចារណាសារឡើងវិញ) ។

៨) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចស្តីពីសំណុំបែបបទឲ្យមានការពិចារណាឡើងវិញលើសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីនិយាយនៅក្នុងអង្គបុរេជំនុំជម្រះផ្ទាល់ខ្លួន(ថ្ងៃទី២៨ខែសីហាឆ្នាំ២០០៨)(ដិសេធសំណុំបែបបទ) ។

៩) អង្គបុរេជំនុំជម្រះ-សេចក្តីណែនាំស្តីអំពីសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលមិនធ្លាប់មានពីមុនមកក្នុងការនិយាយនៅក្នុងអង្គបុរេជំនុំជម្រះជាបុគ្គល(ថ្ងៃទី២៩ខែសីហាឆ្នាំ២០០៨) ជាទូទៅមានតែមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការប្តឹងនិងនិយាយនៅក្នុងតុលាការ(សូមមើលលេខ២និង៥ខាងលើ) ។ ទោះជាយ៉ាងណាក៏ដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលមិនធ្លាប់មានពីមុនមកខាងផ្លូវច្បាប់អាចនិយាយនៅក្នុងអង្គបុរេជំនុំជម្រះជាបុគ្គលប្រសិនបើផលប្រយោជន៍របស់ខ្លួនមានភាពខុសគ្នាពីផលប្រយោជន៍ទាំងឡាយរបស់ព្រះរាជអាជ្ញាជរាបណាអ្នកទាំងនោះធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរដែលពន្យល់អំពីខ្លឹមសារនិងភាពពាក់ព័ន្ធនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរដូចបានស្នើឡើងឲ្យបានយ៉ាងហោចណាស់ក៏១០ថ្ងៃដែរមុនពេលសវនាការ ។

១០) អង្គបុរេជំនុំជម្រះ-ទម្រង់ជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចផ្ទាល់មាត់ស្តីពីពាក្យសុំរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំពោះដីកាបញ្ជូនរឿងឲ្យស៊ើបសួរនៅក្នុងបណ្តឹងឧទ្ធរណ៍សម្រាប់ការបកប្រែភាសា(ថ្ងៃទី៥ខែធ្នូឆ្នាំ ២០០៨) ដោយសារតែមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនបានបញ្ជាក់ជាផ្លូវការដល់អង្គបុរេជំនុំជម្រះស្តីពីគោលបំណងក្នុងការបង្ហាញទឡ្ហីករណ៍ផ្ទាល់

មាត់១០ថ្ងៃមុនពេលសវនាការដូចបានតម្រូវនៅក្នុង«សេចក្តីណែនាំស្តីអំពីសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលមិនធ្លាប់មានពីមុនមកក្នុងការនិយាយនៅក្នុងអង្គបុរេជំនុំជម្រះជាបុគ្គល(ថ្ងៃទី២៩ខែសីហា ឆ្នាំ២០០៨) ពាក្យសុំរបស់ខ្លួនត្រូវបដិសេធ ។

**កាំង ហ្គិចអ៊ាវ «ឌុច»**


កាំង ហ្គិចអ៊ាវ ហៅ ឌុច

១) ការិយាល័យសហចៅក្រមស៊ើបអង្កេត(ក.ស.ច.ក)ដីកាស្តីពីសំណើររបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំពោះសកម្មភាពស៊ើបអង្កេត(ថ្ងៃទី៤ខែមិថុនា ឆ្នាំ២០០៨)សហចៅក្រមស៊ើបអង្កេតបានចេញដីកាលើសំណើរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការអនុវត្តន៍សកម្មភាពស៊ើបអង្កេតមួយចំនួនអនុលោមតាមមាត្រា៥៥(១០) ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំយក?ឱកាសដើម្បីសម្ភាស ឌុច ទាក់ទងទៅនឹងការសម្លាប់សាច់ញាតិដែលត្រូវបានសម្លាប់នៅក្នុងមន្ទីរស-២១ ។ ខណៈដែលសំណើនេះមានភាព«ស្របច្បាប់» ដោយសារតែសំណុំរឿងក្តីនេះត្រូវប្រញាប់បញ្ជូនទៅកាន់សហព្រះរាជអាជ្ញាដើម្បីឲ្យទាន់កាលបរិច្ឆេទសំណើនេះត្រូវបដិសេធដើម្បីជាប្រយោជន៍ដល់បែបបទរដ្ឋបាលរបស់តុលាការ ។

២) ក.ស.ច.ក-ដីកាទាក់ទងទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាចំពោះសកម្មភាពស៊ើបអង្កេត(ថ្ងៃទី៤ខែមិថុនាឆ្នាំ២០០៨)សហព្រះរាជអាជ្ញាស្នើឡើងថា(ក.ស.ច.ក) ស៊ើបអង្កេត ឌុចពីបទឧក្រិដ្ឋកម្មក្នុងស្រុករបស់ប្រទេសកម្ពុជាចំពោះអំពើមនុស្សឃាតនិងការធ្វើទារុណកម្ម ។ ដោយសារតែសមាសភាពនៃការចោទប្រកាន់ដូចបានស្នើឡើងត្រូវបានស៊ើបអង្កេតរួចហើយដែលជាផ្នែកមួយនៃការស៊ើបអង្កេតខាងផ្លូវច្បាប់និងដោយសារតែនិយមន័យខាងផ្លូវច្បាប់សម្រាប់ដីកាចោទប្រកាន់ត្រូវបានបង្កើតឡើងតាមរយៈដីកាបញ្ជូនរឿងដែលមិនទាន់បានចេញនៅឡើយសំណើនេះត្រូវបដិសេធ ។ ដីកាបញ្ជូនរឿងមិនបានចោទប្រកាន់ឌុចពីបទឧក្រិដ្ឋកម្មជាតិនោះទេ ។ ព្រះរាជអាជ្ញាបានធ្វើបណ្តឹងឧទ្ធរណ៍ទៅកាន់អង្គបុរេជំនុំជម្រះហើយបានឈ្នះលើបណ្តឹងនេះ ។ ភាពខុសប្លែកគ្នាជាក់លាក់នៃបទឧក្រិដ្ឋកម្មជាតិស្តីពីអំពើមនុស្សឃាតនិងទារុណកម្មត្រូវបានបញ្ចូលទៅក្នុងដីកាចោទប្រកាន់(សូមមើលលេខ៣និង៨ខាងក្រោម) ។

៣) ក.ស.ច.ក-ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឌុច(ថ្ងៃទី៨ខែសីហាឆ្នាំ២០០៨)ក.ស.ច.កបានចេញដីបញ្ជូនរឿងដែលពិពណ៌នាអំពីអំពើឃោរឃៅប្រព្រឹត្តនៅគុកទួលស្លែងនិងតួនាទីរបស់ឌុចនៅក្នុងកន្លែងនោះ ។

ក) ដីកាបញ្ជូនរឿងបានចោទប្រកាន់ឌុចពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះការដាក់ឃុំឃាំងការធ្វើជាទាសករទារុណកម្ម រំលោភ សម្លាប់ សម្លាប់បំផុតពូជការធ្វើទុកបុកម្នេញនិងអំពើអមនុស្សធម៌ផ្សេងៗទៀត ។ ដីកាបញ្ជូនរឿងក៏ចោទប្រកាន់ឌុចពីបទរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវពោលគឺការបង្ខាំងជនស៊ីវិលដោយខុសច្បាប់ដកហូតសិទ្ធិតាមអំពើចិត្តសម្រាប់ការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌បង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរតាមអំពើចិត្តការធ្វើទារុណកម្មនិងការប្រព្រឹត្តដោយអមនុស្សធម៌ការសម្លាប់តាមអំពើចិត្ត ។ សេចក្តីសម្រេចរបស់ ក.ស.ច.ក ដែលមិនចោទប្រកាន់បទឧក្រិដ្ឋកម្មជាតិស្តីពីការធ្វើទារុណកម្មនិងមនុស្សឃាតត្រូវបានទាមទារនៅក្នុងបណ្តឹងឧទ្ធរណ៍(សូមមើលលេខ៧ខាងក្រោម) ។

ខ) ទម្រង់នៃការទទួលខុសត្រូវរួមមានការប្រព្រឹត្តការចេញបញ្ជាការទទួលខុសត្រូវលើការបញ្ជាការរៀបចំគម្រោងការញុះញង់និងការជួយនិងបង្កលក្ខណៈងាយស្រួល ។ សេចក្តីសម្រេចរបស់ ក.ស.ច.កមិនចោទប្រកាន់ចំពោះការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមត្រូវបានទាមទារនៅក្នុងបណ្តឹងឧទ្ធរណ៍សូម(មើលលេខ៨ខាងក្រោម) ។

គ) ដីកាបញ្ជូនរឿងបានចាត់ទុក ឌុចថាមានការសោកស្តាយ

និងប្រកបដោយកិច្ចសហការ ។

៤) អង្គបុរេជំនុំជម្រះ--កំណត់សម្គាល់របស់សាធារណជនស្តីពីការបដិសេធរបស់ចៅក្រមន័យថុល(ថ្ងៃទី១៣ខែតុលាឆ្នាំ២០០៨) ចៅក្រមន័យថុលបានរួចផុតពីការពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអនុលោមតាមវិធានផ្ទៃក្នុងទី៣៤(១) ប្រហែលជាដោយសារគាត់បានចូលរួមនៅក្នុងដំណើរការរឿងក្តីមុនពេលមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលទាក់ទងនឹងឌុចក្នុងឋានៈគាត់ជាចៅក្រមរបស់តុលាការយោធា ។ ថុលត្រូវបានជំនួសដោយចៅក្រមបម្រុងឈ្មោះប៉ែន ពេជ្រសាលី ។

៥) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចស្តីពីសំណើរបស់អៀងសារីក្នុងការដាក់ដីកាបញ្ជូនរឿងឲ្យស៊ើបសួរស្តីពីបញ្ហាសម្ព័ន្ធឧក្រិដ្ឋកម្មរួមនៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាចេញពីដីកាបញ្ជូនរឿងនៃសំណុំឯកសាររឿងក្តីលេខ០០១(ថ្ងៃទី៦ខែតុលាឆ្នាំ២០០៨) សំណើរបស់អៀងសារីក្នុងការដាក់ដីកាបញ្ជូនរឿងឲ្យស៊ើបសួរស្តីពីបញ្ហាសហកម្មឧក្រិដ្ឋកម្មរួមត្រូវបដិសេធដោយសារវិធានផ្ទៃក្នុងមិនអនុញ្ញាតឲ្យភាគីទីបីធ្វើអន្តរាគមនិងដោយសារតែគាត់នឹងមានឱកាសតវ៉ាលើសំណុំបែបបទសំខាន់ៗរបស់សហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងសំណុំរឿងក្តីរបស់គាត់ ។

៦) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចស្តីពីញត្តិមិនអនុញ្ញាតឲ្យមានអ្នកជូនយោបល់តុលាការ(ថ្ងៃទី១៨ខែតុលាឆ្នាំ២០០៨) ញត្តិរបស់អៀងសារីមិនអនុញ្ញាតអានតូនីញ៉ូ កាសេសនិងសមាជិកមួយចំនួនទៀតមកពីក្រុមប្រឹក្សានិពន្ធនាយកនិងគណៈកម្មាការនិពន្ធនាយកនៃសារព័ត៌មានអន្តរជាតិស្តីពីយុត្តិធម៌ឧក្រិដ្ឋកម្មឲ្យធ្វើជាអ្នកជូនយោបល់តុលាការស្តីពីបញ្ហាសហកម្មឧក្រិដ្ឋកម្មរួមត្រូវបានបដិសេធ ដោយឈរលើមូលដ្ឋានថាគាត់មិនអាចឈរធ្វើអន្តរាគមន៍នៅដំណើរការកាត់សេចក្តីដែលមិនពាក់ព័ន្ធនឹងគាត់ ។

៧) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចស្តីពីសំណើសុំការពាររួមគ្នាដើម្បីធ្វើអន្តរាគមន៍លើបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម (ថ្ងៃទី៥ខែវិច្ឆិកាឆ្នាំ២០០៨) អង្គបុរេជំនុំជម្រះបានបដិសេធសំណើធ្វើឡើងដោយសហមេធាវីរបស់ អៀងធិរិទ្ធ, នួនជា,និងខៀវសំផនដែលសុំឲ្យបើកសវនាការលើបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម ។ អ្នកទាំងអស់ផ្តល់ទឡ្ហីករណ៍ថាខ្លួនមានផលប្រយោជន៍ផ្ទាល់ក្នុងបញ្ហានេះហើយសូម្បីតែគ្មានសិទ្ធិធ្វើអន្តរាគមន៍ក៏ដោយសំណើរបស់ខ្លួនសុំឲ្យមានសវនាការគួរតែត្រូវបានផ្តល់ឲ្យដោយឈរលើមូលដ្ឋានសេដ្ឋកិច្ចខាងតុលាការនិងសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ។ អង្គបុរេជំនុំជម្រះបដិសេធសំណើនេះដោយដកស្រង់ពីការបដិសេធខាងដើមចំពោះសំណើរបស់អៀងសារីក្នុងការធ្វើអន្តរាគមន៍លើបញ្ហានេះ(សូមមើលលេខ៥និង៦ខាងលើ) ។

៨) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាបញ្ជូនរឿង(ថ្ងៃទី៥ខែធ្នូឆ្នាំ២០០៨) សហព្រះរាជអាជ្ញាបានចោទប្រកាន់កំហុសខាងផ្លូវច្បាប់ពីរចំណុចក្នុងដីកាបញ្ជូនរឿងគឺ(១) ការខកខានមិនបានចោទប្រកាន់ឌុចពីបទឧក្រិដ្ឋកម្មជាតិស្តីពីការសម្លាប់និងការធ្វើទារុណកម្មនិង (២) ការខកខានមិនបានចោទប្រកាន់ឌុច ពីបទប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដែលកើតឡើងនៅមន្ទីរស-២១តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ។ អានតូនីញ៉ូ កាសេស នៃមជ្ឈមណ្ឌលម៉ាកហ្គិល ដើម្បីសិទ្ធិមនុស្សនិងពហុនិយមខាងផ្លូវច្បាប់ព្រមទាំងបណ្ឌិតខេអាំបុសបានដាក់ជូនខ្ទឹមសារសង្ខេបរបស់អ្នកផ្តល់យោបល់តុលាការស្តីពីបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម ។

ក) វិសាលភាពពិនិត្យមើលឡើងវិញត្រូវបានកម្រិតនៅត្រឹមហេតុផលដូចលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍

ខ) អង្គបុរេជំនុំជម្រះមានសិទ្ធិអំណាចសម្រេចដោយឯករាជ្យតាមបែបផែនផ្លូវច្បាប់លើបទល្មើសនិងគំរូនៃការទទួលខុសត្រូវនៅក្នុងដីកាបញ្ជូនរឿង ។

គ) ដោយសារតែបទដ្ឋានអន្តរជាតិតម្រូវ ឲ្យមានភាពជាក់លាក់នៅក្នុងដីកាចោទប្រកាន់និងមាត្រា៣៥(ថ្មី) នៃច្បាប់របស់អ.វ.ត.កចែងថាជនត្រូវចោទត្រូវជូនដំណឹងលម្អិតស្តីពីសារជាតិនិងមូលហេតុនៃការចោទប្រកាន់ហេតុផលចំពោះបណ្តឹងឧទ្ធរណ៍មិនអាចសម្រេចបានទេនៅក្នុងការជំនុំជម្រះក្តី ។

ឃ) ហេតុផលទី១ៈការខកខានមិនបានចោទប្រកាន់បទឧក្រិដ្ឋកម្មជាតិៈដោយសារបទឧក្រិដ្ឋកម្មជាតិស្តីពីអំពើមនុស្ស

ឃាតនិងការធ្វើទារុណកម្មមានសមាសធាតុដែលមិនត្រូវដាក់បញ្ចូលនៅក្នុងនិយមន័យអន្តរជាតិដោយសារតែគ្មានការអនុញ្ញាតឲ្យដាក់បញ្ចូលបទល្មើសខាងផ្លូវច្បាប់លើសពីមួយទាក់ទងទៅនឹងអំពើដូចគ្នានៅក្នុងដីកាចោទប្រកាន់តែមួយ,ព្រមទាំងដោយសារការពិតដែលគាំទ្រដល់ធាតុផ្សំសំខាន់នៃឧក្រិដ្ឋកម្មក្នុងស្រុកត្រូវបានដាក់បញ្ចូលទៅក្នុងវិសាលភាពនៃការស៊ើបអង្កេតខាងផ្លូវតុលាការបទឧក្រិដ្ឋកម្មក្នុងស្រុកស្តីពីការធ្វើទារុណកម្មនិងការសម្លាប់ដោយបានគិតទុកជាមុនអាចបន្ថែមចូលទៅក្នុងដីកាបញ្ជូនរឿង ។

ង) ហេតុផលទី២: ការខកខានមិនបានដាក់បញ្ចូលសហកម្មឧក្រិដ្ឋកម្មរួមធ្វើជាគំរូនៃការទទួលខុសត្រូវដោយសារដីកាបញ្ជូនរឿងបាននិយាយសំដៅតែទៅលើសំណុំរឿងក្តីលេខ០០១ដែលដោះស្រាយតែទៅលើបទឧក្រិដ្ឋកម្មប្រព្រឹត្តនៅស-២១និងមិនរាប់បញ្ចូលសហកម្មឧក្រិដ្ឋកម្មរួមធ្វើជាផ្នែកមួយដាក់លាក់សម្រាប់ការស៊ើបអង្កេត, ឌុចមិនត្រូវបានជូនដំណឹងឲ្យបានត្រឹមត្រូវអនុលោមតាមវិធានផ្ទៃក្នុង២១(១)ឃ) អំពីការចោទប្រកាន់ថាបានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមស-២១មុនពេលមានដីកាបញ្ជូនរឿងឲ្យស៊ើបសួរចុងក្រោយរបស់សហព្រះរាជអាជ្ញាអាស្រ័យហេតុនេះអង្គបុរេជំនុំជម្រះនឹងមិនបន្ថែមការចោទប្រកាន់នេះទៅក្នុងដីកាបញ្ជូនរឿងនោះទេ ។

## នួន ជា



នួន ជា

១) ដីការបស់ ក.ស.ច.កបដិសេធសំណើសុំមោឃភាពនៃការបង្ហាញខ្លួនបឋម(ថ្ងៃទី២៨ខែមករាឆ្នាំ២០០៨)

២) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចជាសាធារណៈចំពោះបណ្តឹងជំទាស់បន្ទាន់របស់ចៅក្រមស៊ើបអង្កេតចិត្តបន្ទាន់របស់ចៅក្រមន័យថុល(ថ្ងៃទី៤ខែកុម្ភៈឆ្នាំ២០០៨)អង្គបុរេជំនុំជម្រះបដិសេធសំណើសុំបន្ទាន់របស់មេធាវីការពារក្តីចំពោះបណ្តឹងជំទាស់ចិត្តជាបន្ទាន់របស់ចៅក្រមន័យថុលដោយឈរលើមូលដ្ឋានភស្តុតាងមិនគ្រប់គ្រាន់ស្តីពីភាពលម្អៀងពិតប្រាកដ ឬជាក់ស្តែង ។

៣) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន(ថ្ងៃទី២០ខែមីនាឆ្នាំ២០០៨) ដោយបដិសេធបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើហេតុផលថាលក្ខខណ្ឌយ៉ាងច្រើនរបស់វិធានផ្ទៃក្នុង៦៣(៣)សម្រាប់ការឃុំខ្លួនបណ្តោះអាសន្ននៅតែបំពេញបាននៅឡើយ) ។

៤) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាបដិសេធសំណើសុំមោឃភាព(ថ្ងៃទី២៦ខែសីហាឆ្នាំ២០០៨) បណ្តឹងឧទ្ធរណ៍ត្រូវបដិសេធ)

៥) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងលក្ខខណ្ឌឃុំខ្លួនបណ្តោះអាសន្ន(ថ្ងៃទី២៦ខែកញ្ញា ឆ្នាំ២០០៨) អង្គបុរេជំនុំជម្រះបានទទួលស្គាល់បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីជំទាស់នឹងសេចក្តីសម្រេចរបស់ ក.ស.ច.ក.ដែលរារាំងជនត្រូវចោទមិនឲ្យទាក់ទងគ្នាដោយឈរលើហេតុផលថាច្បាប់អន្តរជាតិបានដាក់ឲ្យនៅដាច់ដោយឡែកពីគ្នាដែលចាំបាច់សម្រាប់ការការពារមិនឲ្យមានការផ្សំគំនិតដើម្បីដាក់សម្ពាធលើសាក្សីនិងជនរងគ្រោះ ។ អង្គបុរេជំនុំជម្រះបានយោងទៅលើសេចក្តីសម្រេចចិត្តរបស់ខ្លួនចុះ ថ្ងៃទី៣០ ខែមេសាដែលផ្តល់ការទាក់ទងគ្នារវាងអៀង សារី និងប្រពន្ធរបស់គាត់ អៀង ធីរិទ្ធ (សូមមើលលេខ៥,អៀង សារី,នៅខាងក្រោម)

៦) អង្គបុរេជំនុំជម្រះ-សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ទាក់ទងទៅនឹងការតែងតាំងអ្នកជំនាញ(ថ្ងៃទី២២ខែតុលាឆ្នាំ២០០៨)អង្គបុរេជំនុំជម្រះបានបដិសេធបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីស្តីពីការបដិសេធរបស់ ក.ស.ច.កមិនអនុញ្ញាតឲ្យមានអ្នកជំនាញពិនិត្យមើលពីភាពនៅមាំមួនរបស់ នួន ជា ក្នុងការកាត់សេចក្តី ។ ផ្ទុយពីការយល់ឃើញរបស់ ក.ស.ច.កលទ្ធភាពរបស់ជនត្រូវចោទចូលរួមយ៉ាងមានប្រសិទ្ធិភាពនៅក្នុងដំណើរការសេចក្តីចាប់តាំងពីដើមដំបូងដែលគាត់ត្រូវបានចោទពីបទឧក្រិដ្ឋ

កម្ម ។ ទោះជាយ៉ាងណាក៏ដោយខ្លួនជាមិនមានកម្រិតធ្ងន់ធ្ងរបំផុតដែលទាមទារឲ្យអ្នកជំនាញពិនិត្យមើលពីសមត្ថភាពរបស់គាត់ឡើយដោយសារតែ អ្នកជំនាញខាងវេជ្ជសាស្ត្របានកំណត់កាលពីមុនថាសមត្ថភាពយល់ដឹងរបស់គាត់មិនប៉ះពាល់ដោយសារតែស្ថានភាពសុខភាពរបស់គាត់ទេហើយគាត់បាននិយាយ«ប្រកបដោយស្មារតីនឹងនរពាក់ព័ន្ធរៀបចំត្រឹមត្រូវនិងគ្រប់ជ្រុងជ្រោយ» នៅក្នុងសវនាការនៅចំពោះមុខក.ស.ច.កនិងអង្គបុរេជំនុំជម្រះ ។

**ខៀវ សំផន**



ខៀវ សំផន

១) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចផ្អាកសវនាការលើការឃុំខ្លួនបណ្តោះអាសន្ន(ថ្ងៃទី២៣ខែមេសា ឆ្នាំ២០០៨) សំណើរបស់ខៀវ សំផន សុំផ្អាកសវនាការស្តីពីបណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្នត្រូវបានអនុញ្ញាត ។ ខៀវ សំផនបានស្នើឲ្យមានការផ្អាកដោយឈរលើហេតុផលថាគាត់ត្រូវបានដកហូតសិទ្ធិចំពោះការការពារពីសំណាក់សហមេធាវីអន្តរជាតិហ្សាក់វឺសហ្សេ ។ វឺសហ្សេបានបដិសេធមិនព្រមបន្តការពារដោយសារតែឯកសារទាំងអស់នៅក្នុងសំណុំរឿងក្តីមិនត្រូវបានបកប្រែ ។ អនុលោមតាមវិធានផ្ទៃក្នុង៣៨(១)អង្គបុរេជំនុំជម្រះបានព្រមានវឺសហ្សេថាគាត់បានរំលោភបំពានដំណើរការរបស់អង្គបុរេជំនុំជម្រះនិងសិទ្ធិរបស់ជនត្រូវចោទ ។

២) ក.ស.ច.ក--ដីកាបដិសេធសំណើសុំដោះលែង(ថ្ងៃទី២៣ខែមិថុនាឆ្នាំ២០០៨)ដោយបដិសេធសំណើសុំដោះលែងដោយសារបញ្ហាសុខភាព) ។

៣) ក.ស.ច.ក--ដីកាបដិសេធសំណុំបែបបទដោះលែង(ថ្ងៃទី២៨ខែតុលាឆ្នាំ២០០៨)(ដោយបដិសេធសំណុំបែបបទដោះលែង) ។

៤) អង្គបុរេជំនុំជម្រះ--សេចក្តីណែនាំចំពោះមេធាវីការពារក្តីពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន(ថ្ងៃទី១៥ខែសីហាឆ្នាំ២០០៨)អង្គបុរេជំនុំជម្រះបានក្រើនរំឭកដល់មេធាវីការពារក្តីថាបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្នត្រូវបានផ្អាកអស់រយៈពេលជិតបួនខែ ព្រមទាំងបានផ្តល់ឲ្យមេធាវីការពារក្តីរយៈពេល៧ថ្ងៃដើម្បីបញ្ជាក់អំពីគោលជំហររបស់ខ្លួន ។

៥) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចស្តីពីសំណើសុំឲ្យមានសវនាការសាធារណៈស្តីពីបណ្តឹងឧទ្ធរណ៍លើការបកប្រែ(ថ្ងៃទី៤ខែវិច្ឆិកាឆ្នាំ២០០៨)ដោយផ្តល់ឲ្យមានសវនាការសាធារណៈ)

៦) ក.ស.ច.ក--ដីកាស្តីពីការពន្យារការឃុំខ្លួនបណ្តោះអាសន្ន(ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨) ដោយពន្យាការឃុំខ្លួនរយៈពេលមួយឆ្នាំ) ។

៧) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចលើសំណុំបែបបទបំពេញបន្ថែមសម្រាប់ការដោះលែង(ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨) ។

ខៀវ សំផន បានដាក់សំណុំបែបបទមួយសុំឲ្យមានការដោះលែងជាបន្ទាន់ដែលជូនផ្ទាល់ទៅកាន់ប្រធានអង្គបុរេជំនុំជម្រះរួមជាមួយបណ្តឹងឧទ្ធរណ៍របស់គាត់ជំទាស់នឹងដីការបស់ ក.ស.ច.កស្តីពីការពន្យារពេលការឃុំខ្លួនរយៈពេលមួយឆ្នាំ(សូមមើលលេខ៦ខាងលើ) ។ ដោយទាញការសន្និដ្ឋានថាក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនអាចយកមកអនុវត្តន៍បានហើយថារាល់សេចក្តីសម្រេចចិត្តទាំងអស់ស្តីពីការដោះលែងនឹងត្រូវធ្វើឡើងដោយអង្គបុរេជំនុំជម្រះដែលជាអង្គភាពប្រធានបានសន្និដ្ឋានថាសំណុំបែបបទមិនអាចទទួលយកបាន ។

**អៀង សារី**--សូមមើលកាំង ហ្គេចអ៊ាវ លេខ៥និង៦ សម្រាប់ការវិនិច្ឆ័យលើការព្យាយាមរបស់ អៀង សារីក្នុងការធ្វើអន្តរាគមន៍នៅក្នុងការពិចារណារបស់អង្គបុរេជំនុំជម្រះអំពីភាពអាចយកមកអនុវត្តបាននូវសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់នឹងដីកាបញ្ជូនរឿងរបស់កាំង ហ្គេចអ៊ាវ ។


អៀង សារី

១) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ទាក់ទងទៅនឹងការទំនាក់ទំនងរវាងជនត្រូវចោទនិងប្រពន្ធរបស់គាត់ (ថ្ងៃទី៣០ខែមេសា ឆ្នាំ២០០៨) ។ អនុស្សារណៈរបស់ក.ស.ច.ក ដែលផ្តល់សិទ្ធិឲ្យ អៀង សារី និងប្រពន្ធរបស់គាត់ អៀង ធីរិទ្ធ ទៅសួរសុខទុក្ខគ្នាម្តងក្នុងមួយសប្តាហ៍មិនមានហេតុផលគ្រប់គ្រាន់ ។ អនុលោមតាមសិទ្ធិរបស់ជនត្រូវចោទដែលត្រូវតែប្រព្រឹត្តក្នុងលក្ខណៈមនុស្សជាតិការទំនាក់ទំនងរវាងជនត្រូវចោទមិនត្រូវកម្រិតឬបដិសេធដរាបណាការទំនាក់ទំនងនេះការពារផលប្រយោជន៍ដល់ការស៊ើបអង្កេត (សូមមើលលេខ៦នួន ជាខាងលើ) ។

២) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ជំទាស់នឹងសំបុត្រទាក់ទងទៅនឹងសំណើសុំព័ត៌មានស្តីពមន្ត្រីច្បាប់ដេវីដ ប៊យ (ថ្ងៃទី២៨ខែសីហាឆ្នាំ២០០៨) សេចក្តីសម្រេចរបស់ក.ស.ច.កដែលបដិសេធសំណើនេះត្រូវអនុវត្ត) ។

៣) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន(ថ្ងៃទី១៧ខែតុលា ឆ្នាំ២០០៨) បណ្តឹងឧទ្ធរណ៍ត្រូវបដិសេធ) ។

៤) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ទាក់ទងទៅនឹងការតែងតាំងអ្នកជំនាញ(ថ្ងៃទី២១ខែតុលា ឆ្នាំ២០០៨) ការតែតាំងអ្នកជំនាញខាងចិត្តសាស្ត្រត្រូវបដិសេធដោយផ្អែកលើហេតុផលដូចគ្នាដូចធ្លាប់បានបដិសេធលើបណ្តឹងឧទ្ធណ៍របស់នួន ជា ទាក់ទងទៅនឹងការតែងតាំងអ្នកជំនាញខាងសុខភាព (សូមមើលលេខ៦នួនជាខាងលើ) ។

៥) ក.ស.ច.ក--ដីកាស្តីពីការពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន(ថ្ងៃទី១០ខែវិច្ឆិកា ឆ្នាំ២០០៨) ។

**អៀងធីរិទ្ធ**

១) អង្គបុរេជំនុំជម្រះ--សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន(ថ្ងៃទី៩ខែកក្កដា ឆ្នាំ២០០៨) ដោយយល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្នមានភាពត្រឹមត្រូវដោយឈរលើហេតុផលមួយចំនួនដូចបានបញ្ជាក់នៅក្នុងវិធានផ្ទៃក្នុង៦៣(៣) ដែលបង្កើតលក្ខខណ្ឌសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន) ។


អៀង ធីរិទ្ធ

២) ក.ស.ច.ក--ដីកាស្តីពីការពន្យារពេលលើការឃុំខ្លួនបណ្តោះអាសន្ន(ថ្ងៃទី១០ខែវិច្ឆិកា ឆ្នាំ២០០៨) ។

**ថាយល័រ ណើមស៍**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# តើមានចុងចោទប៉ុន្មានរូបដែលថាច្រើនក្នុងសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម?

កាត់ទោសចុងចោទទៅតាមចំនួនមួយសមស្របដែលបានកំណត់ទៅតាមធនធានរយៈពេលយូរអង្វែងដែលអាចរកបានមានវរបកស្រាយបន្ទឹតតឈប់ឈរចាប់តាំងពីមានការចរចា នៅក្នុងឆ្នាំ១៩៩៧ដែលថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយកចិត្តទុកដាក់តែទៅលើ“មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់” និងអ្នកដែលមាន“ទំនួលខុសត្រូវខ្ពស់បំផុត” ប៉ុណ្ណោះចំពោះខក្រិដ្ឋកម្មដ៏ឃោរឃៅក្នុងរបបប៉ុលពត ។ ក្រុមអ្នកចរចាកម្ពុជាអង្គការសហប្រជាជាតិនិងសហរដ្ឋអាមេរិកមិនធ្លាប់បានកំណត់ចំនួនជនសង្ស័យដែលត្រូវចោទប្រកាន់និងនាំយកមកកាត់ទោសត្រឹមតែ៥ ឬ៦នាក់នោះឡើយ ទោះបីជាមិនមានអាថ៌កំបាំងដែលថាមន្ត្រីកម្ពុជាមួយចំនួនចង់ឲ្យមានការកាត់ទោសតែចំនួនមនុស្សតិចតួចប៉ុណ្ណោះដោយមិនរាប់បញ្ចូលទាំងមន្ត្រីរដ្ឋាភិបាលនិងមន្ត្រីយោធាបច្ចុប្បន្ននោះឡើយ ។ ប៉ុន្តែគ្មានការចរចាណាមួយច្បាស់លាស់ដែលបង្ហាញឲ្យឃើញពីការទទួលយកទស្សនៈរបស់កម្ពុជានោះឡើយ ដោយសារតែទស្សនៈនេះបានក្លាយជាគោលជំហរមួយដែលមិនអាចទទួលយកបានសម្រាប់អ្នកចរចាដែលមិនមែនជាប្រជាជនកម្ពុជា ហើយហេតុការណ៍នេះនឹងបំផ្លាញចោលទាំងស្រុងនូវភាពសុចរិតរបស់តុលាការ ។ នៅក្នុងការចរចាជាច្រើនលើកនិងមានរយៈពេលយូរជាមួយអាជ្ញាធរកម្ពុជានិងអង្គការសហប្រជាជាតិ ក្រុមអ្នកចរចានិយាយតែអំពីបុគ្គលដែលគេនឹងនាំយកមកជំនុំជម្រះទោសរហូតដល់១៥នាក់ ឬប្រហាក់ប្រហែលនេះប៉ុណ្ណោះ ហើយយើងក៏បានដឹងដែរថាមានបុគ្គលច្រើនជាងនេះដែលត្រូវបានស្នើឡើងពីសំណាក់អ្នកស្រាវជ្រាវនិងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិជាច្រើន ។ មានពេលខ្លះអ្នកចរចាភាគីខាងអង្គការសហប្រជាជាតិបាននិយាយដល់ចុងចោទសំខាន់ៗដែលមានចំនួនចាប់ពី២០រហូតដល់៣០នាក់ប៉ុន្តែនៅក្នុងការចរចានេះយើងបានដឹងនិងបានបង្ហាញអំពីតួលេខខ្ពស់បំផុតដែលប្រហែលជាជាង១៥នាក់ឬប្រហាក់ប្រហែលនេះនៅក្នុងការជំនុំជម្រះទោស ។ យើងដឹងថាធនធានរបស់យើងមានកំណត់និងស្ថានភាពនយោបាយជាក់ស្តែងក៏ដូចជាបុគ្គលទាំងនោះមានវ័យចាស់ជរាដែលអាចនឹងធ្វើឲ្យចំនួនមនុស្សដែលត្រូវយកមកកាត់ទោសនៅសល់ចំនួនតិចប៉ុន្តែក៏មិនមែននៅសល់តិចពេកដែរ ។

## គ្មាននិយមន័យណាមួយចែងឲ្យបានច្បាស់លាស់

ក្នុងនាមជាអ្នកចរចានិងអ្នកធ្វើសេចក្តីព្រាង យើងមិនដែល



អ្នកភូមិក្នុងបន្ទប់សវនាការ

ព្យាយាមបង្កើតនិយមន័យឲ្យបានច្បាស់លាស់ទៅលើពាក្យ "មេដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត" នោះឡើយ ដោយសារតែនិយមន័យនេះបានក្លាយជាលំហាត់មួយប្រកបដោយភាពប្រថុយប្រថាន ។ តាមការពិតអ្នកចរចាខាងភាគីអង្គការសហប្រជាជាតិនិងសហរដ្ឋអាមេរិកគឺជាអ្នកដែលជំរុញឲ្យមានកម្រិតមួយខ្ពស់សម្រាប់ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ជាជាងការចង់បានរបស់កម្ពុជានូវប្រភេទដែលមានលក្ខណៈទូលំទូលាយសម្រាប់ពាក្យ "អ្នកទទួលខុសត្រូវ" នៅក្នុងដំណាក់កាលនៃការចរចាសំខាន់ៗចុងក្រោយនេះ ។ ការខិតខំប្រឹងប្រែងនេះបានធ្វើឲ្យកម្រិតនេះកើនឡើងកាន់តែខ្ពស់រហូតដល់ "អ្នកទទួលខុសត្រូវធំធេងបំផុត" ដែលបានចរចាសម្រាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូននៅពាក់កណ្តាលឆ្នាំ២០០០ត្រូវបានប្រានចោល ដើម្បីទទួលយកទស្សនៈមួយយូរអង្វែងនិងទូលំទូលាយសម្រាប់ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ។

អ្វីដែលកំពុងតែលេចឮរវាងសហព្រះរាជអាជ្ញានិងការដាក់ពាក្យបណ្តឹងទៅកាន់អង្គបុរេជំនុំជម្រះត្រូវបានរំពឹងទុកនៅក្នុងការចរចាហើយអ្វីដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលគឺថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងធ្វើការទៅតាមឆន្ទៈដែលអង្គជំនុំជម្រះបានរៀបចំឡើង ។ ការពិតខ្ញុំជឿជាក់ថាដំណើរការនេះកំពុងត្រូវបានសាកល្បងទោះបីជាមានសេចក្តីថ្លែងការណ៍ស្តីអំពីឆន្ទានុសិទ្ធិមួយរបស់សហព្រះរាជអាជ្ញាកម្ពុជាបង្ហាញជាសាធារណៈក៏ដោយដែលនឹងនាំឲ្យចៅក្រមផ្នែកការពិចារណាស្តីពីគោលបំណងនៅក្រោយការជំទាស់ ។ ហេតុផលសំខាន់ពីរធំៗដែលអ្នកចរចាគិតថាសហព្រះរាជអាជ្ញាមិនយល់ស្របអាចបណ្តាលមកពី ១) ផ្អែកលើលក្ខណៈសម្បត្តិរបស់បុគ្គលជាក់លាក់ណាមួយដែលកំពុងត្រូវចោទប្រកាន់ ឬ ២) ដោយសារសហព្រះរាជអាជ្ញាម្នាក់បានបង្ហាញចេញពីការទទួលរងឥទ្ធិពល នយោបាយហើយសហព្រះរាជអាជ្ញាម្នាក់ទៀតបានស្វែងរកវិធានរបស់អង្គបុរេជំនុំជម្រះដើម្បីធានាសុចរិតភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជាក់ស្តែងក្នុងអំឡុងពេលចរចាការព្រួយបារម្ភអំពីឥទ្ធិពលនយោបាយគឺជាការលំបាកមួយក្នុងការដោះស្រាយប៉ុន្តែប្រជាជនគ្រប់រូបបានដឹងរួចហើយថាយើងកំពុងតែបង្កើតយន្តការដោះស្រាយជម្លោះដើម្បីយកឈ្នះលើលក្ខណៈសម្បត្តិឬការមិនយល់ស្របផ្អែកនយោបាយ ប្រសិនបើចំណុចណាមួយកើតឡើង ។ ការសាកល្បងដ៏ពិតប្រាកដមួយមិនមែនជាការដាក់ពាក្យបណ្តឹងរបស់សហព្រះរាជអាជ្ញាដែលតុលាការបង្កើតឡើងដើម្បីសម្រុះសម្រួលនោះឡើយប៉ុន្តែថាតើចៅក្រមនៃអង្គបុរេជំនុំជម្រះឈាននៅមុខក្នុងការរៀបចំនិងបំពេញភារកិច្ចប្រកបដោយកម្រិតខ្ពស់បំផុតនៃសុចរិតភាពខាងតុលាការដែរឬអត់ ។ យើងអាចវាយតម្លៃការបំពេញភារកិច្ចរបស់អង្គបុរេជំនុំជម្រះ នៅពេលដែលការសម្រេចចិត្តត្រូវបានប្រគល់ឲ្យ ។

## ភាពប្រសើរឡើងសម្រាប់អ្នកផ្តល់ជំនួយ

ទីបំផុតការបង្កើនចំនួនជនត្រូវចោទពី៥រហូតដល់១០ឬ១៥នាក់អាចធ្វើឲ្យការទាមទារថ្លៃឧបត្ថម្ភផ្នែកហិរញ្ញវត្ថុដែលមានរយៈពេលវែងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាងាយស្រួលក្នុងការតស៊ូមតិពីព្រោះវាអាចបង្ហាញពីសុចរិតភាពនិងការជឿទុកចិត្តរបស់តុលាការ ។ នេះជាគន្លឹះដែលយើងអាចចាក់សោរយកថវិកាអន្តរជាតិបានហើយនេះក៏មិនមែនជាទឡ្ហីករណ៍ដែលថាចំនួនចុងចោទត្រូវតែកំណត់ដើម្បីបំពេញរបៀបវារៈនយោបាយក្នុងស្រុកដែរ ។ នៅពេលដែលផ្ទុក្នុងនយោបាយនិងអំពើពុករលួយគ្របដណ្តប់លើការងាររបស់តុលាការថវិកាអន្តរជាតិនឹងអស់ទៅវិញយ៉ាងឆាប់រហ័ស ហើយការបញ្ចប់សវនាការទៅលើចុងចោទចំនួន៥រូបនឹងកាន់តែមានការលំបាកក្នុងការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុនិងដំណោះស្រាយចំពោះហេតុការណ៍ថ្មីៗនៅក្នុងប្រវត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញគឺភាគីម្ខាងៗដែលជជែកដេញដោលគ្នាត្រូវទទួលយកការសម្រុះសម្រួលគ្នាដូចដែលក្រុមអ្នកចរចាបានស្នើឡើងពោលគឺសុំមិនឲ្យមានចុងចោទតិចពេកហើយក៏មិនឲ្យមានចុងចោទច្រើនពេកដែរប៉ុន្តែសុំឲ្យមានចំនួនចុងចោទសមស្របដែលអាចធ្វើឲ្យមានប្រភពធនធានរយៈពេលវែងនិងការអនុវត្តមួយសមហេតុផលចំពោះតម្រូវការដែលសុំឲ្យចុងចោទជា"មេដឹកនាំជាន់ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិងអ្នកទទួលខុសត្រូវខ្ពស់បំផុត"សម្រាប់ឧក្រិដ្ឋកម្មក៏ឃោរឃៅក្នុងរបប ប៉ុល ពត ។ ខ្ញុំសង្ឃឹមថាចៅក្រមក៏យល់ឃើញដូចនេះដែរ ។

**ដេវីដ សេហ្វ័រ**

# នួន ជា កាលពីក្មេងនៅទីក្រុងបាងកក (១៩៤២-១៩៥០) និងបក្សកុម្មុយនីស្តថៃ៖ ជីវិតរបស់បុរសនេះនៅទីក្រុងបាងកកដែលបានក្លាយជា"បងធំទី២" នៅក្នុងរបបខ្មែរក្រហម

ផ្អែកលើបទសម្ភាសន៍ជាមួយ នួន ជា និងអតីតសមមិត្ត របស់គាត់នៅក្នុងបក្សកុម្មុយនីស្តថៃនិងផ្អែកលើកំណត់ត្រាសិក្សា នៅក្នុងទីក្រុងបាងកកការសិក្សានេះបង្ហាញជូនពីភាពលម្អិតស្តីអំពី ជីវិតរបស់គាត់នៅក្នុងទីក្រុងបាងកក និងកែតម្រូវព័ត៌មានដែល ភ័ន្តច្រឡំបានសរសេរអំពីគាត់ ។ គាត់កើតនៅថ្ងៃទី៧ ខែ កក្កដា ឆ្នាំ១៩២៦ នៅខេត្តបាត់ដំបងនិងបានទៅទីក្រុងបាងកក នៅឆ្នាំ ១៩៤២ ដើម្បីសិក្សាថ្នាក់ឧត្តមដោយមានឈ្មោះថៃ រុង លឹត ឡៅឌី ឬ រុងលឹត ឡៅឌី ។ គាត់បានបញ្ចប់ការសិក្សាថ្នាក់មធ្យមរៀនវគ្គ ត្រៀម២ឆ្នាំនៅសកលវិទ្យាល័យធម្មាសាធបន្ទាប់មកបានចូល រៀនខាងច្បាប់នៅសកលវិទ្យាល័យធម្មសាធ ។ គាត់បានចូលក្នុង អង្គការយុវជនថៃឆ្វេងនិយមនៅឆ្នាំ១៩៤៧ និងបានចាប់ផ្តើម បម្រើការជាស្មៀននៅក្រសួងហិរញ្ញវត្ថុ ។ ក្នុងចំណោមមិត្តភក្តិ ជិតស្និទ្ធរបស់គាត់ គាត់បានស្គាល់អង្គការយុវជនថៃ ហើយអ្នក នៅកន្លែងធ្វើការរបស់គាត់គឺជាអ្នកដែលបានក្លាយជាសមាជិក របស់បក្សកុម្មុយនីស្តថៃប៉ុន្តែគាត់ស្ថិតក្រោមឥទ្ធិពលរបស់បក្ស អស់រយៈពេល៨ឆ្នាំដោយមិនចូលរួមរហូតដល់ឆ្នាំ១៩៥០ ។


នួន ជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ត្រឹមខែមករាឆ្នាំ១៩៥០ គាត់ស្ទើរតែបញ្ចប់ការសិក្សាឆ្នាំ ទីពីរនៅសកលវិទ្យាល័យ ។ នៅឆ្នាំនោះគាត់បានចូលរួមបក្ស កុម្មុយនីស្តថៃនិងចាប់ផ្តើមធ្វើការនៅក្នុងក្រសួងការបរទេស ។ ប៉ុន្តែគាត់បានបោះបង់ចោលការសិក្សានិងការងាររដ្ឋាភិបាល ដើម្បីចូលរួមការតស៊ូប្រឆាំងនឹងអាណានិគមនៅក្នុងប្រទេស កម្ពុជា ។ មានព័ត៌មានតិចតួចបុគ្គានសោះស្តីអំពីពេលវេលារបស់ នួន ជា នៅក្នុងប្រទេសថៃពន្យល់អំពីជម្រើសនយោបាយកែប្រែ សង្គមទាំងស្រុងនិងកាប់សម្លាប់នៅពេលដែលខ្មែរក្រហមកាន់ អំណាច ។ ជម្រើសទាំងនេះប្រាកដជាមានឫសគល់ផ្សេងទៀតដូច ជាបទពិសោធន៍របស់ នួន ជា នៅក្នុងប្រទេសវៀតណាមឬបន្ទាប់ ពីការវិលត្រឡប់របស់គាត់មកប្រទេសកម្ពុជានៅឆ្នាំ១៩៥៥ ។

## សេចក្តីផ្តើម

ក្នុងនាមជាលេខាទីពីរនៃបក្សកុម្មុយនីស្តកម្ពុជា ជាតំណែង ដែលគាត់បានកាន់តាំងពីឆ្នាំទសវត្សរ៍ ឆ្នាំ១៩៦០ នួន ជា ត្រូវ បានស្គាល់ថាជា «បងធំទី២» ដែលឈរលំដាប់ទីពីរបន្ទាប់ពីមេ ដឹកនាំបក្ស ប៉ុល ពត ឈ្មោះហៅក្រៅ សាឡុត ស ឆ្នាំ (១៩២៥-១៩៩៨) ។ បន្ទាប់ពីកាន់កាប់ទីក្រុងភ្នំពេញដោយ កម្លាំងកុម្មុយនីស្តនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឈ្មោះរបស់ ប្រទេសត្រូវបានប្រែទៅជាកម្ពុជាប្រជាធិបតេយ្យហើយ នួន ជា បានក្លាយជាប្រធានសភាតំណាងប្រជាជនរបស់ប្រទេស ។ នៅ ក្នុងតំណែងជាច្រើនគាត់បានក្លាយជាកម្លាំងជំរុញបែបមនោគមន៍ វិជ្ជានៅពីក្រោយរបបកម្ពុជាប្រជាធិបតេយ្យ និងទទួលខុសត្រូវ ចំពោះគោលនយោបាយផ្លាស់ប្តូរប្រទេសទាំងស្រុងរបស់ខ្លួន ។ បន្ទាប់ពីការលុកលុយរបស់វៀតណាមមកលើកម្ពុជានៅចុង

ឆ្នាំ១៩៧៨ គាត់បានស្នាក់នៅជាមួយ ប៉ុល ពត ដោយដកថយមកជាមួយមេដឹកនាំបក្សមកកាន់ជនបទ។ ប៉ុល ពត ស្លាប់នៅខែមេសា ឆ្នាំ១៩៩៨ ហើយនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំដដែល នួន ជា ជាមួយ ខៀវ សំផន ប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យបានផ្ញើលិខិតមួយច្បាប់ជូន ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជាថាយល់ព្រមចុះចូលនិងនិយាយថាពួកគេមានបំណងរស់នៅក្នុងប្រទេសជាពលរដ្ឋសាមញ្ញ។ ហ៊ុន សែន បានស្វាគមន៍ចំពោះការស្នើឡើងនេះ។ បន្ទាប់ពីនោះ នួន ជា បានផ្លាស់ទៅក្រុងប៉ៃលិនដែលមានព្រំដែនជាប់ប្រទេសថៃ ហើយបានរស់នៅជាមួយក្រុមគ្រួសាររបស់គាត់។ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ គាត់ត្រូវបានចាប់ខ្លួននិងជាប់ឈ្មោះជាជនសង្ស័យនៃអំពើប្រល័យពូជសាសន៍ដែលបានកើតឡើងក្នុងអំឡុង របបកម្ពុជាប្រជាធិបតេយ្យ។ គាត់ត្រូវបាននាំខ្លួនមកទីក្រុងភ្នំពេញហើយបច្ចុប្បន្នកំពុងរង់ចាំសវនាការនៅចំពោះមុខសាលាក្តីពិសេសដែលត្រូវបានបង្កើតឡើងក្រោមការទំនុកបម្រុង របស់អង្គការសហប្រជាជាតិដើម្បីធ្វើការវិនិច្ឆ័យទៅលើអំពើប្រល័យពូជសាសន៍។

ចំណេះដឹងរួមមួយក្នុងចំណោមអ្នកស្រាវជ្រាវជាន់ខ្ពស់ស្តីពីប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើបគឺ នួន ជា បានទទួលការអប់រំថ្នាក់មធ្យមនិងថ្នាក់ឧត្តមនៅទីក្រុងបាងកកដែលគាត់ត្រូវបានជ្រើសរើសឲ្យចូលធ្វើការជាមន្ត្រីមួយរូបនៅក្នុងរដ្ឋាភិបាលថៃហើយនៅក្នុងទីក្រុងបាងកកគាត់បានក្លាយជាសមាជិកបក្សកុម្មុយនីស្តថៃ។ ទោះបីជាយ៉ាងណាក៏ដោយមិនមានការសិក្សាណាមួយដែលផ្តល់ឲ្យនូវរូបភាពត្រឹមត្រូវនិងលម្អិតរបស់បុរសម្នាក់នៅក្នុងអំឡុងឆ្នាំដែលគាត់បានស្នាក់នៅក្នុងទីក្រុងបាងកកទេ។ នៅក្នុងស្នាដៃរបស់គាត់ស្តីពី ប៉ុល ពត, ដេវីដ ឆេនល័រ អ្នកស្រាវជ្រាវជាន់ខ្ពស់ល្បីល្បាញម្នាក់ទៅលើប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើបគ្រាន់តែបង្ហាញជូនដោយសង្ខេបអំពី នួន ជា ដោយនិយាយយ៉ាងងាយថាៈ

នួន ជា គឺជាខ្មែរកាត់ចិនមកពីខេត្តបាត់ដំបងហើយកើតក្នុងគ្រួសារធូរធានៅឆ្នាំ១៩២៧។ ឈ្មោះរបស់គាត់ពីកំណើតគឺ ឡូ បិន គុណ។ ក្នុងអំឡុងសង្គ្រាមលោកលើកទីពីរនៅពេលដែលខេត្តបាត់ដំបងស្ថិតក្រោមការត្រួតត្រារបស់ថៃគាត់បានទៅទីក្រុងបាងកកដែលគាត់បានបញ្ចប់ការសិក្សាថ្នាក់មធ្យមនៅក្រោមឈ្មោះ ឡុង រូត។ នៅឆ្នាំ១៩៤៥ គាត់បានចុះឈ្មោះចូលរៀនជានិស្សិតច្បាប់នៅសកលវិទ្យាល័យធម្មាសាធក្នុងទីក្រុងបាងកកដែលគាត់ទទួលបានអាហារូបករណ៍ទៅសិក្សា។ ភ្លាមនោះគាត់បានក្លាយជាសមាជិកបក្សកុម្មុយនីស្តថៃដោយមិនផ្តល់ដំណឹងដល់ក្រុមគ្រួសាររបស់គាត់ឡើយ។ គាត់ប្រហែលត្រូវបានជំរុញឲ្យធ្វើដូច្នោះដោយជីដូនមួយរបស់ ឈ្មោះ ស៊ីវ ហេង ដែលបានចំណាយពេលមួយផ្នែកក្នុងសង្គ្រាមនៅទីក្រុងបាងកក ហើយបានចូលរួមបក្សកុម្មុយនីស្តឥណ្ឌូចិននៅខេត្តបាត់ដំបងនៅឆ្នាំ១៩៤៥។

ឧទាហរណ៍មួយទៀតគឺជាការអត្ថាធិប្បាយសង្ខេបរបស់ ប៊ែន ឃៀរនិន អ្នកស្រាវជ្រាវជាន់ខ្ពស់ដែលមានចំណេះដឹងលម្អិតអំពីបក្សកុម្មុយនីស្តកម្ពុជា។ គាត់សរសេរនៅក្នុងស្នាដៃរបស់គាត់ស្តីពីប្រធានបទនេះថាៈ

នៅឆ្នាំដូចគ្នា (ឆ្នាំ១៩៤៥) ឡុង រ៉េត និស្សិតច្បាប់ជនជាតិខ្មែរនៅសកលវិទ្យាល័យធម្មាសាធទីក្រុងបាងកកដែលបម្រើការងារពាក់កណ្តាលម៉ោងជាស្មៀននៅក្នុងក្រសួងការបរទេសត្រូវបានជ្រើសរើសដោយ មួន និងក្រោយមកបានចូលរួមបក្សកុម្មុយនីស្តថៃ។ គាត់បានផ្លាស់ទៅខេត្តបាត់ដំបងហើយភ្លាមនោះបានផ្ទេរទៅបក្សកុម្មុយនីស្តឥណ្ឌូចិន។ (នៅឆ្នាំ១៩៦០ ក្រោមឈ្មោះ នួន ជា គាត់បានក្លាយជាលេខាទីពីររបស់បក្សកុម្មុយនីស្តកម្ពុជា)។

មាននិក្ខេបបទថ្នាក់បណ្ឌិតដែលរៀបចំឡើងដោយ ស៊ុម សាក់ ដឹមទ៊ីរ៉ាសាគល់ អ្នកស្រាវជ្រាវជាន់ខ្ពស់ថៃដែលមានចំណេះដឹងជ្រៅជ្រះស្តីពីប្រវត្តិសាស្ត្របក្សកុម្មុយនីស្តថៃ។ ទាក់ទិននឹង នួន ជា ក្នុងអំឡុងពេលដែលគាត់នៅក្នុងបក្ស ស៊ុម សាក់ ភ្ជាប់សេចក្តីសង្ខេបជាមួយពាក្យមិនត្រឹមត្រូវមួយចំនួនរបស់ឧត្តម ស៊ីសុវ៉ាន ដោយសរសេរថា ៈ

នៅឆ្នាំ១៩៤៧ ឧត្តមចងចាំនៅពេលដែលត្រូវបានគេស្នើឲ្យចូលរួមប្រជុំបីបួនកន្លែងរបស់កងយុវជនដើម្បីនិយាយអំពីស្ថានភាពក្នុងប្រទេសនិងអន្តរជាតិ។ ក្នុងនាមជាកម្មាភិបាលម្នាក់នៅក្នុងការងារឃោសនាបើកចំហជាធម្មតាគាត់មិនបានចូលរួមនៅក្នុងសកម្មភាពអង្គការចាត់តាំងសមាត់បែបនេះឡើយ)។ កងនេះ

មានសមាជិក៦ឬ៧នាក់ក្រោមការដឹកនាំរបស់រួមនិងរីងដែលក្នុងចំណោមនោះមានសមាជិកខ្មែរវ័យក្មេងម្នាក់ ។ គាត់ត្រូវបានណែនាំឲ្យស្គាល់ខត្តមដោយប្រើឈ្មោះ«រ័ត្ន»ហើយត្រូវបានគេនិយាយថាធ្លាប់ធ្វើការនៅក្នុងក្រសួងការបរទេសថៃ ។ គាត់បានត្រឡប់មកប្រទេសកម្ពុជានៅក្នុងឆ្នាំដដែល ។ ក្រោយមក ខត្តមបានដឹងថា «រ័ត្ន» ការពិតគឺជា នួន ជា ដែលបន្ទាប់ពីឆ្នាំ១៩៧៥ បានក្លាយជាប្រធានសភាតំណាងប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

រួមជាមួយសេចក្តីសន្ទេបច្បាស់លាស់ អត្ថបទនីមួយៗស្តីពី នួន ជា ផ្ទុកនូវភាពមិនត្រឹមត្រូវអំពីឆ្នាំកំណើតរបស់គាត់ជាឆ្នាំដែលគាត់បានចូលរៀននៅសកលវិទ្យាល័យធម្មាសាធនិងវគ្គសិក្សាដែលគាត់បានចូលរួមឈ្មោះដែលគាត់បានប្រើនៅប្រទេសថៃអំពីការងាររបស់គាត់នៅក្នុងទីក្រុងបាងកកនៅពេលណានិងរបៀបណាដែលគាត់បានចូលរួមក្នុងបក្សកុម្មុយនីស្តថៃ និងនៅពេលណានិងរបៀបណាទើបគាត់បានចូលរួមនៅក្នុង បក្សកុម្មុយនីស្តឥណ្ឌូចិននិងការតស៊ូប្រឆាំងនឹងបារាំង ។

នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០១សាជីវកម្មផ្សព្វផ្សាយអូស្ត្រាលីបានផ្សាយព័ត៌មានដែលមានចំណងជើងថា«អ្នកស៊ើបអង្កេតអំពើប្រល័យពូជសាសន៍នៅកម្ពុជាស្នើសុំឯកសារដែលថៃមាន» ដែលបានអត្ថាធិប្បាយថា ៖

អ្នកស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាកំពុងស្នើសុំសាកលវិទ្យាល័យថៃដែលប្រកបដោយកិត្យានុភាពខ្ពស់ឲ្យប្រគល់ឯកសាររបស់អ្នកដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលធ្លាប់បានសិក្សានៅទីនោះដោយនិយាយថា ឯកសារទាំងនោះអាចផ្ទុកនូវភ័ស្តុតាងសំខាន់សម្រាប់សាលាក្តីដែលគាំទ្រដោយអង្គការសហប្រជាជាតិ ។ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាលោក ឆាំង យុសរសេរលិខិតមួយច្បាប់ដោយជំរុញឲ្យសកលវិទ្យាល័យធម្មាសាធប្រគល់ឯកសារស្តីពី នួន ជា ជា«បងធំទីពីរ» ដែលមានតែស្រមោលតំណាងឲ្យជនផ្តាច់ការ ប៉ុល ពត ។

មន្ត្រីអង្គការសហប្រជាជាតិនិយាយថា បណ្ណសារដ្ឋានរបស់សកលវិទ្យាល័យនឹងក្លាយជាប្រភពឯកសារភ័ស្តុតាងសំខាន់សម្រាប់សាលាក្តី ។ អ្នកស៊ើបអង្កេតមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើ នួន ជា ដែលជាលេខាទីពីរនៃបក្សកុម្មុយនីស្តកម្ពុជានិងជាឧបនាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នួន ជា បានចូលសាលាច្បាប់នៃសកលវិទ្យាល័យធម្មាសាធដោយទទួលបានអាហារូបករណ៍សិក្សានៅទសវត្សរ៍ឆ្នាំ១៩៤០ ហើយក្រោយមកធ្វើការនៅក្រសួងការបរទេសថៃ ឥឡូវគាត់រស់នៅក្រុងប៉ៃលិននៅភាគពាយ័ព្យនៃប្រទេសដែលគាត់ធ្លាប់រស់នៅតាំងពីការតស៊ូរបស់ខ្មែរក្រហមបានបញ្ចប់ ។

របាយការណ៍ព័ត៌មានមិនបានចង្អុលបង្ហាញថាតើសកលវិទ្យាល័យធម្មាសាធបានឆ្លើយតបឬក៏អត់ទេប៉ុន្តែទោះបីសកលវិទ្យាល័យចង់ឆ្លើយតបក៏ដោយ កាលដែលមិនស្គាល់ឈ្មោះដែល នួន ជា បានប្រើក្នុងអំឡុងពេលរបស់គាត់នៅទីក្រុងបាងកកទំនងជាមិនអាចទៅរួចទេដើម្បីកំណត់អត្តសញ្ញាណ របស់គាត់ចេញពីក្នុងចំណោមនិស្សិតរាប់ពាន់នាក់ដែលបានចុះឈ្មោះនៅសកលវិទ្យាល័យក្នុងអំឡុងពេលដែលគាត់បានសិក្សានៅសកលវិទ្យាល័យធម្មាសាធ ។ លើសពីនេះទៀតដូចដែលបានចង្អុលបង្ហាញខាងក្រោមរហូតដល់ឆ្នាំ២០០១សូម្បីតែអតីតសមាជិកបក្សកុម្មុយនីស្តថៃដែលសកម្មជាមួយ នួន ជា ក្នុងអំឡុងពេលដែលគាត់នៅទីក្រុងបាងកកក៏មិនបានដឹងថាសមមិត្តបក្សចាស់របស់គាត់ដែលមកពីប្រទេសកម្ពុជាដែលការពិតគឺ នួន ជា ជាបងធំទីពីរនៃរបបខ្មែរក្រហមឡើយ ។ ចាប់ផ្តើមនៅខែកញ្ញា ឆ្នាំ២០០៣ អ្នកនិពន្ធរូបនេះបានជួបជាមួយអតីតសមាជិកបក្សកុម្មុយនីស្តថៃជាមនុស្សដែលអ្នកនិពន្ធបានឮពី នួន ជា ផ្ទាល់គឺជាសមមិត្តរបស់គាត់ ។ សមាជិកទាំងនេះជាអ្នកដែលបានដឹងច្រើនប៉ុន្តែត្រឹមតែថាសមមិត្តរបស់ខ្លួនដែលបានផ្ទេរពីបក្សកុម្មុយនីស្តថៃទៅបក្សកុម្មុយនីស្តឥណ្ឌូចិនហើយបន្ទាប់មកបានធ្វើដំណើរត្រឡប់ទៅប្រទេសកម្ពុជាគឺជាអ្នកដែលមានឈ្មោះ នួន ជា ។

រហូតមកដល់ពេលនេះនៅតែមិនទាន់មានព័ត៌មានទូលំទូលាយជាសាធារណៈស្តីអំពី នួន ជា ក្នុងអំឡុងពេលរបស់គាត់រស់នៅក្នុងទីក្រុងបាងកកដែលអាចយល់ពីការពិតដែលថា នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨ ការស្រាវជ្រាវតាមវេបសាយរបស់អ្នកនិពន្ធទៅលើឈ្មោះថៃរបស់ នួន ជា គឺ រុងលឺត ឡៅឌី ដោយប្រើអក្ខរាវិរុទ្ធថៃចេញលទ្ធផលច្រើនជាងមួយ ។ ទោះបីជាយ៉ាង

ណាក៏ដោយការស្រាវជ្រាវដោយប្រើការប្រកបជាអក្សរវ៉ូម៉ាំង វុងលី ឡៅឌី ដោយវាយនៅក្នុងអត្ថបទកាសែតបាងកកប៉ុស្តិ៍ ដោយអ្នកកាសែតថៃ នូ សាវ៉ា ដែលធ្លាប់ប្រមូលព័ត៌មានសន្ទឹកសន្ទាប់ទៅលើប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំ ។ ផ្អែកលើបទសម្ភាសន៍របស់អ្នកយកព័ត៌មានជាមួយ នួន ជា អត្ថបទនេះបានលេចឡើងនៅក្នុងកាសែតចេញផ្សាយ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០៦ ។ អ្នកយកព័តមានដដែលគូសបញ្ជាក់អំពីជីវិតរបស់ នួន ជា នៅក្នុងឯកសារចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០០៦ហើយដែលអាចរកបាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្វីដែល នូ សាវ៉ាបានពុពី នួន ជា និងអ្វីដែលអ្នកនិពន្ធនេះបានព្ នៅក្នុងបទសម្ភាសន៍របស់គាត់ជាមួយ នួន ជា គឺដូចគ្នា ។ ទោះបីជាយ៉ាងណាក៏ដោយ ឈ្មោះ នួន ជា ត្រូវបានប្រើនៅខណៈពេលរស់នៅក្នុងទីក្រុងបាងកកដែលគាត់មិនបានបកស្រាយការសម្ងាត់ឲ្យអ្នកនិពន្ធដឹងប៉ុន្តែគាត់បានប្រាប់ នូ សាវ៉ា ។ នៅក្នុងឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាគាត់ (នូ សាវ៉ា) សរសេរថា នួន ជា បានចូលសកលវិទ្យាល័យធម្មាសាធការពិតវគ្គត្រៀមរបស់សកលវិទ្យាល័យឲ្យកំណត់ត្រារបស់អ្នកនិពន្ធ នៅក្នុងឆ្នាំ ១៩៤៤ ដោយប្រើឈ្មោះថៃ រុងលឹត ឡៅឌី ។ បើគ្រាន់តែមើលមួយភ្លែតស្នាដៃរបស់ នូ សាវ៉ា លេចឡើងហួសពីអ្វីដែលមានពីមុនមកស្តីអំពី នួន ជា ប៉ុន្តែបើអានអត្ថបទរបស់គាត់ឲ្យដិតដល់ជាងនេះអត្ថបទនេះបង្ហាញថាគាត់គ្រាន់តែរាយការណ៍តែអ្វីដែល នួន ជា បានប្រាប់គាត់តែប៉ុណ្ណោះ ។ គាត់មិនបានពិនិត្យមើលទ្រឹស្តីឬឯកសារដើមផ្សេងៗទៀតឡើយ ហើយក៏មិនបានស្រាវជ្រាវរកអ្នកដែលសកម្មជាមួយ នួន ជា ក្នុងអំឡុងពេលដែលគាត់ស្នាក់នៅទីក្រុងបាងកកដើម្បីផ្ទៀងផ្ទាត់ជាមួយអ្វីដែល នួន ជា ប្រាប់គាត់ឡើយ ។ ជាងនេះទៅទៀត នូ សាវ៉ាមិនបានដឹងច្បាប់អំពីប្រវត្តិសាស្ត្រនយោបាយថៃនាពេលនោះទេ ហើយក៏មិនដឹងច្បាស់អំពីច្បាប់និយ័តកម្មចំពោះការជ្រើសរើសឲ្យចូលជាមន្ត្រីរដ្ឋាភិបាលដែលបណ្តាលឲ្យគាត់មានកំហុសជាក់ស្តែងនិងធ្វើឲ្យមានការបកស្រាយដែលប្រកបដោយភាពសង្ស័យ ។ ជាលទ្ធផលអ្វីដែលគាត់បានសរសេរអំពីជីវិតរបស់ នួន ជា នៅក្នុងទីក្រុងបាងកកខុសពីអ្វីដែលបានកើតឡើងជាក់ស្តែង ។

អ្នកនិពន្ធនេះបានទៅសួរសុខទុក្ខ នួន ជា នៅផ្ទះរបស់គាត់ក្នុងទីក្រុងប៉ៃលិននៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៣ ដែលនៅពេលនោះគាត់នៅជាមនុស្សមានសេរីភាពនៅឡើយហើយបានសម្ភាសគាត់ (នួន ជា) អស់រយៈពេល៣ម៉ោងនិង២០នាទី ។ នៅក្នុងបទសម្ភាសន៍ដែលធ្វើឡើងជាភាសាថៃ នួន ជា បានបដិសេធមិនបកស្រាយឈ្មោះដែលគាត់បានប្រើក្នុងអំឡុងពេលនៅទីក្រុងបាងកកប៉ុន្តែគាត់បញ្ជាក់ច្បាស់ដោយនិយាយថាសាលាមធ្យមសិក្សាដែលគាត់បានបញ្ចប់គឺជាសាលាដែលគ្រប់គ្រង ដោយរដ្ឋាភិបាលស្ថិតនៅក្នុងបរិវេណវត្តបិនចាម៉ាបូភិតឥឡូវគឺជាសាលាម៉ាថាយម (បិនចាម៉ាបូភិត) ហើយដែលគាត់បានបញ្ចប់វគ្គត្រៀមចូលសកលវិទ្យាល័យធម្មាសាធជំនាន់ទី៧ ។ គាត់ក៏បានលើកឡើងនូវឈ្មោះមនុស្ស៥នាក់ទៀតដែលជាសមាជិករបស់បក្សកុម្មុស្តថៃរួមមានសមាជិកម្នាក់មកពីកងរបស់បក្សដូចគ្នា ។

ផ្អែកលើព័ត៌មាននេះអ្នកនិពន្ធបានធ្វើការស្វែងរកនិងបានរកឃើញថា ឈ្មោះរបស់ នួន ជា នៅទីក្រុងបាងកកគឺ រុងលឹត



ប៉ុល ពត

ឡើវិញ ។ គាត់អាចរកឃើញឯកសាររបស់មនុស្សម្នាក់ដែលមានឈ្មោះនោះនៅម៉ាថាយម បិនចាម៉ាបូភីត និងសកលវិទ្យាល័យធម្មាសាធដែល នួន ជា បានសិក្សាកាលនៅពីក្មេងហើយនៅឯក្រសួងកិច្ចការបរទេសថៃជាកន្លែងដែលគាត់ធ្លាប់បានធ្វើការ ។ ក្នុងខណៈពេលធ្វើការស្រាវជ្រាវនេះអ្នកនិពន្ធក៏បានសម្ភាសជាមួយអតីតសមាជិកបក្សកុម្មុយនីស្តថៃមួយចំនួនដែល នួន ជា បានលើកឡើងនៅក្នុងបទសម្ភាសន៍របស់គាត់ ។

យោងតាមព័ត៌មានដែលទទួលបានមកពីការស្រាវជ្រាវខាងលើគោលបំណងនៃការសិក្សានេះ គឺដើម្បីតាមដានឲ្យបានលម្អិតតាមដែលអាចធ្វើទៅបាននូវជីវិតនិងសកម្មភាពនយោបាយរបស់ នួន ជា កាលពីនៅក្មេងដែលបានរស់នៅទីក្រុងបាងកកពីឆ្នាំ១៩៤២ដល់ឆ្នាំ១៩៥០ ។ ជាមួយនឹងការបញ្ជាក់ឲ្យបានច្បាស់អំពីចំណុចដែលមិនច្បាស់លាស់អំពីជីវប្រវត្តិរបស់គាត់ ។ ការសិក្សានេះនឹងពិនិត្យមើលទៅលើចលនាកុម្មុយនីស្តនៅក្នុងប្រទេសថៃនៅចុងទសវត្សរ៍ឆ្នាំ១៩៤០ អំឡុងពេលដែលចលនាកុម្មុយនីស្តពង្រីកខ្លួនលើសពីសមាជិកភាពសំខាន់របស់ចិននិងវៀតណាមហើយបានចាប់ផ្តើមជ្រើសរើសសមាជិក ក្នុងចំណោមបញ្ញវ័ន្តថៃនិងនិស្សិតសាកលវិទ្យាល័យ ។ នួន ជា គឺជានិស្សិតម្នាក់ដែលបានចូលរួមក្នុងសកម្មភាពដែលទទួលឥទ្ធិពលពីកុម្មុយនីស្តហើយនៅទីបញ្ចប់បានចូលរួមនៅក្នុងបក្សកុម្មុយនីស្តថៃ ។ មានការស្រាវជ្រាវតិចតួចស្តីពីបក្សកុម្មុយនីស្តថៃក្នុងអំឡុងពេលនេះ ។ ជាមួយនឹងការបកស្រាយឲ្យកាន់តែលម្អិតអំពីបុគ្គល នួន ជា ការសិក្សានេះក៏នឹងពិនិត្យមើលទៅលើចលនាបក្សកុម្មុយនីស្តថៃក្នុងអំឡុងពេលក្រោយសង្គ្រាមបន្តិចព្រមទាំងពិនិត្យមើលការចូលរួមរបស់ជនជាតិដែលមានការអប់រំខ្ពស់នៅក្នុងបក្សនេះ ។




## ១) បទសម្ភាសន៍ជាមួយ នួន ជា នៅទីក្រុងប៉ៃលិន

នៅព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៣ អ្នកនិពន្ធរួមជាមួយមនុស្សដែលមកពីសកលវិទ្យាល័យបីនាក់ទៀតបានចេញដំណើរពីខេត្តបាត់ដំបងទៅសួរសុខទុក្ខ នួន ជា នៅផ្ទះរបស់គាត់នៅតំបន់ប៉ៃលិន ភាគខាងលិចប្រទេសកម្ពុជាជិតព្រំដែនថៃ ។ ផ្ទះរបស់គាត់ស្ថិតនៅជិតផ្ទះ ខៀវ សំផន ។ សង់អំពីឈើជាមួយដំបូលស័ង្កសីនិងបន្ទប់ពីលើជើងតាងជាផ្ទះដែលមានទំហំមធ្យមរួមជាមួយបន្ទប់ខាងមុខមួយនិងបន្ទប់គេងពីរ ។ អង់តែនទូរទស្សន៍ខ្ពស់មួយបញ្ឈរក្បែរជណ្តើរនៅផ្លូវចូលផ្ទះ ។ មិនមានឆ្មាំនិងសន្តិសុខត្រូវបានរក្សាឡើយ ។ ផ្ទះនោះសាមញ្ញដែលជាផ្ទះក្នុងភូមិបែបបុរាណសប់សាត់មួយ ។ នួន ជា រស់នៅជាមួយប្រពន្ធនិងកូន ៗរបស់គាត់ព្រមទាំងប្តីប្រពន្ធរបស់កូនគាត់ ។ ក្រុមគ្រួសាររបស់គាត់ដាំពោតនិងល្ង ហើយពួកគាត់បានជួលដីពីកូនប្រុសរបស់ អៀង សារី (ឧបនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីការបរទេសក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ) ។ កូនប្រុសរបស់គាត់ (អៀង សារី) គឺជាមនុស្សមានឥទ្ធិពលនៅទីក្រុងប៉ៃលិន ។

ខណៈពេលដែលអ្នកនិពន្ធទៅធ្វើទស្សនកិច្ច នួន ជា នៅផ្ទះជាមួយប្រពន្ធរបស់គាត់និងចៅរបស់គាត់អាយុ១ឆ្នាំ ។ មនុស្សម្នាក់ក្នុងចំណោមមនុស្សជាច្រើនដែលបានអមដំណើរអ្នកនិពន្ធគឺជានិស្សិតខ្មែរ ឈ្មោះ អួន ភ័ក្ត្រគីនី ដែលជានិស្សិតឆ្នាំទី២ថ្នាក់អនុបណ្ឌិតនៅឯសកលវិទ្យាល័យវ៉ាសេដានៃសាលាការសិក្សាអំពីអាស៊ីប៉ាស៊ីហ្វិក ។ នាងបានណែនាំភ្ញៀវម្នាក់ៗក្នុង

សម្ដីជាភាសាខ្មែរ ។ ដោយសារម្នាក់ៗនៅក្នុងក្រុមអាចនិយាយភាសាថៃការសន្ទនាក៏បានបន្តក្នុងភាសាថៃ ។ ភាសាថៃរបស់ នួន ជា មានលក្ខណៈខុសពីភាសាថៃរបស់ជនជាតិថៃ ។ អ្នកអាចរំពឹងគិតពីចំណុចនេះដោយពិចារណាថាគាត់បានទទួលការអប់រំថ្នាក់មធ្យមនិងឧត្ដមនៅទីក្រុងបាងកក ហើយខណៈពេលគាត់ជានិស្សិតនៅសកលវិទ្យាល័យសម្មាសាធ គាត់បានបម្រើការងារអស់រយៈពេលជាង៣ឆ្នាំជាមន្ត្រីម្នាក់នៅក្នុងរដ្ឋាបាលប្រទេសថៃ ។ ទោះបីជាយ៉ាងណាក៏ដោយទាំងអស់នេះគឺបានកើតឡើងជាងពាក់កណ្ដាលទសវត្សរ៍មុនម៉្លេះហើយយោងតាម នួន ជា បន្ទាប់ពីគាត់បានចូលរួមការតស៊ូនៅប្រទេសកម្ពុជានៅឆ្នាំ១៩៥០ ការជាប់ពាក់ព័ន្ធរបស់គាត់ជាមួយបក្សកុម្មុយនីស្ដថៃក៏បានបញ្ឈប់ហើយគាត់កម្រមានការប្រើប្រាស់ភាសាថៃណាស់ ។ ថ្វីបើដូច្នេះក្ដីគាត់មិនបានភ្លេចភាសានេះឡើយពីព្រោះ នួន ជា បាននិយាយថាចាប់តាំងពីរស់នៅទីក្រុងប៉ៃលិន គាត់អានសៀវភៅថៃហើយស្ដាប់វិទ្យុថៃ ។ គាត់ក៏បានធ្វើដំណើរទៅប្រទេសថៃរៀងរាល់៦ខែម្ដងឬលើសពីនេះដើម្បីទៅគ្លីនិកនៅចាន់ថាបូរីក្នុងការពិនិត្យជំងឺបេះដូងនិងសរសៃឈាម ក្នុងខួរក្បាលនិងជំងឺផ្សេងៗទៀត ។ ក្នុងអំឡុងពេលទាំងនោះគាត់បាននិយាយថាគាត់បានទិញសៀវភៅជាភាសាថៃស្ដីពីព្រះពុទ្ធសាសនាដែលគាត់បាននាំយកមកផ្ទះដើម្បីអាន ។ កំពុងតែនិយាយដូច្នេះ នួន ជា បានចូលបន្ទប់គេងរបស់គាត់ហើយនាំយកសៀវភៅដែលសរសេរដោយអាចារ្យខាងព្រះពុទ្ធសាសនាថៃល្បីល្បាញ ដូចជា ពុទ្ធដាសា ភិក្ខុ, *P.A* ។ ប៉ាយុទ្ទោ ភិក្ខុ និង ប៉ាន់យ៉ាណានដា ភិក្ខុ ។ នៅខាងមុខបន្ទប់របស់គាត់បានព្យួររូបថតរបស់សម្ដេចសង្ឃរាជ ប្រា យ៉ាណាសង់វ៉ន ។

៦ថ្ងៃបន្ទាប់ពីការសម្ភាសន៍ជាមួយ នួន ជា អ្នកនិពន្ធបានជួបជាមួយ យុ ឆាំង នៅមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងទីក្រុងភ្នំពេញ ។ យោងទៅតាម លោក ឆាង យុ, នួន ជា មានភាពប្រយ័ត្នប្រយែងមិនទុកចិត្តហើយការពារខ្លួននៅពេលត្រូវបានសម្ភាសដោយជនជាតិខ្មែរប៉ុន្ដែគាត់និយាយច្រើនជាមួយជនជាតិបរទេស ។ ជាពិសេសនៅពេលសួរជាភាសាថៃគាត់បង្ហាញការរំភើបខ្លាំងហើយចង់និយាយលម្អិតអំពីខ្លួនគាត់ ។ នួន ជា ពិតជានិយាយច្រើនក្នុងអំឡុងពេលសម្ភាសន៍នៅផ្ទះរបស់គាត់ ។ ពេលនោះប្រហែលជាត្រូវអរគុណចំពោះភាសាថៃ ។

## សេចក្ដីសង្ខេបនៃបទសម្ភាសន៍

នួន ជា បានចាប់ផ្ដើមបទសម្ភាសន៍ដោយនិយាយថាគាត់កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩២៦ នៅក្រុងបាត់ដំបង(ខេត្តរបស់កម្ពុជាមានឈ្មោះដូចគ្នាដែរ) នៅជិតវត្តគរ ។ ឪពុករបស់គាត់គឺជាអ្នកជួញដូរប្រកបរបរដាំពោតហើយពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មគ្រប់ប្រភេទ ចំណែកម្ដាយរបស់គាត់ដេរនិងធ្វើការងារស្រដៀងគ្នានេះ ។ គាត់បានចាប់ផ្ដើមចូលរៀននៅពេលគាត់អាយុបាន៧ឆ្នាំហើយក្នុងនាមជាក្មេងម្នាក់ដែលគ្មានបទពិសោធន៍ធ្វើការងារស្រែចម្ការ ។ គាត់បានរៀនភាសាបារាំងនៅឯសាលារៀន ។ នៅខេត្តបាត់ដំបងគាត់ក៏បានរៀនភាសាថៃហើយយោងតាមគាត់ភាសាថៃគឺជាភាសាដែលងាយស្រួលរៀនសម្រាប់ប្រជាជនកម្ពុជា ។ មុនពេលសង្គ្រាមលោកលើកទី១ក្រុមគ្រួសាររបស់គាត់ធូរធារផ្នែកសេដ្ឋកិច្ចប៉ុន្ដែក្នុងអំឡុងពេលសេដ្ឋកិច្ចធ្លាក់ចុះបន្ទាប់ពីសង្គ្រាមគ្រួសាររបស់គាត់បានជំពាក់បំណុលគេហើយស្ថានភាពរស់នៅបានធ្លាក់ចុះ ។ ជីតាបង្កើតរបស់គាត់គឺជាចិនទាជីវមកពីស្វាទូ(ស្វាតូ) ប្រទេសចិនចំណែកជីដូនបង្កើតរបស់គាត់គឺជាជនជាតិខ្មែរ ។ ត្រកូលរបស់ឪពុកគាត់គឺឡាវ ។ នៅពេលបុណ្យចូលឆ្នាំសំពះព្រះខែហើយនៅពេលបុណ្យឆេងម៉េង ឪពុករបស់គាត់បន់ស្រន់របៀបចិនដល់ដូនតារបស់គាត់ គាត់ក៏បានគោរពចំពោះ ស៊ុន យ៉ាតសេន ។ ប៉ុន្ដែឪពុកម្ដាយរបស់គាត់ក៏បានគោរពបូជានៅវត្តព្រះពុទ្ធដែរ ។ ទោះបីជាមានខ្សែចិន នួន ជា រៀនភាសាចិនបានតិចតួច ។ ប្រពន្ធរបស់គាត់ក៏មានខ្សែចិនដែរហើយកើតនិងធំធាត់នៅក្នុងគ្រួសារអ្នកស្រែនៅខេត្តកំពង់ឆ្នាំង ។ ពួកគាត់មានកូន៤នាក់និងចៅជាង១០នាក់ ។

នៅឆ្នាំ១៩៤១ នៅពេលប្រទេសថៃគ្រប់គ្រងខេត្តបាត់ដំបងនិងខេត្តសៀមរាបគាត់នៅក្មេងនៅឡើយហើយមិនចាប់អារម្មណ៍អំពីហេតុការណ៍នោះឡើយ ។ ទោះបីគាត់មានសញ្ជាតិខ្មែរនិងជាជនជាតិខ្មែរក៏ដោយហេតុការណ៍នោះបានធ្វើឲ្យគាត់ ក្លាយជាពលរដ្ឋថៃហើយក្លាយជាចំណែកមួយរបស់ជនជាតិថៃ ។ ក្រោយមកនៅឆ្នាំ១៩៤១នៅពេលកងទ័ពជប៉ុនផ្លាស់ចូលមកឥណ្ឌូចិនភាគខាងត្បូងបន្ទាប់មកចូលក្នុងប្រទេសថៃ កងទ័ពជប៉ុន

បោះទីតាំងនៅវត្តគរជាវត្តមួយនៅក្បែរផ្ទះរបស់គាត់ដើម្បី ការពារស្ពានដែកដែលនៅក្បែរនោះ នៅលើខ្សែរថភ្លើងធ្វើដំណើរមកពីភ្នំពេញទៅបាត់ដំបង ។ គាត់គ្មានអារម្មណ៍ស្អប់កងទ័ពជប៉ុនឡើយ ។ គាត់មានអារម្មណ៍ស្អប់បារាំងយ៉ាងខ្លាំងដូច្នេះហើយគាត់គ្មានហេតុផលអ្វីដែលត្រូវស្អប់ជប៉ុនដែលបង្ក្រាបបារាំងឡើយ ។ ក្រៅពីនេះគាត់បានឮថាជប៉ុនបានជួយអ្នកស្នេហាជាតិកម្ពុជា ។ ទោះបីយ៉ាងណាក៏ដោយ នៅពេលនោះ គាត់នៅក្មេងនៅឡើយ នៅពេលរស់នៅខេត្តបាត់ដំបងហើយមិនបានដឹងច្បាស់លាស់ក្នុងការប្រឆាំងនឹងបារាំងឡើយ ។ គាត់មិនទាន់មានការភ្ញាក់រឭកខាងនយោបាយទេ ។ ការភ្ញាក់រឭកនេះបានកើតឡើងក្រោយមកទៀត ហើយរីកចម្រើនបន្តិចម្តងៗ ។ ប៉ុន្តែ នៅទីបំផុតគាត់បានដឹងថាសង្គមរបស់អាណានិគមនិយមបារាំងមានវណ្ណៈមន្ត្រីខ្មែរថ្នាក់មូលដ្ឋានជាច្រើននាក់ដែលត្រូវបានពង្រឹងដោយបារាំង ហើយធ្វើការសង្កត់សង្កិនទៅលើប្រជាជនកម្ពុជាក្នុងការទារពន្ធអាករនិងការរឹបអូសយករបស់ផ្សេងៗទៀតតាមទាមទាររបស់បារាំង ។ រដ្ឋាភិបាលអាណានិគមបានត្រួតត្រាលើការលក់ស្រាហើយផ្តល់ភាពស្របច្បាប់ទៅលើការលក់អាភៀនក្នុងការគេងយកចំណេញដើម្បីបំពេញការលោភលន់របស់ខ្លួន ។

នៅឆ្នាំ១៩៤២ គាត់បានបញ្ចប់ឆ្នាំទី៤នៅសាលាមធ្យមសិក្សា ។ បន្ទាប់មកគាត់បានចាកចេញទៅកាន់ទីក្រុងបាងកក ។ នៅពេលនោះគាត់បាននិយាយថាគាត់មកជាមួយនឹងចំណាប់អារម្មណ៍មិនច្បាស់លាស់នូវអ្វីដែលហៅថាប្រទេសឯករាជ្យ ។ បន្ទាប់ពីមកដល់ទីក្រុងបាងកក គាត់ភ្ញាក់ផ្អើលដោយឃើញថាមានជនជាតិចិនជាច្រើនទោះបីប្រទេសថៃជាប្រទេឯករាជ្យ ។ ពាណិជ្ជកម្មរបស់ប្រទេសថៃត្រូវបានគ្រប់គ្រងដោយជនជាតិចិនហើយមានជនជាតិថៃតិចតួចប៉ុណ្ណោះដែលប្រកបអាជីវកម្ម ។ ទោះបីជាយ៉ាងណាក៏ដោយគាត់បានឃើញថា ជនជាតិថៃនិងជនជាតិចិនរួមរស់នៅជាមួយគ្នា ។ នៅប្រទេសកម្ពុជាជនជាតិខ្មែរនិងជនជាតិចិនក៏រួមរស់នៅជាមួយគ្នាដែរប៉ុន្តែជនជាតិខ្មែរនិងជនជាតិវៀតណាមមានការប្រឆាំងគ្នា ។

នៅទីក្រុងបាងកកមានអាចារ្យខ្មែរបីនាក់នៅវត្តបិនចាម៉ាបូភីតដែលមកពីខេត្តបាត់ដំបងហើយអាចារ្យទាំងនោះថែរក្សា នួនជា ។ គាត់រស់នៅទីស្នាក់ការរបស់អាចារ្យទាំងនោះហើយបានចាប់ផ្តើមចូលរៀននៅសាលាវត្តបិនចាម៉ាបូភីត ជាសិស្សថ្នាក់មធ្យមឆ្នាំទី៥ ។ ឪពុករបស់គាត់បានចំណាយថ្លៃឈ្នួលសាលាឲ្យគាត់និងចំណាយក្នុងការរស់នៅទីក្រុងបាងកក ។ គាត់អាចរស់នៅបានដោយចំណាយអស់តិចជាងអ្វីដែលឪពុករបស់គាត់បានផ្ញើឲ្យគាត់ដូច្នេះគាត់គ្មានបញ្ហាខាងហិរញ្ញវត្ថុឡើយ ។ នៅពេលបញ្ចប់ការសិក្សាឆ្នាំទី៦នៃសាលាមធ្យមសិក្សា គាត់បានចុះឈ្មោះនៅថ្នាក់ទី៧នៃវគ្គត្រៀមនៅសកលវិទ្យាល័យធម្មាសាធ ។ ទោះបីជាយ៉ាងណាក៏ដោយថ្នាក់រៀនធម្មតាមិនត្រូវបានធ្វើឡើងដោយសារសង្គ្រាម ។ គាត់បានបញ្ជូនការងារសាលារបស់គាត់តាមប្រៃសណីយ៍ហើយគ្រាន់តែមកប្រឡងនៅសកលវិទ្យាល័យ ។ ក្នុងអំឡុងពេលគាត់នៅប្រទេសថៃគាត់បានប្រើឈ្មោះផ្សេងហើយប្រើឈ្មោះបច្ចុប្បន្នក្នុងអំឡុងពេលតស៊ូនៅប្រទេសកម្ពុជា ។ ទោះបីជាងយ៉ាងណាក៏ដោយគាត់បាននិយាយថា គាត់មិនអាចបង្ហាញអ្នកនិពន្ធនូវឈ្មោះរបស់គាត់ដែលបានប្រើនៅប្រទេសថៃបានឡើយ ។ ទោះបីជាគាត់បានចុះឈ្មោះចូលរៀនវគ្គត្រៀមគាត់មិនមានកាសនិយាយជាមួយនាយកសកលវិទ្យាល័យ ព្រីឌី ផានុមយ៉ុង ។ នោះដោយសារគាត់នៅក្មេងហើយគ្រាន់តែជាសិស្សម្នាក់នៅទីនោះហើយដោយសារគាត់មិនបានចូលរួមក្នុងសកម្មភាពប្រឆាំងនឹងជប៉ុនរបស់ថៃសេរីដែលព្រីឌីបានដឹកនាំ ។

ក្នុងអំឡុងពេលនោះ មហាជន ដែលជាអង្គភាពផ្សព្វការរបស់បក្សកុម្មុយនីស្តថៃត្រូវបានបោះពុម្ពជាសាធារណៈហើយចុះផ្សាយអត្ថបទស្តីពីការតស៊ូដើម្បីរំដោះពីអាណានិគម ។ គាត់ចូលចិត្តអានមហាជនហើយគាត់បានធ្វើទស្សនកិច្ចការិយាល័យបោះពុម្ពផ្សាយ នៅជិតសាណាមហ្លួងដែលគាត់បានជិទាស់យោបល់ជាមួយ ឧត្តម ស៊ីសុវ៉ាន ហើយអ្នកមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តដទៃទៀតស្តីពីការតស៊ូប្រឆាំងនឹងបារាំងនិងបញ្ហាផ្សេងទៀត ។ ពីដំបូងគាត់មិនបានដឹងថា មហាជន គឺជាការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តឡើយ ប៉ុន្តែអត្ថបទរបស់ការចេញផ្សាយនេះគឺជាទំនាក់ទំនងដំបូងរបស់គាត់ជាមួយបក្សកុម្មុយនីស្តថៃ ។ គាត់អានអត្ថបទ មហាជន ក្នុងអំឡុងពេលដែល មហាជន ចេញផ្សាយជាសាធារណៈមុនពេលនោះគឺនៅពេលដែលមហាជនបោះពុម្ព

ដោយសម្ងាត់គាត់បាននិយាយថា គាត់មិនបានអានអត្ថបទរបស់ មហាជនឡើយ ។ នៅពេលគាត់ចាប់ផ្ដើមអាន មហាជន គាត់ចាប់ផ្ដើមមានការសង្ស័យថា ហេតុអ្វីបានជាគាត់មកសិក្សានៅសកលវិទ្យាល័យធម្មាសាធ ។ គាត់បានចាប់ផ្ដើមឆ្ងល់ថាតើ គាត់កំពុងរៀនដើម្បីអ្វីហើយគិតថាជាជាងការបម្រើប្រទេសជាតិការសិក្សារបស់គាត់នឹងបម្រើឲ្យពួកវណ្ណៈកាន់អំណាចតែប៉ុណ្ណោះ ។ ប្រសិនបើគាត់រៀនចប់ពីសកលវិទ្យាល័យហើយចៃដន្យត្រូវបានប្រគល់តំណែងនៅកន្លែងណាមួយឲ្យធ្វើជាចៅហ្វាយស្រុកវាហាក់ដូចជាថាតំណែងនោះនឹងបម្រើឲ្យវណ្ណៈកាន់អំណាចព្រមទាំងសម្រាប់តែការគាបសង្កត់ទៅលើប្រជាជនតែប៉ុណ្ណោះ ។ ប្រសិនបើគាត់ក្លាយជាមេធាវីវិញនោះគាត់នឹងការពារប្រជាជនដោយសារតែលុយកាក់ ។ ការគិតបែបនេះហើយទើបនាំឲ្យមានការបោទស្សរចុះឡើងនៅក្នុងខ្លួនគាត់ ។

ភាពស្អប់ខ្ពើមដែលចាប់ផ្ដើមមាននៅក្នុងអារម្មណ៍របស់គាត់នាពេលនោះចំពោះភាពអយុត្តិធម៌និងភាពមិនស្មោះត្រង់នៅក្នុងសង្គមបែបនោះទើបធ្វើគាត់គិតមើលអំពីការចូលបួសជាព្រះសង្ឃក្នុងជីវិតរបស់គាត់ហើយគាត់នៅចាំបានថាមានពេលមួយកាលពីគាត់នៅក្មេងក្នុងខណៈពេលដែលគាត់បានឃើញការបូជាសពនៅឈាបនដ្ឋានមួយ គាត់បាននិយាយទៅកាន់ជីដូនរបស់គាត់(ជីដូនខាងម្ដាយ) ថាគាត់ចង់ក្លាយជាព្រះសង្ឃក៏ប៉ុន្តែការគិតបែបនោះក៏លែងមានទៅវិញនៅពេលជីដូនរបស់គាត់បានប្រាប់គាត់ថាគាត់នៅក្មេងពេកក្នុងអំឡុងពេលគាត់រស់នៅវត្តបិនចាម៉ាបូភីតគាត់តែងតែស្ដាប់ធម៌ទេសនារបស់ព្រះសង្ឃម្ដងក្នុងមួយសប្ដាហ៍ ។

មុនពេលសង្គ្រាមដុតរលត់ទៅគឺនៅក្នុងពុទ្ធសករាជ ២៤៨៧/ឆ្នាំ(១៩៤៤) ដែលនៅពេលនោះ នួន ជា បាននិយាយថាគាត់បានចូលរួមក្នុងអង្គការយុវជនថៃដែលគាត់បាននិយាយថាជាអង្គការមួយដែលស្ថិតនៅក្រោមបក្សកុម្មុយនីស្ត ។ គាត់បានចូលតាមការអញ្ជើញរបស់រួម វង់ផាន ជានាយកសាលាចិនដែលស្ថិតនៅក្បែរណាងលីង នៅក្នុងទីក្រុងបាងកកនាពេលនោះ ។ អ្នកទាំងពីរបានរស់នៅជាមួយគ្នានៅក្នុងបន្ទប់ជួលមួយ ។ នៅត្រង់កន្លែងនេះ នួន ជា និយាយខុសប្រធានបទត្រង់កន្លែងថាជាច្រើនឆ្នាំក្រោយមកនៅពេលដែលគាត់ទៅទស្សនកិច្ចស្ថានទូតសូវៀតនៅទីក្រុងភ្នំពេញគាត់មានការភ្ញាក់ផ្អើលដោយឃើញអត្ថបទមួយនៅក្នុងទស្សនាវដ្ដីសូវៀតសរសេរជាភាសាបារាំងដែលសរសេរថារួមត្រូវបានកាត់ទោសប្រហារជីវិតនៅក្នុងទីក្រុងបាងកកឲ្យនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៦២ ពីបទជាប់ពាក់ព័ន្ធក្នុងសកម្មភាពកុម្មុយនីស្តដែលជាបទឧក្រិដ្ឋនៅក្នុងប្រទេសថៃ ។

យោងទៅតាម នួន ជា អង្គការយុវជនថៃគឺជាកន្លែងដែលបុរសនិងស្ត្រីក្មេងៗដ៏ក្លៀវក្លាបានប្រមូលផ្ដុំគ្នាដើម្បីធ្វើសកម្មភាពសង្គមការជួយគ្នាទៅវិញទៅមក ព្រមទាំងធ្វើការផ្លាស់ប្ដូរទស្សនៈយោបល់ ។ នៅថ្ងៃទី១ ខែឧសភា អ្នកទាំងអស់នេះបានចូលរួមនៅក្នុងទិវាខែឧសភា ។ នៅពេលដែលសង្គ្រាមកូរ៉េបានផ្ទុះឡើង នួន ជា បាននិយាយថាគាត់បានធ្វើការដើម្បីចលនាសន្តិភាពប្រឆាំងនឹងការឈ្លានពានរបស់អាមេរិក ។ គិតមកត្រឹមពេលនោះគាត់បានក្លាយទៅជាសមាជិកបក្សកុម្មុយនីស្ត ។

ជនជាតិថៃមួយចំនួននៅក្នុងអង្គការយុវជនដែលគាត់នៅចាំបានពីសកម្មភាពដ៏ក្លៀវក្លានោះមាន ដូចជា និត ផុងដាផេតដែលជាក្មេងស្រីរាងទាបមានខ្សែស្រឡាយចិន និងសាណុះ ដានិចារិនជាបុរសប្រកបដោយភាពខ្ពង់ខ្ពស់បន្តិចដែលរស់នៅប្រទេសចិនអស់រយៈពេលជាយូរ ហើយដែល នួន ជា បានធ្វើអត្ថាធិប្បាយមិនត្រូវបានប្រទ្បាំជាមួយគ្រូបង្រៀននៅសកលវិទ្យាល័យជូឡាឡុងកន ឈ្មោះ សាណុះ តាំប៊ុនយុម ឲ្យដែលនឹងលេចឡើងក្រោយមកនៅក្នុងការសិក្សានេះ ។ អ្នកដទៃទៀតដែលសកម្មគឺរីងមេឃ ដៃបុល ដែល នួន បានចាំថាគាត់មានពុកមាត់មុនពេលរដ្ឋប្រហារនៅខែវិច្ឆិកា ឆ្នាំ១៩៤៧ ព្រមទាំង ឡាមចៀក សាបសុនថុន ដែលជាប្អូនស្រីរបស់ ប្រាសិទ្ធិ សាបសុនថុន ឲ្យបញ្ញាវ័ន្តកុម្មុយនីស្តនិងជាអ្នកនិពន្ធ ។ សមាជិកអង្គការយុវជនថៃបានដឹង នួន ជា មកពីខេត្តបាត់ដំបងហើយពួកគេនិយាយជាមួយគាត់អំពីទុក្ខព្រួយរបស់ប្រជាជនដែលរស់នៅក្រោមនឹមអាណានិគមនិយមបារាំង ។

ក្រៅពីអានមហាជនជាប្រចាំ នួន ជា បាននិយាយថាគាត់ក៏បានអានព្រឹត្តប័ត្រដែលមានឈ្មោះថា «ផ្លូវចេញ» របស់ថៃដែលរៀបចំដោយ ឧត្តម ស៊ីសុវ៉ាន ឲ្យ(ថាង អួក ខុងថៃ) ដែលជាការ

បកប្រែជាភាសាថៃថាសេចក្តីថ្លែងការបស់កុម្មុយនីស្តនិងទស្សនៈស្តីពីជីវិតនិពន្ធដោយ ប្រាសិទ្ធី សាបសុនថុន ។ គាត់មិនយល់ស្រប នូវចំណុចជាច្រើននៅក្នុងស្នាដៃចុងក្រោយរបស់អ្នកនិពន្ធនេះ ។ គាត់ក៏បានអានកាសែតសៀងថៃអភិវឌ្ឍន៍ ។

បើនិយាយអំពីចលនាខ្មែរឥស្សរៈនៅពេលដែលគាត់នៅក្នុងទីក្រុងបាងកក នួន ជា បាននិយាយថាចលនានេះត្រូវបានបែងចែកជាច្រើនក្រុមហើយមិនអនុវត្តគោលនយោបាយត្រឹមត្រូវទេ ។ ក្រុមមួយចំនួនបានប្រើឈ្មោះចលនានេះដើម្បីបង្កើនផលប្រយោជន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ គាត់បានជួបមេដឹកនាំខ្មែរឥស្សរៈដែលស្គាល់ឈ្មោះថាជា ប៉ុក ឃុន នៅក្នុងប្រទេសថៃ ក៏ប៉ុន្តែបុរសនេះធ្វើឲ្យគាត់យល់ឃើញថាជាមនុស្សដែលគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះប្រសិនបើមានឱកាស ។ តាមទស្សនៈរបស់ នួន ជា យល់ថាហេតុផលដែលក្រុមខ្មែរឥស្សរៈទាំងអស់នេះគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួនជាធំនោះគឺដោយសារតែអនិកជនខ្មែរនៅប្រទេសថៃដែលរស់នៅក្នុងខេត្តសុរិន្ទនិងខេត្តបុរីរាំមនសិការជាតិជាជនជាតិខ្មែរគឺមានភាពខ្សោយណាស់ ហើយពួកគេមិនគិតអំពីអ្វីដែលកំពុងកើតឡើងនៅក្នុងប្រទេសកម្ពុជាទេ ។ នៅក្នុងទីក្រុងបាងកកចំនួនប្រជាជនកម្ពុជាមានតិច ហើយអ្នកទាំងអស់នោះនិយាយភាសាថៃ ។ គាត់ប្រៀបធៀបចំណុចទាំងអស់ជាមួយនឹងបទពិសោធន៍បន្តបន្ទាប់របស់គាត់នៅក្នុងប្រទេសវៀតណាម ដែលមនសិការជាជនជាតិខ្មែរក្នុងចំណោមប្រជាជនកម្ពុជាដែលរស់នៅក្នុងប្រទេសនោះគឺមានភាពជ្រាលជ្រៅក្រៃលែង ។

ក្នុងអំឡុងពេលរស់នៅប្រទេសថៃអន្តភាពវៀតមិញជាច្រើននៅខាងភាគីថៃដែលជាប់ព្រំដែនជាមួយឥណ្ឌូចិន ។ គាត់គិតថាពួកគេជាអន្តភាពប្រកបដោយសមត្ថភាពខ្ពស់ក៏ប៉ុន្តែនៅពេលនោះគាត់គ្មានទំនាក់ទំនងជាមួយពួកវៀតមិញទេ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក្នុងនាមជានិស្សិតមួយរូបគាត់បានធ្វើដំណើរទៅសុរិន្ទដើម្បីអង្កេតមើលសកម្មភាពខ្មែរឥស្សរៈ ។

ក្នុងអំឡុងពេលនៅក្នុងទីក្រុងបាងកក នួន ជា បាននិយាយថាពូរបស់គាត់ឈ្មោះ ស៊ីវ ហេង ជាប្តីរបស់មីងគាត់(ប្អូនស្រីខាងម្តាយគាត់) ហើយដែលមកពីភាគខាងត្បូងនៃប្រទេសកម្ពុជាមានសកម្មភាពកៀរគ្នាជាមួយខ្មែរឥស្សរៈនៅខេត្តសុរិន្ទភាគពាយ័ព្យនៃប្រទេសថៃ ។ គាត់បានធ្វើដំណើរចូលទីក្រុងបាងកកដើម្បីផ្គត់ផ្គង់ស្បៀងជាច្រើនលើកច្រើនសារ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយយោងទៅតាម នួន ជា ពូរបស់គាត់ម្នាក់នេះមិនបានណែនាំឲ្យគាត់ចូលទៅក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិនទេ ហើយក៏មិនបានណែនាំឲ្យស្គាល់សាស្ត្រាចារ្យ ត្រាន វ៉ាន អ៊ាវជាមេដឹកនាំវៀតណាម ដែលរស់នៅទីក្រុងបាងកកនា ពេលនោះដែរ ។ អ៊ាវ ជាមិត្តភក្តិរបស់ ព្រីឌី ផាណុមយុង ហើយ នួន ជា បាននិយាយថាគាត់បានស្គាល់ឈ្មោះមនុស្សម្នាក់នេះក៏ប៉ុន្តែមិនដែលជួបមុខទេ ។

ក្នុងខណៈជានិស្សិតសិក្សានៅសកលវិទ្យាល័យធម្មាសាធឡ្យ ដែលគាត់ចូលរៀននៅក្នុង ខែឧសភា ឆ្នាំ១៩៤៦បន្ទាប់ពីបញ្ចប់វគ្គត្រៀម នួន ជា បាននិយាយថាគាត់ក៏បានបម្រើការអស់រយៈពេល៣ឆ្នាំជាមន្ត្រីរដ្ឋាភិបាលធម្មតាម្នាក់នៅក្នុងនាយកដ្ឋានជម្រះបញ្ជីទូទៅរបស់ក្រសួងហិរញ្ញវត្ថុថៃ ។ គាត់បានក្លាយទៅជាមនុស្សម្នាក់ដែលស្តាប់ការបង្រៀននៅសកលវិទ្យាល័យធម្មាសាធនាពេលព្រឹកហើយទៅការិយាល័យរបស់គាត់នៅក្រសួងហិរញ្ញវត្ថុ ។ នៅឆ្នាំ១៩៥០ខណៈពេលកំពុងធ្វើការនៅក្រសួងគាត់បានក្លាយជាសមាជិករបស់បក្សកុម្មុយនីស្តថៃ ។ មុនពេលចូលរួមគាត់បានឆ្លងកាត់រយៈពេល៦ខែជាបេក្ខភាព ។ មុនពេលនោះ នួន ជា បាននិយាយថាគាត់មាន សកម្មភាពអស់រយៈពេល៤ឆ្នាំនៅក្នុងអង្គការយុវជនថៃដែលគាត់បាននិយាយម្តងទៀតថាអង្គការនេះស្ថិតនៅក្រោមបក្សកុម្មុយនីស្តថៃ ។ កោសិការបស់បក្សដែលគាត់ជាប់ពាក់ព័ន្ធគឺជាកោសិកាមួយរបស់មន្ត្រីរដ្ឋាភិបាលហើយរួមមានសមាជិក៣រូបរួមទាំងខ្លួនគាត់ដែលធ្វើការនៅនាយកដ្ឋានជម្រះបញ្ជីទូទៅ ។ គាត់នៅចាំថា ឈ្មោះមនុស្សម្នាក់នៅក្នុងចំណោមសមាជិកគឺ ឧត្តម ។ គាត់គឺជាអ្នកដែលហៅ នួន ជា ឲ្យចូលក្នុងបក្សកុម្មុយនីស្តថៃប៉ុន្តែមនុស្សម្នាក់នេះគឺជាមនុស្សផ្សេងពីឈ្មោះឧត្តម ស៊ីសុវ៉ាន ។ នួន ជា មិនអាចចាំបាននូវឈ្មោះរបស់សមាជិកផ្សេងៗទៀតទេ ។ តាមអ្វីដែលគាត់បានដឹងគាត់គឺជាជនជាតិខ្មែរតែម្នាក់គត់នៅក្នុងបក្សកុម្មុយនីស្តថៃ ។

នៅឆ្នាំ១៩៥០ ពេលធ្វើការនៅក្រសួងហិរញ្ញវត្ថុការ

ប្រឡងមួយត្រូវបានធ្វើឡើងក្នុងការជ្រើសរើសបុគ្គលិកឲ្យទៅធ្វើការនៅក្រសួងការបរទេសថៃហើយគាត់ក៏បានប្រឡងជាប់ ។ ហេតុផលរបស់គាត់ដែលចូលប្រឡងនោះគឺដោយសារការងាររបស់គាត់នៅក្រសួងហិរញ្ញវត្ថុគឺគិតតែពីចំនួនតួលេខតែប៉ុណ្ណោះ ហើយគាត់មិនមើលឃើញអនាគតក្នុងកិច្ចការនេះទេ ។ គាត់ចង់ក្លាយជាអ្នកការទូត ។ បន្ទាប់ពីផ្លាស់ទៅធ្វើការនៅក្រសួងការបរទេសគាត់ត្រូវបានគេដាក់នៅក្នុងការិយាល័យឥណ្ឌូចិនដែលទទួលបន្ទុកកិច្ចការជាមួយភូមានិងបារាំងនៅឥណ្ឌូចិន ។ ប្រាក់បៀវត្សរ៍ប្រចាំខែរបស់គាត់គឺមានចំនួនតែ ២៨បាតប៉ុណ្ណោះ ។ គាត់ធ្វើការនៅក្រសួងការបរទេសអស់រយៈពេល១ខែ ដែលគាត់នៅចាំថាបានអានរបាយការណ៍ពីទាហានបារាំងដែលបាញ់ទៅលើប្រជាជនឡាវមួយចំនួនរស់នៅតាមដងទន្លេដែលកំពុងជួសពីទន្លេមេគង្គ ។

សាខាបក្សកុម្មុយនីស្តឥណ្ឌូចិនរបស់វៀតណាមបានដឹងថាជនជាតិខ្មែរម្នាក់បានចូលរួមក្នុងបក្សកុម្មុយនីស្តថៃ ។ ពួកវៀតណាមបានទាក់ទងជាមួយគាត់តាមរយៈភាគីថៃដើម្បីសួរថាតើគាត់មានបំណងចូលរួមនៅក្នុងការតស៊ូប្រឆាំងបារាំងដែរឬទេ ។ គាត់បានឆ្លើយតបវិញថាគាត់ពិតជាមានបំណងបែបនោះមែន ។ ប្រសិនបើគាត់ចង់បានជីវិតប្រកបដោយភាពសុខស្រួលគាត់ប្រាកដជានឹងនៅបន្តធ្វើនៅឯក្រសួងការបរទេសនោះ ។ នៅថ្ងៃណាមួយគាត់នឹងអាចក្លាយជាឯកអគ្គរដ្ឋទូតប៉ុន្តែគាត់លែងទប់ចិត្តបានចំពោះអ្វីដែលបារាំងកំពុងធ្វើនៅឥណ្ឌូចិន ។ បន្ទាប់ពីការពិភាក្សាថ្នាក់ជាន់ខ្ពស់រវាងភាគីថៃនិងវៀតណាមគាត់បានផ្លាស់ប្តូរសមាជិកភាពរបស់គាត់ទៅក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិន ។

ការងាររបស់គាត់នៅក្នុងបក្សកុម្មុយនីស្តត្រូវបានគិតចាប់តាំងពីពេលដែលគាត់ចូលក្នុងបក្សកុម្មុយនីស្តថៃ នួន ជា បានអត្ថាធិប្បាយថាវាជាគោលការណ៍មូលដ្ឋានក្នុងចំណោមបក្សកុម្មុយនីស្តដែលការងាររបស់បក្សមួយត្រូវរាប់ចាប់តាំងពីពេលដែលមនុស្សម្នាក់នេះចូលក្នុងបក្សដំបូងដោយមិនគិតអំពីថាតើបក្សកុម្មុយនីស្តនោះជាអ្វីឡើយ ។ បន្ទាប់ពីបានផ្លាស់ទៅបក្សកុម្មុយនីស្តឥណ្ឌូចិនគាត់បានចូលទៅក្នុងតំបន់សំឡូតនៅប៉ៃលិនជាកន្លែងដែលគាត់ធ្វើការនៅក្នុងភូមិដោយទទួលខុសត្រូវខាងផ្នែកឃោសនាការនិងបោះពុម្ពកាសែតស្តីពីការតស៊ូប្រឆាំងបារាំង ។ នៅពេលនោះគាត់មិនមែនជាអ្នកមានឋានៈខ្ពស់នៅក្នុងបក្សទេ ។

នៅក្នុងការតស៊ូប្រឆាំងបារាំងគាត់អាចមើលឃើញថាខ្មែរឥស្សរៈមិនបានអនុវត្តគោលនយោបាយដ៏ត្រឹមត្រូវនោះទេហើយនៅតាមតំបន់ជួរភ្នំដែលហួសពីការគ្រប់គ្រងរបស់បារាំងក្រុមអ្នកភូមិដែលមានអាវុធយុទ្ធភណ្ឌអាចក្រោកឈរឡើងខ្លួនឯងដោយមានឬក៏មិនចាំបាច់មានការជួយឧបត្ថម្ភពីខ្មែរឥស្សរៈឡើយ ។ គាត់បានមើលឃើញថាជាតិនិយមរបស់កសិករមានសភាពខ្លាំងហើយប្រសិនបើមានការជំរុញអ្នកទាំងនោះនឹងចូលរួមក្នុងការតស៊ូដើម្បីប្រឆាំងនឹងបារាំងជាមិនខាន ។ ទោះបីយ៉ាងណាក៏ដោយមេដឹកនាំខ្មែរឥស្សរៈគ្មានគោលនយោបាយឡើយ ។ អ្នកទាំងនោះជាជនឱកាសនិយម ។

ឆ្នាំដែលស្តាលីនបានស្លាប់ឲ្យនៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៥ នួន ជា បានចាកចេញពីប៉ៃលិនដោយថ្មើរជើងទៅកាន់ទីក្រុងនៅតាមបណ្តោយព្រំដែនថៃគឺអារ៉ាន់យ៉ា ប្រាថេត ជាកន្លែងដែលគាត់ជិះរថភ្លើងទៅទីក្រុងបាងកកដោយបង្ហាញខ្លួនជាជនជាតិថៃ ។ គាត់ជិះរថភ្លើងពីទីក្រុងបាងកកទៅកាន់ទីក្រុងនុងខាយ បន្ទាប់មកក៏ជិះឡានទៅប៊ុងកាន់ហើយចុងក្រោយឆ្លងកាត់ទន្លេមេគង្គនិងឡើងនៅត្រង់ទីក្រុងរបស់ឡាវឈ្មោះ ប៉ាក សាន ។ គាត់បានឆ្លងកាត់ប្រទេសឡាវដោយមានការនាំផ្លូវពីប្រជាជនឡាវឥស្សរៈដែលបានដឹកគាត់តាមកង់រួចហើយធ្វើដំណើរថ្មើរជើងឆ្ពោះទៅហាវប៉ិញដែលជាគោលដៅរបស់គាត់នៅប្រទេសវៀតណាម ។ ការធ្វើដំណើរនេះធ្វើឲ្យគាត់ចំណាយពេលជាច្រើនខែ ។ ដោយចំណាយពេល២ឆ្នាំនៅហាវប៉ិញ ជនជាតិខ្មែរប្រហែល១០នាក់ដោយរាប់ទាំងគាត់ផងបានទទួលការបណ្តុះបណ្តាលពីគ្រូជនជាតិវៀតណាម ។ អ្នកបកប្រែត្រូវបានផ្តល់ចំពោះអ្នកណាដែលមិនមានភាសាវៀតណាម ។ គាត់បានរៀននៅប្រទេសវៀតណាមខណៈពេលដែលសមរភូមិឌៀនបៀនភូបានកើតឡើងឲ្យខែមីនានិងខែឧសភា (ឆ្នាំ១៩៥៤) ។ កន្លែងនោះហើយដែលគាត់បានជួបជាមួយមេដឹកនាំប្រទេសឡាវព្រះអង្គម្ចាស់សុផានុវង្សកៃសុន ផុមវិហាន និង សិញកាប៉ូស៊ី យូដូនឡាម៉ានី ។ ក៏ប៉ុន្តែគាត់មិនបានជួបជនជាតិថៃណាម្នាក់ទេ ។ កិច្ចព្រមព្រៀងឈប់បាញ់នៅទីក្រុង

ហ្សឺណែវត្រូវបានចុះហត្ថលេខានៅខែកក្កដា ឆ្នាំ១៩៥៤ ហើយមួយឆ្នាំបន្ទាប់មកគឺឆ្នាំ១៩៥៥គាត់បានចាកចេញពីប្រទេសវៀតណាមហើយត្រឡប់មកកាន់ទីក្រុងភ្នំពេញវិញ ។ នៅពេលនោះហើយដែលគាត់បានជួបជាមួយ ប៉ុល ពត ជាលើកដំបូង ។ គាត់ក៏បានសៀវភៅម៉ៅសេទុងបកប្រែជាភាសាវៀតណាមដែលគាត់បានទិញនៅភ្នំពេញបន្ទាប់ពីការបញ្ចប់ការតស៊ូប្រឆាំងបារាំង ។

គាត់ត្រូវបានជ្រើសរើសជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជាហើយនៅតែកាន់មុខតំណែងនោះដែលមានឋានៈទីពីរ បន្ទាប់ពីប៉ុល ពត តាមឋានន្តរស័ក្តិរបស់បក្ស ។ គាត់បានកត់សម្គាល់ថានៅក្នុងខ្សែបក្សហើយសូម្បីតែនៅក្នុងមជ្ឈដ្ឋានព្រះសង្ឃនិងព្រះពុទ្ធសាសនាមានការប្រឈមមុខដាក់គ្នា ។ មានការប្រឈមមុខដាក់គ្នារវាងរូបគាត់ជាមួយ ប៉ុល ពត ។ តែទោះជាយ៉ាងណាក៏ដោយមិនមានការប្រឈមមុខគ្នាធំដុំនោះទេរវាងអ្នកទាំងពីរនេះជាពិសេសខាងផ្នែកគោលនយោបាយ ។ នួន ជា បានគូសបញ្ជាក់ថា ប៉ុល ពត ជាជនកុម្មុយនីស្តហើយគាត់ក៏ជាបុរសម្នាក់មានគោលការណ៍សីលធម៌ខ្ពស់ដែរ ។ គាត់មិនដែលធ្វើបាបនរណាម្នាក់ហើយគាត់ក៏មិនចេះជីកស៊ីដែរ ។

នៅពេលនិយាយពីសង្គ្រាមមានការធ្វើសង្គ្រាមឈ្លានពាននិងសង្គ្រាមដើម្បីការពារខ្លួនហើយសង្គ្រាម ដែលគាត់ធ្វើឡើងនោះគឺជាសង្គ្រាមការពារដើម្បីខ្លួនតែប៉ុណ្ណោះ ។ ដើម្បីការពារប្រទេសប្រទេសត្រូវតែមានឥទ្ធិពលយោធាហើយមនុស្សម្នាក់ៗមានសិទ្ធិការពារខ្លួន ។ ជួនកាលមនុស្សម្នាក់ត្រូវតែសម្លាប់អ្នកផ្សេងដើម្បីការពារខ្លួន ។ នោះជាកាតព្វកិច្ចដែលមិនអាចចៀសផុតឡើយ ។ ឆ្នាំ១៩៧០គឺជាឆ្នាំដែលគាត់ចូលទៅក្នុងព្រៃដើម្បីធ្វើការតស៊ូហើយទើបតែឥឡូវនេះទេដែលគាត់ធ្វើការសិក្សាយ៉ាងហ្មត់ចត់អំពីព្រះពុទ្ធសាសនា ។ តែទោះជាយ៉ាងណាក៏ដោយចាប់តាំងពីពេលធ្វើបដិវត្តន៍ខណៈពេលដែលនិយាយទៅកាន់មន្ត្រីរដ្ឋាភិបាលក្នុងវគ្គបណ្តុះបណ្តាលគាត់បាននិយាយអំពីបញ្ហាដែលដូចគ្នាទៅនឹងសីលប្រាំរបស់ព្រះពុទ្ធសាសនា ដូចជាអ្នកកាន់អំណាចមិនត្រូវលង់ខ្លួនទៅលើប្រាក់កាសស្រានិងស្រី ។ អ្នកកាន់អំណាចមិនត្រូវលួចប្លន់អ្វីដែលជារបស់អ្នកផ្សេងនោះឡើយ ។ អ្នកដែលមិនអាចគោរពតាមតម្រូវការទាំងអស់នេះមិនអាចក្លាយជាមន្ត្រីរដ្ឋាភិបាលទេ ។ ពាក្យទាំងអស់នេះដូចគ្នាទៅនឹងទស្សនៈរបស់ ម៉ៅ សេទុងដែរ ។

បន្ទាប់ពីបានចាកចេញពីប្រទេសថៃនៅឆ្នាំ១៩៥០ គាត់គ្មានការទាក់ទងបន្តមកទៀតទេជាមួយនឹងបក្សកុម្មុយនីស្តថៃ



ហើយគាត់កម្រជួបជនជាតិថៃណាស់ ។ ឧទាហរណ៍ ដែលកម្រនោះគឺនៅឆ្នាំ១៩៧៥ឬ១៩៧៦ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យដែលនៅពេលនោះគាត់បានជួប ដួង វ៉ានណាស្រ៊ី ជាសមាជិកបក្សកុម្មុយនីស្តថៃដែលមកកាន់ទីក្រុងភ្នំពេញក្នុងដំណើរទស្សនកិច្ចសង្កេតការណ៍ ។ និយាយត្រឡប់ទៅឆ្នាំ១៩៤៨វិញនៅឯសកលវិទ្យាល័យធម្មសាធជាពេលដែលគាត់រៀនថ្នាក់បញ្ចប់ជំនាន់ទី៧នៃវគ្គត្រៀម ដួង រៀននៅថ្នាក់បញ្ចប់ជំនាន់ទី៥ ។ ដូច្នេះហើយការជួបជុំផ្សេងៗទៀតជាមួយនឹងជនជាតិថៃម្នាក់ដែលគាត់ចាំបានគឺបុរសម្នាក់ដែលមានឋានៈជាលេខាបក្សកុម្មុយនីស្តថៃដែលមានឈ្មោះហៅក្រៅថា ឆាត ហើយ ដែលពណ៌សម្បុរជ្រះដូចចិន ។

ការធ្វើដំណើរទៅបរទេសរបស់គាត់ត្រូវកម្រិតត្រឹមប្រទេសចិនដើម្បីចូលរួមសន្និសិទ្ធស្តីពីសន្តិភាពនៅប្រទេសចិន ក្នុងអំឡុងពេលតស៊ូប្រយុទ្ធប្រឆាំងនឹងបារាំង ព្រមទាំងការធ្វើដំណើរជាផ្លូវការទៅប្រទេសចិន វៀតណាម និងកូរ៉េខាងជើង ក្នុងឋានៈជាមេដឹកនាំសភាប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ ។

ដោយឆ្លុះបញ្ចាំងអំពីមេដឹកនាំខ្មែរក្រហមជាច្រើននាក់ផ្សេងទៀត នួន ជា បានហៅអ្នកទាំងអស់នោះថាជាមនុស្សល្អនិងជាប្រភេទមនុស្សមិនចេះលួចនិងមិនធ្វើអាក្រក់ ។ អ្នកទាំងអស់នៅជាមនុស្សចេះដឹង ។ ប៉ុល ពត ក៏ដូចជា ជូ អេនឡាយដែរគឺមានការអប់រំខ្ពស់ហើយបានសិក្សានៅប្រទេសបារាំងទៀត ។ ខណៈពេលដែលអ្នកទាំងអស់ នួន ជា និង(មេដឹកនាំខ្មែរក្រហមផ្សេងៗទៀត) កំពុងកាន់អំណាចប្រជាជននៅក្រៅប្រទេសបានរិះគន់អ្នកទាំងអស់នេះចំពោះបញ្ហាមួយឬបញ្ហាផ្សេងទៀត ។ តែទោះជាយ៉ាងណាក៏ដោយ តាមទស្សនៈរបស់គាត់ប្រការទាំងអស់នោះគ្មានខ្លឹមសារអ្វីទាំងអស់ក្រៅពីការរិះគន់ពីអ្នកខាងក្រៅ ។ គាត់បានលើកឧទាហរណ៍ពីប្រទេសជប៉ុន ។ បើទោះជាខ្សត់ធន់ធានធម្មជាតិប្រទេសនេះនៅតែអាចអភិវឌ្ឍន៍បាន ។ ប្រការទាំងនេះគឺដោយសារតែការភ្ញាក់ស្មារតីខាងសាសនា ។ រឿងដ៏សំខាន់ជាងគេបំផុត គឺការគិតរបស់មនុស្សម្នាក់ៗនិងអំណាចឆន្ទៈរបស់មនុស្សម្នាក់ៗ ប្រទេសជប៉ុនមានលទ្ធភាពក្លាយខ្លួនទៅជាមហាអំណាចដោយសាតែការគិតនិងឆន្ទៈរបស់ខ្លួន ។ ដោយសារប្រទេសនេះបានធ្វើឲ្យការគិតទាំងអស់នេះក្លាយជាការអនុវត្តតាមរយៈការខិតខំប្រឹងប្រែងរបស់ខ្លួន ។ គោលបំណងរបស់គាត់គឺត្រូវលើកតម្កើងការគិតនិងឆន្ទៈរបស់ប្រទេសកម្ពុជាហើយធ្វើឲ្យការគិតនិងឆន្ទៈទាំងនោះក្លាយទៅជាការអនុវត្តតាមរយៈការខិតខំប្រឹងប្រែងរបស់ខ្លួន ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅ អ្នកឈ្នះបានដាក់ឲ្យរបបនេះទទួលខុសត្រូវចំពោះរឿងរ៉ាវទាំងអស់ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក៏ប៉ុន្តែគាត់សួរវិញថា ប្រសិនបើរបបកម្ពុជាប្រជាធិបតេយ្យបានសម្លាប់ប្រជាជនអ៊ីចឹងតើរបបនេះអាចឈ្នះសង្គ្រាមនៅក្នុងឆ្នាំ១៩៧៥យ៉ាងម៉េចកើត? តើមានអ្នកណាដែលដុតផ្ទះដែលទើបសាងសង់រួចថ្មីៗចោល? គាត់ខ្លួនឯងមិនដែលមានចិត្តគិតពីការសម្លាប់ប្រជាជននោះទេ ។ ប៉ុន្តែមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យមានការងារធ្វើយ៉ាងច្រើនលើសលប់ ។ អ្នកទាំងនេះគ្រាន់តែជឿអំពីអ្វីដែលមន្ត្រីថ្នាក់កណ្តាលនិងថ្នាក់ក្រោមរបស់ខ្លួនប្រាប់មកតែប៉ុណ្ណោះ ហើយអ្នកទាំងនោះមិនមានលទ្ធភាពចេញទៅត្រួតពិនិត្យតាមតំបន់មូលដ្ឋានឡើយ ។ ប្រជាជនជាច្រើនបានស្លាប់ដោយសារហេវហត់អស់កម្លាំងនិងអត់ឃ្លានដោយសារតែប្រជាជនទាំងនោះត្រូវបង្ខំឲ្យធ្វើការអស់ជាច្រើនម៉ោងជាងអ្វីដែលបានកំណត់រួច ព្រមទាំងហូបបបររាវកក្ខូកដោយសារតែភាពខ្វះខាតស្បៀង ។ ប្រការដែលគាត់មិនមានលទ្ធភាពចេញទៅបញ្ឈប់អ្វីដែលបានកើតឡើងគឺជារឿងអកុសល ។ ដោយសារតែរឿងនេះហើយគឺគាត់ទទួលខុសត្រូវ ។

## ៣) ការស្វែងរកឈ្មោះជាភាសាថៃរបស់ នួន ជា

ដោយទទួលព័ត៌មានមកពីបទសម្ភាសន៍នេះ ភារកិច្ចដំបូងរបស់អ្នកនិពន្ធនៅពេលត្រឡប់ទៅទីក្រុងបាងកកដោយចេញពីទីក្រុងភ្នំពេញគឺត្រូវស្វែងរកឈ្មោះដែល នួន ជា ធ្លាប់ប្រើនៅទីក្រុងបាងកក ។ ការដែលមិនស្គាល់ឈ្មោះនោះនឹងធ្វើឲ្យមានការលំបាកក្នុងការតាមរកប្រវត្តិរឿងរ៉ាវទាក់ទងនឹងជីវិតរបស់គាត់នៅក្នុងទីក្រុងបាងកក បើទោះជាអ្នកនិពន្ធពិតជាបានជួបអតីតសមាជិកបក្សកុម្មុយនីស្តថៃជាច្រើនដែលឈ្មោះអ្នកទាំងអស់នោះត្រូវបាន នួន ជា លើកយកមកនិយាយក្នុងពេលធ្វើសម្ភាស ។

ជំហានដំបូងត្រូវរកបញ្ជីឈ្មោះនិស្សិតដែលបានចុះឈ្មោះ

រៀនថ្នាក់បញ្ចប់ជំនាន់ទី៧នៃវគ្គគ្រៀម នៅសកលវិទ្យាល័យធម្មសាធ ដើម្បីពិនិត្យមើលថាតើមានឈ្មោះមួយណាដែលធ្វើឲ្យនិពន្ធចាប់អារម្មណ៍ ។ ដូច នួន ជា ធ្លាប់បាននិយាយថា ថ្នាក់បញ្ចប់ជំនាន់ទី៧បានចាប់ផ្តើមចូលរៀននៅពាក់កណ្តាលឆ្នាំដំបូងនៃឆ្នាំ ១៩៤៤ ហើយបញ្ចប់ក្នុងរយៈពេល២ឆ្នាំក្រោយមក ក្នុងអំឡុងពាក់កណ្តាលឆ្នាំដំបូងនៃឆ្នាំ១៩៤៦ ។ បញ្ជីឈ្មោះក្នុងថ្នាក់នេះដែលអ្នកនិពន្ធពិនិត្យមើលមានឈ្មោះចំនួន១៤៣៩នាក់ ។ មិនមានវិធីណាមួយអាចដឹងថាតើមានឈ្មោះណាខ្លះដែលត្រូវលុបបំបាត់ ប៉ុន្តែនេះទំនងជាចំនួនសិស្សសរុបនៅក្នុងថ្នាក់រៀនបញ្ចប់ជំនាន់ទី៧ ។ បញ្ជីឈ្មោះនេះមានចំនួនច្រើនជាងអ្វីដែលអ្នកនិពន្ធរំពឹងគិតទុកទៅទៀត ។ ឈ្មោះទាំងអស់ត្រូវបានរាយតាមលំដាប់អក្ខរាវិរុទ្ធថៃ ។ ដោយចាប់ផ្តើមពីក្បាលបញ្ជី ឈ្មោះអ្នកនិពន្ធបានពិនិត្យមើលពាក់កណ្តាលបញ្ជីនៅពេលនោះគាត់បានប្រទះឃើញឈ្មោះ រុងលឹត ឡៅឌី ដោយមើលឃើញឈ្មោះនេះ អ្នកនិពន្ធមានប្រផ្នូលថានេះជាឈ្មោះដែល នួន ជា បានប្រើ ។ ហេតុផលមួយចំពោះប្រផ្នូលនេះគឺព័ត៌មានមកពី ដេវីដ ឆេនល័រ និង បេន ឃែរនិន ដែលបានដកស្រង់សម្តីនៅខាងដើមនៃការសិក្សាស្រាវជ្រាវ ។ យោងតាមឆេនល័រ, នួន ជា បានប្រើឈ្មោះ ឡុងរួត ក្នុងអំឡុងពេលរស់នៅក្នុងទីក្រុងបាងកក ។ ឃែរនិន បានឲ្យឈ្មោះ នួន ជា ថា ឡុងរ៉េត ។ ឈ្មោះទាំងពីរនេះមានភាពប្រហាក់ប្រហែលទៅនឹងឈ្មោះ រុងលឹត ។ ហេតុផលមួយទៀតគឺត្រកូលឈ្មោះ ឡៅឌី ។ នៅក្នុងបទសម្ភាសន៍ នួនបានលើកឡើងថា ត្រកូលរបស់ឪពុកគាត់គឺ ឡៅ ។ នេះគឺជាត្រកូល ចិន ។ នៅពេលបង្កើតនាមត្រកូលតាមបែបថៃ ជនជាតិថៃដែលមានជីដូនជីតាជាចិនតែងតែបញ្ចូលសូរសំឡេងនាមត្រកូលតាមរបៀបចិនទៅក្នុងនាមត្រកូលថ្មីជារបៀបថៃវិញ ។ ចំពោះនាមត្រកូលរបៀបចិនគឺ ឡៅ វាទំនងជាថា នួន បានបន្ថែមពាក្យជាភាសាថៃ គឺ «ឌី» ដែលមានន័យថា «ល្អ» ដោយផ្តល់ឲ្យគាត់នូវនាមត្រកូលតាមរបៀបចិន-ថៃ ឈ្មោះ ឡៅឌី (ឡៅល្អ) ។

ដោយមានអំណះអំណាងរឹងមាំដែលឈ្មោះជាភាសាថៃរបស់ នួន ជា គឺ រុងលឹត ឡៅឌី ។ ជំហានបន្ទាប់គឺត្រូវត្រួតពិនិត្យមើលសាលាវត្តបិនចាម៉ាបូភីត (បច្ចុប្បន្នឈ្មោះ ម៉ាថាយុម បិនចាម៉ាបូភីត) ជាកន្លែងដែល នួន បាននិយាយថា គាត់បានរៀននៅទីនោះ ដើម្បីតាមរកថាតើឈ្មោះនោះមាននៅក្នុងបញ្ជីនិស្សិតបញ្ចប់ការសិក្សានៅសាលានោះដែរឬអត់ ។

ម៉ាថាយុម បិនចាម៉ាបូភីត គឺជាសាលាមធ្យមសិក្សាគ្រប់គ្រងដោយរដ្ឋាភិបាលមានទីតាំងនៅក្នុងបរិវេណវត្តបិនចាម៉ាបូភីតជាវត្តលេចធ្លោដែលកសាងឡើងដោយស្តេច ជូឡាឡុងកន ដែលស្ថិតនៅចំកណ្តាលទីក្រុងបាងកក មិនឆ្ងាយពីរាជវាំងជិតឡាដា ហើយនិងការិយាល័យរបស់នាយករដ្ឋមន្ត្រី ។ រូបបដិមាព្រះពុទ្ធនៅសុខោទ័យត្រូវបានដាក់តម្កល់នៅក្នុងព្រះវិហារធ្វើអំពីថ្មម៉ាបខណៈពេលដែលសិល្បៈគំនូររបស់វត្តនៅជុំវិញត្រូវបានដាក់តម្រៀបជាជួរនូវរូបដិមាយ៉ាងច្រើនដែលបញ្ជូនមកវត្តនេះពីគ្រប់ទីកន្លែងទូទាំងពិភពលោក ។ ការដាក់តម្រៀបជាជួរនៅខាងក្រោយព្រះវិហារគឺជាអគារជាច្រើនដែលបង្កើតបានជាកន្លែងស្នាក់នៅរបស់ព្រះសង្ឃ ។ ស្ថិតនៅក្បែរទីតាំងនេះមានសាលាវត្តបិនចាម៉ាបូភីត ។ កុដិរបស់ព្រះសង្ឃទាំងនេះគឺជាកន្លែងស្នាក់នៅរបស់ព្រះសង្ឃបីអង្គមកពីខេត្តបាត់ដំបងដែលព្រះសង្ឃទាំង៣អង្គជាអ្នកថែរក្សា នួន ជា ហើយនៅកន្លែងនេះហើយដែលគាត់ធ្លាប់រស់នៅខណៈពេលគាត់រៀននៅសាលាក្បែរនោះ ។ របៀបរបបរស់នៅនិងការសិក្សារបស់ នួន គឺមិនមានលក្ខណៈវិសេសវិសាលនោះទេ ។ មកដល់សព្វថ្ងៃនេះ យុវជនជាច្រើនមកពីទីជនបទដែលធ្វើដំណើរមកទីក្រុងបាងកក ដើម្បីបន្តការសិក្សារស់នៅក្នុងលក្ខណៈដូចគ្នានេះដែរ ។ ក្នុងចំណោមសមាជិកបក្សកុម្មុយនីស្តថៃដែលនឹងបញ្ចប់ការសិក្សានេះ ដូចជា ប្រាសិទ្ធិ សាបសុនថុន, រួម វង់ផាន, សាណុះ ផានិឆារៀន, ស៊ុមខាន ភីឆៃគល់, ប្រាសិទ្ធិ ចារឿនរ៉ាត មកពីជនបទហើយបានរស់នៅក្នុងវត្តនេះខណៈពេលសិក្សាថ្នាក់ឧត្តមនៅទីក្រុងបាងកក ។

នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៣ អ្នកនិពន្ធបានទៅមើលបន្ទប់គ្រូៗនៅម៉ាថាយុម បិនចាម៉ាបូភីត ។ សាលានេះមានឈ្មោះសិស្សបញ្ចប់ការសិក្សាដែលបញ្ចូលក្នុងប្រព័ន្ធក្នុងកំព្យូទ័រ ។ ដូច្នេះហើយអ្នកនិពន្ធត្រូវបានប្រាប់ថា ការស្វែងរកឈ្មោះគឺងាយស្រួលបំផុត ។ ជាការពិតណាស់ ឈ្មោះជាភាសាថៃរបស់ នួន ជា នៅទីនោះហើយ ។ អ្នកនិពន្ធបានធ្វើការស្រាវជ្រាវភ្លាមៗហើយក្នុងរយៈពេលតែមួយភ្លែត ឈ្មោះនោះក៏បានលេចឡើងគឺ រុងលឹត

ឡៅឌី ។ ប្រវត្តិរូបដែលនៅជិតឈ្មោះនោះគឺសិស្សលេខ៤៨៦៧ ដែលបញ្ចប់ការសិក្សានៅថ្នាក់មធ្យមឆ្នាំទី៤ នៅក្នុងឆ្នាំសិក្សា ១៩៤២ និងបញ្ចប់ការសិក្សាថ្នាក់មធ្យមឆ្នាំទី៥ នៅក្នុងឆ្នាំសិក្សា ១៩៤៣ ជាឆ្នាំដែលគាត់បានចុះឈ្មោះចូលរៀនវគ្គត្រៀមនៅ សកលវិទ្យាល័យធម្មសាធ ។ ការបញ្ចប់ឆ្នាំសិក្សា១៩៤៣ គួរតែ នៅពាក់កណ្តាលឆ្នាំ១៩៤៤ ដែលគាប់ជួននឹងពេលវេលាចុះ ឈ្មោះចូលថ្នាក់បញ្ចប់ការសិក្សាជំនាន់ទី៧ ក្នុងវគ្គត្រៀមនៅ សកលវិទ្យាល័យធម្មសាធ ។ ក៏ប៉ុន្តែមានកំហុសឆ្គងខ្លះៗនៅត្រង់ កន្លែងនេះ ។ នៅក្នុងបទសម្ភាសន៍ នួន ជា បានប្រាប់អ្នកនិពន្ធថា គាត់បានបញ្ចប់ថ្នាក់មធ្យមឆ្នាំទី៤នៅបាត់ដំបងរួចហើយទើបទៅ ទីក្រុងបាងកក ហើយសិក្សារៀនសូត្រនៅសាលាវត្តបិនចាម៉ាបូភិត ជាសាលាដែលគាត់ចូលរៀនថ្នាក់មធ្យមឆ្នាំទី៥និងបញ្ចប់នៅឆ្នាំ ទី៦ ដែលជាដំណើរការទូទៅរបស់និស្សិតម្នាក់ៗ ដែលចង់បន្តទៅ ថ្នាក់ត្រៀមនៅសាកលវិទ្យាល័យ ។ ក៏ប៉ុន្តែកំណត់ហេតុប្រវត្តិរូប នៅសាលាបានបង្ហាញថា ក្រោមឈ្មោះថា រុងលឹត, នួន បានចូល រៀនថ្នាក់មធ្យមឆ្នាំទី៤ បានបញ្ចប់ឆ្នាំទី៥ រួចហើយបន្តទៅថ្នាក់ ត្រៀមនៅឯសាកលវិទ្យាល័យ ។ ទាំងអស់នេះហាក់ដូចជាមិន ធម្មតា ។ អ្នកនិពន្ធឆ្ងល់ថាតើហេតុអ្វីបានជាមានការខុសឆ្គងនៅក្នុង ការដាក់បញ្ចូលព័ត៌មានទៅក្នុងប្រព័ន្ធកុំព្យូទ័រ ។ បុគ្គលិកធ្វើការនៅ សាលាដែលស្រាវជ្រាវរឿងនេះគ្មានចម្លើយចំពោះបញ្ហានេះទេ ។ បន្ទាប់មកអ្នកនិពន្ធបានទាក់ទងជាមួយមន្ត្រីម្នាក់នៅក្រសួង ការបរទេសដែលគាត់ស្គាល់ ហើយបានស្នើសុំឲ្យមន្ត្រីនោះឲ្យពិនិត្យ ក្រែងលោហ៍ឃើញឈ្មោះ រុងលឹត ឡៅឌី នៅក្នុងប្រវត្តិរូបរបស់ បុគ្គលិកដែលចូលធ្វើការ ។ គាត់បានរកឃើញប្រវត្តិរូបទាំងនោះ នៅក្នុងបញ្ជីមន្ត្រីការបរទេសចាស់របស់ក្រសួង គាត់បានរកឃើញ ឈ្មោះ រុងលឹត ឡៅឌី ជាមួយកំណត់ចំណាំខ្លីមួយដែលសរសេរថា គាត់បានចូលបម្រើការនៅក្រសួងការបរទេសនៅពុទ្ធសករាជ ២៤៩៣ បន្ទាប់មកក៏លាឈប់វិញ ។ នេះបញ្ជាក់ថា រុងលឹត បាន ចូលបម្រើការនៅក្រសួងការបរទេសថៃនៅឆ្នាំ១៩៥០ ដែលជា ពុទ្ធសករាជ២៤៩៣ តែទោះបីយ៉ាងណាក៏ដោយ ថ្ងៃនិងខែដែល គាត់បានចូលធ្វើការមិនមានកត់ត្រាទុកទេ ។ ថ្ងៃខែឆ្នាំ លាលែងពី តំណែងក៏មិនមានកត់ត្រាទុកដែរ ក៏ប៉ុន្តែមន្ត្រីដែលធ្វើការស្រាវជ្រាវ បានប្រាប់អ្នកនិពន្ធថា នៅបន្ទាត់ចំពីខាងក្រោមមានសរសេរថា រុងលឹត បានចូលក្រសួងការបរទេសនៅក្នុងឆ្នាំ១៩៥០ ។ សំណេរ នេះគ្រាន់តែបញ្ជាក់ថា គាត់បានលាលែងពីតំណែងដែលមន្ត្រីបាន និយាយថាឃ្លានេះបង្កប់ន័យថាគាត់បានលាលែងចេញពីតំណែង នៅក្នុងឆ្នាំ១៩៥០ដដែល ។ ប្រការនេះមានភាពស្របគ្នាជាមួយ នឹងសម្តីរបស់ នួន ជា ក្នុងបទសម្ភាសន៍ដែលថា គាត់បានចូលក្រសួង ការបរទេសនៅក្នុងឆ្នាំ១៩៥០ បន្ទាប់មកលាលែងពីតំណែងមួយ ខែក្រោយមក ។

បន្ទាប់ពីបានស្វែងរកឃើញនៅក្រសួងការបរទេស អ្នកនិពន្ធ បានស៊ើបអង្កេតមើលនៅឯនាយកដ្ឋានជំរះបញ្ជីទូទៅរបស់ក្រសួង ហិរញ្ញវត្ថុ ជាកន្លែងដែល នួន ជា បាននិយាយថា គាត់ធ្លាប់ធ្វើការ រយៈពេលបីឆ្នាំ ដើម្បីពិនិត្យមើលថាតើឈ្មោះ រុងលឹត អាចរក ឃើញនៅក្នុងបញ្ជីឈ្មោះនោះដែរឬអត់ ក៏ប៉ុន្តែអ្នកនិពន្ធត្រូវ បានប្រាប់ថា នាយកដ្ឋាននេះរក្សាទុកតែបញ្ជីឈ្មោះបុគ្គលិកដែល ចូលនិវត្តន៍ចាប់តាំងពីឆ្នាំ១៩៨៦តែប៉ុណ្ណោះ ។ ដូច្នេះហើយ អ្នកនិពន្ធមិនអាចមានលទ្ធភាពបញ្ជាក់ពីកំណត់ហេតុបណ្ណសារដ្ឋាន នៅក្រសួងហិរញ្ញវត្ថុថៃ ស្តីពីការជ្រើសរើសឲ្យចូលបម្រើការងារ របស់ រុងលឹត ឡៅឌី នៅក្នុងនាយកដ្ឋានជម្រះបញ្ជីទូទៅ ក្នុងអំឡុង ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៤០ ។

ត្រឹមឥឡូវនេះ វាខិតទៅរកភាពប្រាដកប្រជាដែលថា រុងលឹត ឡៅឌី គឺជា នួន ជា ។ ប្រសិនបើមនុស្សរបស់ នួន ដែល បានលើកឡើងនៅក្នុងបទសម្ភាសន៍របស់គាត់ទទួលស្គាល់ថាពួកគេ ទាក់ទងយ៉ាងសកម្មជាមួយ រុងលឹត ហើយប្រសិនបើសារៈសំខាន់ នៃសកម្មភាពទាំងនោះត្រូវគ្នាជាមួយនឹងអ្វីដែល នួន បាននិយាយ នៅក្នុងបទសម្ភាសន៍របស់គាត់ ភាពប្រាកដប្រជាអាចពេញលេញ ។ បច្ចុប្បន្ននេះ អ្នកនិពន្ធបានធ្វើការទាក់ទងជាមួយ ខុត្តម ឆារឿនរ៉ាត (១៩២៩-២០០៧) ដែលជាជនកុម្មុយនីស្តដ៏សកម្មម្នាក់ ហើយ បើតាមអ្នកនិពន្ធដឹង គឺជា ខុត្តម ដែលជាសហការីរបស់ នួន ជា នៅក្នុងនាយកដ្ឋានជំរះបញ្ជីទូទៅ ហើយដែល នួន ជា និយាយថា ខុត្តម ជាអ្នកដែលហៅគាត់ឲ្យចូលក្នុងបក្សកុម្មុយនីស្តថៃ ។

**(នៅមានត)**

**អ៊ីជី ម្វ៉ាស៊្រីម៉ា**

# ល្ខោននិយាយ : រឿងទម្លាយភាពស្ងប់ស្ងាត់

*សូមមេត្តាលើកលែងទោសអោយខ្ញុំផង? ប្រហែលជាខ្ញុំបាននិយាយពាក្យយឺតពេលបន្តិចហើយមើលទៅ ។ ថ្ងៃស្អែកខ្ញុំនឹងព្យាយាមម្តងទៀត ។ ខ្ញុំសុំទោស ហើយសូមអ្នកមេត្តាលើកលែងទោសឲ្យខ្ញុំទៅ........ ប្រែក្លាយទន្លេដែលពោរពេញទៅដោយឈាម ឲ្យទៅជាទន្លេនៃការផ្សះផ្សាជាតិ ។ ទន្លេនៃភាពទំនួលខុសត្រូវ ។ និយាយ និយាយ និយាយ..........*

«រឿងទម្លាយភាពស្ងប់ស្ងាត់» ជាល្ខោននិយាយមួយដែលត្រូវបានផលិតឡើងយ៉ាងពិសេសសម្រាប់ប្រជាជនកម្ពុជាទាំងអស់ដែលរួចផុតពីភាពចលាចលនៅក្នុងរបបខ្មែរក្រហម ។ ល្ខោននិយាយនេះសង្ឃឹមថានឹងជំរុញកិច្ចសន្ទនារវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលផ្តោតសំខាន់ទៅលើបញ្ហាមួយចំនួនទាក់ទងនិងរបៀបទទួលខុសត្រូវក្នុងការផ្សះផ្សាអតីតកាល និងបច្ចុប្បន្នកាល ។

អមជាមួយនិងការនិទានដ៏ពិរោះ ការសម្តែងទាំងប៉ុន្មាននៅក្នុងល្ខោននិយាយនេះ បានឆ្លុះបញ្ចាំងអំពីជីវិតប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម និងការតស៊ូផ្លូវចិត្ត និងអារម្មណ៍បច្ចុប្បន្នរបស់ជនរងគ្រោះនិងឧក្រិដ្ឋជនរបស់របបខ្មែរក្រហម ។

ល្ខោននិយាយនេះ គឺឆ្លុះបង្ហាញអំពីក្តីសង្ឃឹមដែលអាចទទួលបានម្តងទៀត ។ វាក៏បានជំរុញការលើកទឹកចិត្តទស្សនិកជនដែលចូលរួមទស្សនាឲ្យបង្ហាញនូវរាល់បទពិសោធន៍ដែលពួកគេធ្លាប់បានឆ្លងកាត់ និងនៅក្នុងវគ្គខ្លះសម្រាប់ការជំរុញលើកទឹកចិត្តឲ្យមានការសារភាព សុំខមាទោសនិងស្វែងរកការលើកលែងទោស ។

សរសេរ និង ដឹកនាំសាច់រឿងដោយអ្នកស្រី អាណាម៉ារី ព្រីន រួមជាមួយនិងជំនួយការផ្នែកស្រាវជ្រាវពីមជ្ឈមណ្ឌល



ឈុតមួយនៃការសម្តែងក្នុងរឿងទម្លាយភាពស្ងប់ស្ងាត់

ឯកសារកម្ពុជា រាល់សាច់រឿងទាំងប្រាំពីរនៅក្នុងល្ខោននិយាយនេះ គឺភាគច្រើនពឹងផ្អែកទៅលើបទសម្ភាសន៍មួយចំនួនដែលបានធ្វើជាមួយនិងជនរស់រានមានជីវិតនៅតាមខេត្ត ។ ល្ខោននិយាយនេះ គឺយ៉ាងយូរប្រហែលមានរយៈពេលប្រហែលមួយម៉ោងនិងដប់ប្រាំនាទី ។

## តួអង្គសម្តែង

តួអង្គទាំងអស់ត្រូវបានសម្តែងដោយអ្នកគ្រូបង្រៀនបួននាក់របស់សាកលវិទ្យាល័យវិចិត្រសិល្បៈ ដែលដើរតួជាតួអង្គប្រុសផងនិងស្រីផង ។ តួអង្គម្នាក់ គឺស្ត្រីមួយរូបដែលឈឺចាប់ជាមួយនិងវិប្បដិសារីរបស់ខ្លួនដែលបានលួចអង្ករដែលទុកសម្រាប់ពេលអាសន្នតាំងពីពេលនាងនៅជាក្មេងស្រីតូច ។ តួអង្គម្នាក់ទៀតមិនបាននិយាយជាមួយកូនប្រុសរបស់ខ្លួនដោយសារតែសង្ស័យថាកូនប្រុសគាត់បានប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ ព្រោះថាគាត់ជាកម្មាភិបាលរបស់ខ្មែរក្រហម ។ ចំណែកឯតួអង្គពីរនាក់ទៀត គឺជាទាហានយុវជនខ្មែរក្រហមដែលមានខ្សែជីវិតល្អខុសប្លែកគ្នាក្នុងការបម្រើអង្គការ (របបបក្ស) ។ រាល់សាច់រឿងទាំងប្រាំពីរនេះ គឺសុទ្ធតែពាក់ព័ន្ធជាមួយជម្លោះផ្លូវចិត្តនិងពាក្យសំដីដែលបុគ្គលទាំងបួននាក់ខ្វាចក្នុងការនិយាយបង្ហាញ ។

## ការបញ្ចូលបទចម្រៀងនិងការរាំដ៏ជោគជ័យ

ការប្រើប្រាស់បទចម្រៀង និងរបាំបែបខ្មែរនៅក្នុងល្ខោននេះ បានបង្កើនការទទួលយកបានពីសំណាក់ទស្សនិកជនជាបន្ថែមទៀតដើម្បីផ្តល់នូវបរិយាកាសដ៏ស្ងប់ស្ងាត់មួយដែលមានទស្សនិកជនខ្លះបានយំ ។ ល្ខោននិយាយនេះ គឺមិនពោរពេញទៅដោយទុក្ខសោកទាំងស្រុងនោះទេ ដោយសារតែមានវគ្គខ្លះបានបញ្ចូលរបាំប្រពៃណីដែលសប្បាយរីករាយ ដូចជារបាំស្នាជាដើម ។

## បញ្ចាំងនៅភ្នំពេញ

ការសម្តែងលើកដំបូងត្រូវបានបង្ហាញនៅឯក្រសួងកសិកម្ម និងវិចិត្រសិល្បៈសម្រាប់រដ្ឋមន្ត្រី និងមន្ត្រីរាជការដើម្បីសុំការអនុញ្ញាតជាមុនសិន ។ កាលពីថ្ងៃទី២១ និង២២ ខែកុម្ភៈ ល្ខោននិយាយបានបញ្ចាំងនៅឯសាលតាំងពិពរណ៍ស្ថិតនៅហួសរដ្ឋសភាជាតិ ។ ផ្អែកលើការឆ្លើយតបដំបូងបន្ទាប់ពីការសម្តែងជាសាធារណៈរបស់ខ្លួននៅភ្នំពេញ "រឿងទម្លាយភាពស្ងប់ស្ងាត់" មានឥទ្ធិពលយ៉ាងខ្លាំងទៅលើអ្នកទស្សនាល្ខោននិយាយនេះ ។ មនុស្សមួយចំនួនបាននិយាយថា ល្ខោននេះគួរតែមានមនុស្សច្រើនជាងនេះមកទស្សនាតាមតែអាចធ្វើទៅបាន ។ លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឆាំង យុ បានមានប្រសាសន៍ថា "ប្រជាជនកម្ពុជាបានបាត់បង់នូវដួងព្រលឹងរបស់ខ្លួនអស់រយៈពេលជាង៣០ឆ្នាំមកហើយ ហើយគាត់បានរកឃើញដួងព្រលឹងរបស់គាត់វិញនៅក្នុងល្ខោននិយាយនេះ" ។ គាត់ជឿថា សិល្បៈដូចជាសិល្បៈល្ខោននិយាយរបស់អ្នកស្រី ព្រីន បានជួយឲ្យប្រជាជនកម្ពុជាទាំងអស់ផ្តល់តម្លៃទៅលើភាពស្រស់ស្អាតនៅក្នុងភាពងងឹតនៃបទពិសោធន៍វិបត្តិផ្លូវចិត្តដ៏ជូរចត់ ។



ឈុតមួយនៃការសម្តែងក្នុងរឿងទម្លាយភាពស្ងប់ស្ងាត់

"រឿងទម្លាយភាពស្ងប់ស្ងាត់" របស់អ្នកស្រី ព្រីន មានគម្រោងសម្រាប់ដំណើរទស្សនកិច្ចក្នុងប្រទេសជាមួយនិងជំនួយពីស្ថានទូតរបស់រាជាណាចក្រហុល្លង់និងអង្គការមួយចំនួនទៀតដែលក្នុងនោះរួមមានមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានផ្តល់នូវការសិក្សាស្រាវជ្រាវ ហើយនឹងនាំផលិតកម្មនេះទៅកាន់ខេត្តផ្សេងៗដែលជាផ្នែកមួយនៃសកម្មភាពចម្បងរបស់ខ្លួន ។ ល្ខោនដែលអាចធ្វើការចល័តបាន នឹងត្រូវបានរៀបចំសម្រាប់នាំយកល្ខោននេះទៅផ្សាយជូនទស្សនាចាប់ពីក្រុងភ្នំពេញ និងតាមជនបទ ។

## ដំណើរទស្សនកិច្ចដំបូងនៅក្នុងខេត្ត កំពង់ចាម

*កាលពីថ្ងៃទី២៥ និង២៦ ខែកុម្ភៈ ល្ខោននេះត្រូវបានសម្តែងជូនទស្សនានៅឃុំរការពោធិ៍៥ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ ឆាកសម្តែងត្រូវបានរៀបចំនៅក្នុងទីធ្លាផ្ទះដែលស្ថិតក្នុងបរិវេណការិយាល័យស្រុក ។ ដោយសារតែនេះគឺជាដំណើរទស្សនកិច្ចដំបូង ការសម្តែងនេះបានចំណាយអស់រយៈពេលពីរថ្ងៃដើម្បីរៀបចំការដឹកនាំសំខាន់រួមមានដូចជាការតុបតែងឆាក និងរៀបចំការអញ្ជើញចូលរួមសហការពីអាជ្ញាធរក្នុងតំបន់ ។*

*ការសម្តែងបានចាប់ផ្តើមនៅវេលាម៉ោង៧ក្នុងយប់ដំបូង ។ មានមនុស្សជាច្រើនកុះករ លើសពីប្រាំរយនាក់មកទស្សនានៅយប់ដំបូង ដែលក្មេងៗប្រហែលមួយរយនាក់អង្គុយលើកន្ទេល មនុស្សវ័យកណ្តាលចំនួន ២៥០នាក់បានអង្គុយលើកៅអី និង ២០០នាក់ទៀតបានឈរមើលល្ខោននិយាយនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញនិស្សិតមកពីប្រទេសន័រវ៉េ ឲ្យចូលរួមទស្សនាដើម្បីធ្វើការស្វែងយល់ឲ្យកាន់តែច្រើនអំពីអំឡុងពេលរបបខ្មែរក្រហម និងលទ្ធផលរបស់របបនេះ ។ ការសរសេរប្រែសម្រួលជាភាសាដទៃទៀតត្រូវបានបង្ហាញសម្រាប់និស្សិតទាំងនោះ ។*

*ទស្សនិកជនបានទះដៃសាទរយ៉ាងស្រុះគ្នានៅចុងបញ្ចប់ល្ខោននេះ ។ មានបុរសវ័យចំណាស់ម្នាក់បានក្រោកឈរ និងនិយាយអំពីសកម្មភាពសាហាវឃោរឃៅរបស់កម្មាភិបាលខ្មែរក្រហមដែលបានធ្វើចំពោះគាត់នៅពេលគាត់ត្រូវបានជាប់ឃុំឃាំងក្នុងខេត្តកំពង់ចាម ។ គាត់និយាយថាគាត់ពេញចិត្តនឹងល្ខោននេះណាស់ ប៉ុន្តែរាល់សកម្មភាពសាហាវឃោរឃៅរបស់ពួកខ្មែរ-ក្រហមក្នុងល្ខោននេះមិនទាន់ដូចជីវិតពិតដែលគាត់ធ្លាប់បានឆ្លងកាត់នៅក្នុងអំពើប្រល័យពូជសាសន៍នោះទេ ។ ក្នុងអំឡុងពេល៤៥នាទីសម្រាប់ការសួរសំណួរយុវជនដែលចូលរួមទស្សនាជាច្រើននាក់ បានសួរសំណួរមួយចំនួនដូចជា «ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ខ្មែរគ្នាឯង?» និងសំណួរប្រហាក់ប្រហែលគ្នាដទៃទៀតដែលទាក់ទងនឹងខ្មែរក្រហម ។ លោកនាយក ឆាំង យុ បានចូលរួមនៅក្នុងឆ្លើយនឹងសំណួរទាំងនោះនៅយប់ដំបូង ។*

*នៅថ្ងៃទីពីរ ការសម្តែងបានចាប់ផ្តើមនៅម៉ោង៧ល្ងាច ។ មានមនុស្សចូលរួមតិចជាងយប់ដំបូង គឺប្រហែលជា៤០០នាក់ ។ ការសម្តែងត្រូវបានទទួលការស្វាគមន៍ដ៏ល្អផងដែរ ។ មានក្រុមសិស្សវិទ្យាល័យត្បូងឃ្មុំ២០នាក់បានចូលរួមក្នុងការសម្តែងនេះ ។ ទិសដៅធ្វើដំណើរលើកទីពីរនិងលើកទីបីគឺនៅក្នុងខេត្តកណ្តាលនិងខេត្តតាកែវ ។ ល្ខោននេះមានរយៈពេលពីរថ្ងៃ គឺថ្ងៃទី២៨ ខែកុម្ភៈ និងថ្ងៃទី១ ខែមីនា នៅក្នុងខេត្តកណ្តាល ។ ទោះបីជាយ៉ាងណាក៏ដោយការបញ្ចាំងនៅថ្ងៃដំបូងត្រូវបានរំសាយចោលដោយសារមានភ្លៀងធ្លាក់និងខ្យល់ខ្លាំង ។ ល្ខោននេះសម្តែងបានយ៉ាងជោគជ័យនៅយប់ថ្ងៃបន្ទាប់ ទោះបីជាមានការរំខានពីសត្វល្អិតជាច្រើនដែលហើរជុំវិញអំពូលភ្លើង ជាហេតុបង្កការលំបាកដល់តួសម្តែង ។ សរុបមក មានកូនក្មេងនិងមនុស្សធំប្រហែល៥០០នាក់ បានមកមើលល្ខោននៅក្នុងខេត្តកណ្តាល ។ នៅក្នុងខេត្តតាកែវវិញ ល្ខោនបានសម្តែងនៅថ្ងៃចុងសប្តាហ៍ គឺនៅថ្ងៃទី៧និងទី៨ ខែមីនា ។ ឆាកបានសង់ឡើងនៅលើទីវាលលេងបាល់ទាត់ នៅវត្តរំលក ក្នុងឃុំបាស្រែ ស្រុកអង្គរបូរី ។ ដំណើរសម្តែងលើកទីបួននេះមានទីតាំងដដែលនិងបានទាក់ទាញទស្សនិកជនជាច្រើន ទោះបីជាមានភ្លៀងរលឹមនៅពេលល្ងាចក៏ដោយ ។*

**សើ សាយ្យណា**



*ឈុតមួយនៃការសម្តែងក្នុងរឿងទម្លាយភាពស្ងប់ស្ងាត់*

# មួយជីវិតនឹកឃើញជានិច្ច

ខ្ញុំបាទឈ្មោះ សិន ឌល់ឡោះ អាយុ៥៦ឆ្នាំ ជាគ្រូបង្រៀនសាសនាឥស្លាម មានស្រុកកំណើតនៅភូមិកំពង់កណ្ដាល ឃុំក្បាលរមាស ស្រុកកំពត ខេត្តកំពត ។

នៅថ្ងៃទី១៧ ខែមេសា កងទ័ពអាវខ្មៅពាក់ស្បែកជើងកង់ឡានដែលប្រដាប់ដោយអាវុធគ្រប់ដៃបានសម្រុកចូលមកទីក្រុងភ្នំពេញ ហើយបង្ខំឲ្យប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងទាំងអស់ចាកចេញពីផ្ទះ ។ អ្នកដែលមិនព្រមចាកចេញពីផ្ទះឬចេញទៅយឺតយ៉ាវ ត្រូវទាហានអាវខ្មៅខ្មែរក្រហមបាញ់ចោលយ៉ាងកម្រោលនិងឃោរឃៅជាទីបំផុត ។ ដោយឃើញសភាពការណ៍បែបនេះ ប្រជាពលរដ្ឋទាំងអស់មានការភ័យតក់ស្លុតយ៉ាងខ្លាំង ដោយមួយចំនួនយកអីវ៉ាន់បានបន្តិចបន្តួចដាក់តាមខ្លួន និងមួយចំនួនទៀតក៏មិនបានយកអ្វីមកជាប់នឹងខ្លួនដែរ រួចនាំកូនចៅចាកចេញពីផ្ទះដោយថ្មើរជើងទៅតាមទិសដៅដែលទាហានអាវខ្មៅខ្មែរក្រហមបញ្ជាឲ្យទៅ ។ នៅពេលនោះ ខ្ញុំព្រមទាំងប្រជាពលរដ្ឋរាប់ម៉ឺននាក់បានធ្វើដំណើរចាកចេញតាមបណ្ដោយផ្លូវជាតិលេខ៤ ក៏បានឃើញទាហានអាវខ្មៅក្មេងៗជាច្រើនឆែកឆេរយករបស់របរមានតម្លៃពីប្រជាពលរដ្ឋដូចជា៖ មាស នាឡិកាដៃ និងខោអាវល្អៗតាមអំពើចិត្ត និងឃើញមានជនស៊ីវិលនិងទាហានជាច្រើនស្លាប់គួរឲ្យអាសូរដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ថាមិនយូរប៉ុន្មានទេ ខ្ញុំនឹងត្រូវគេសម្លាប់ចោលជាមិនខាន ដោយចោទថាជាទាហានឬជាសេអ៊ីអា ។ នៅពេលខ្ញុំនិងបងប្អូនជីដូនមួយ៦នាក់ព្រមទាំងមិត្តភក្តិរបស់ខ្ញុំ២នាក់ទៀតបានធ្វើដំណើររហូតដល់ថ្នល់ទទឹង ស្រាប់តែត្រូវទាហានអាវខ្មៅខ្មែរក្រហមបញ្ជាឲ្យដើរទៅទិសខាងត្បូងតាមផ្លូវលំមួយរហូតដល់ស្រុកត្រាំខ្នារវិញ ។ សម្រាកនៅទីនោះមួយយប់ ខ្ញុំនិងបងប្អូនជីដូនមួយ ព្រមទាំងមិត្តភក្តិ២នាក់ទៀត ក៏សម្រេចចិត្តធ្វើដំណើរទៅខេត្តកំពតដែលជាស្រុកកំណើតរបស់យើងទាំងអស់គ្នាដើម្បីស្វែងរកឪពុកម្ដាយនិងបងប្អូន ។ ខ្ញុំព្យាយាមសួរពីដំណឹងបងប្អូនតាមតាមផ្លូវរហូតតែគ្មានដំណឹងសោះ ។ ធ្វើដំណើរអស់រយៈពេល១០ថ្ងៃ ខ្ញុំក៏បានមកដល់ភូមិឆ្នាំ ខាងលិចផ្សារឈូក ដែលនៅទីនោះបងប្អូនចាមពីរគ្រួសារបាននិយាយប្រាប់ខ្ញុំថា «ចាមយើងត្រូវខ្មែរក្រហមជម្លៀសទៅស្រុកកំពង់ត្រាចអស់ហើយ» ។ ពួដូច្នេះខ្ញុំនិងមិត្ត២នាក់ ព្រមទាំងបងប្អូនជីដូនមួយ ក៏សម្រេចចិត្តចែកផ្លូវគ្នាដើម្បីស្វែងរកគ្រួសាររៀងៗខ្លួន ដោយខ្លះធ្វើដំណើរទៅស្រុកវាលរេញ ហើយខ្លះទៀតទៅស្រុកកូនសត្វ ។ នៅពេលជិតភ្លឺខ្ញុំបានធ្វើដំណើរតែម្នាក់ឯងដោយមានខោអាវមួយបង្កិចស្ពាយជាប់នឹងខ្លួន ចេញតាមផ្លូវលំទៅកាន់ទិសខាងត្បូង រហូតដល់ភូមិក្រាំងលាវ ទើបចូលសម្រាកនៅក្នុងវត្តមួយ ។ នៅទីនោះ ខ្ញុំបានជួបឪពុកមារបស់ម្ដាយខ្ញុំនៅក្នុងសាលារៀនក្បែរនោះ ។ ក្រោយពីសួរសុខទុក្ខគ្នារួច ខ្ញុំក៏បានសួរគាត់អំពីដំណឹងរបស់ក្រុមគ្រួសារខ្ញុំដែលបានចេញពីក្រុងកំពតមក តើគាត់ទៅស្នាក់នៅទីណា? ក្រោយពីគាត់ប្រាប់ថាឪពុកម្ដាយខ្ញុំត្រូវអង្គការអាវខ្មៅបញ្ជូនទៅរស់នៅភ្នំពានឬភ្នំលាវ ដែលស្ថិតនៅទិសខាងកើតភ្នំកែប ក្បែរមាត់សមុទ្រ ស្អែកឡើងម៉ោងប្រហែលជា៤ភ្លឺ ខ្ញុំក៏រៀបចំចេញដំណើរតទៅទៀត ។ មុនចេញដំណើរ ឪពុកមាខ្ញុំឈរយំ រួចនិយាយថា «យើងមិនដឹងជាថ្ងៃណាបានជួបគ្នាទៀតទេ ដូចឯងឃើញស្រាប់ហើយទិសដៅរបស់យើងមិនដឹងជានៅទីណាទេ ម្យ៉ាងទៀតឃើញតែខ្មែរក្រហមចាប់ចងពល់តែថ្ងៃ យកទៅបាត់ៗ» ។ ពាក្យសម្ដីបែបនេះ ខ្ញុំមានការអាណិតអាសូរគាត់យ៉ាងខ្លាំង រួចខ្ញុំចាប់ដៃនិងសុំលាគាត់ ។ នៅតាមដងផ្លូវមានសភាពស្ងាត់ជ្រងំ យូរៗទើបខ្ញុំឃើញមានមនុស្ស៤-៥នាក់ធ្វើដំណើរ តែមិនដឹងអ្នកទាំងនោះធ្វើដំណើរទៅទីណាទេ រហូតដល់ម៉ោង១១ថ្ងៃត្រង់ ខ្ញុំក៏បានមកដល់ផ្សារកំពង់ត្រាច ។ ដោយសារតែធ្វើដំណើរអស់កម្លាំងនិងគ្មានអ្វីហូប នៅតាមផ្លូវខ្ញុំក៏សុំទឹកអ្នកមូលដ្ឋាននៅក្បែរនោះហូប ។ ពេលនោះស្រាប់តែម្ចាស់ផ្ទះសម្លឹងមើលមុខខ្ញុំ រួចសួរខ្ញុំថា មិត្តឯងមកពីណា? ក្រោយពីខ្ញុំប្រាប់ថា «ខ្ញុំមកពីភ្នំពេញមករកគ្រួសារដែលមករស់នៅភ្នំលាវ» ម្ចាស់ផ្ទះក៏សួរសំឡុតវិញថា មិត្តឯងជាទាហានមែនទេ? ពីព្រោះបើមើលតាមដៃជើង មិត្តឯងជាអ្នកធំ មិនមែនជាប្រជារាស្ត្រធម្មតានោះទេ ។ ដោយឃើញសភាពដូច្នេះ ខ្ញុំក៏ឆ្លើយថា «អឺអើយ! ព្រោះតែ

ខ្លាច លន់ នល់ ចាប់ខ្ញុំធ្វើទាហាន ទើបខ្ញុំរត់ពីខេត្តកំពតទៅរកស៊ីចិញ្ចឹមគ្រួសារនៅប្រាំងចំរេះ ហើយដោយសារនឹកឪពុកម្ដាយខ្លាំងពេក ខ្ញុំក៏ដើរមករកគាត់តាមសម្ដីដែលបងប្អូនប្រាប់» ។ ក្រោយពីឮខ្ញុំប្រាប់ដូច្នេះ ម្ចាស់ផ្ទះក៏ចង្អុលប្រាប់ថា ដើរតាមបណ្ដោយផ្លូវហ្នឹងទៅប្រហែលជា១០គីឡូម៉ែត្រ នឹងដល់ហើយ ។ បន្ទាប់មក ខ្ញុំក៏សុំលាគាត់ដោយគិតក្នុងចិត្តថា «កុំថាឡើយកងឈ្លប កងទ័ព សូម្បីតែប្រជាជនក៏សួររកទាហានដែរ ដូច្នេះមានន័យថាខ្មែរក្រហមប្រាកដជាមានគំនុំជាមួយនឹងទាហាន លន់ នល់ ។ បើសិនជាខ្មែរក្រហមចងគំនុំបែបនេះ អ្នកដែលចេញពីទីក្រុងមិនដឹងថាត្រូវខ្មែរក្រហមធ្វើបាបយ៉ាងណានោះទេ» ។ ដើរបណ្ដើរខ្ញុំគិតបណ្ដើររហូតដល់ថ្ងៃរៀបលិចទើបខ្ញុំបានទៅដល់ភូមិខ្វារ ដែលស្ថិតនៅមិនឆ្ងាយពីភូមិលាវ រួចបានសួរប្រជាជនដែលរស់នៅកន្លែងនោះទៀត ។ ធ្វើដំណើរមកដល់វត្តមួយនៅភូមិលាវ ខ្ញុំក៏បានឃើញបុរសម្នាក់និងក្មេងម្នាក់ចុះមកពីលើសាលាឆាន់ ។ ដោយស្គាល់ច្បាស់ថាជា តាកូប ដែលជាជីដូនមួយម្ដាយរបស់ខ្ញុំ ខ្ញុំបានស្ទុះទៅឱបគាត់ដោយក្ដីនឹករឭក ។ ជាមួយគ្នានេះដែរ គាត់ដូចជាមានការភ្ញាក់ផ្អើលដែលឃើញមុខខ្ញុំ ព្រោះ៥-៦ឆ្នាំកន្លងមកហើយដែលគាត់មិនដែលបានឮដំណឹងពីខ្ញុំ ។ បន្ទាប់មកគាត់បានប្រើកូនរបស់គាត់ឲ្យទៅហៅឪពុកម្ដាយខ្ញុំ ។ មួយសន្ទុះក្រោយមក ខ្ញុំបានឮសំឡេងស្រែកថាបង១ ។ ដោយដឹងច្បាស់ថាជាប្អូនរបស់ខ្ញុំទាំងពីរ ខ្ញុំស្ទុះទៅឱបប្អូនៗដោយក្ដីនឹករឭកជាទីបំផុត រួចសុំលាតាកូបទៅភូមិពូនទាំងយប់ ដែលជាកន្លែងឪពុកម្ដាយខ្ញុំរស់នៅ ។ ដើរកាត់វាលស្រែដែលសម្បូរទៅដោយដីដំបូកជាច្រើននិងព្រៃក្រាស់ៗស្ងាត់ជ្រងំដែលគ្មានមនុស្សហ៊ានដើរទៅជិត ខ្ញុំក៏បានឃើញ ឪពុកម្ដាយខ្ញុំអង្គុយក្បែរភ្លក់ភ្លើង ។ ខ្ញុំឱបគាត់ទាំងពីរនិងប្អូនៗឯទៀតដោយក្ដីសប្បាយរីករាយលាយឡំជាមួយនឹងទឹកភ្នែក ។ ក្រោយមក ឪពុកខ្ញុំក៏សួរខ្ញុំពីដំណើររឿងចាប់តាំងពីភ្នំពេញរហូតមកដល់ភូមិពូន ។ ក្រោយពីខ្ញុំបានរៀបរាប់ពីការធ្វើដំណើរអស់រយៈពេល៣១ថ្ងៃ ចាប់ពីទីក្រុងភ្នំពេញរហូតដល់ភូមិលាវនេះគាត់និយាយថា «សំណាងណាស់ដែលព្រះអាឡោះបានឲ្យឯងស្ងើម៉ាត់ (សុខសាន្ត)រហូតមក ។ ពុកគ្មានសង្ឃឹមថាបានជួបឯងម្ដងទៀតទេ ពីព្រោះអាយុប្រហែលឯងនេះត្រូវខ្មែរក្រហមពាក់អាវខ្មៅចាប់ចងជាខ្សែៗ ដេកស្លាប់ស្មើគ្រប់ទីកន្លែង» ។ ពេលភ្លឺឡើងស្រាប់តែមេភូមិម្នាក់បានមកដល់ផ្ទះរបស់ខ្ញុំ រួចសួរថាយប់មិញមានមនុស្សប្លែកមកស្នាក់នៅផ្ទះអ៊ំមែនទេ? ពេលនោះឪពុកខ្ញុំបានឆ្លើយថា វាជាកូនរបស់ខ្ញុំ វាទើបតែមករកខ្ញុំឃើញ ។ ភ្លាមនោះ ខ្ញុំក្រោកឡើង ហើយឆ្លើយថាខ្ញុំមកពីទីក្រុងភ្នំពេញ ។ ដោយមិនអស់ចិត្ត គាត់សួរបន្តទៀតថាប្អូនឯងនៅភ្នំពេញធ្វើជាទាហានឲ្យ លន់ នល់ មែនទេ? ខ្ញុំឆ្លើយថា ខ្ញុំរត់ពីខេត្តកំពតទៅរស់នៅភ្នំពេញ ដោយសារតែគេដេញចាប់ឲ្យធ្វើជាទាហាន ។ មេភូមិមិនជឿទេដោយនិយាយថា «សាច់ឈាមដូចមិត្តច្បាស់ជាធ្វើទាហានហើយ តូចណាស់ក៏ស័ក្តិបីដែរ មិត្តឯងកុំកុហក អង្គការមិនធ្វើបាបមិត្តឯងទេ ប្រាប់ឲ្យត្រង់ៗមក» ។ ខ្ញុំឆ្លើយនូវពាក្យដដែលថា ខ្ញុំមិនដែលធ្វើជាទាហានទេ គ្រាន់តែជាអ្នកស៊ីឈ្នួលចាំត្រីឲ្យគេគ្រាន់ចិញ្ចឹមជីវិតតែប៉ុណ្ណោះ» ។ ម្ដាយខ្ញុំព្យាយាមអង្វរគាត់ដែរថា «កូនខ្ញុំមិនដែលធ្វើជាទាហានទេ បើអ៊ំមិនជឿ សួរបងប្អូនដែលមកជាមួយខ្ញុំចុះ ប៉ុន្តែពេលសួររួចសូមអ៊ំបញ្ចូលឈ្មោះវានៅក្នុងគ្រួសារខ្ញុំផង» ។ ពេលនោះមេភូមិនៅស្ងៀម រួចនិយាយថា ចាំខ្ញុំសួរយោបល់ថ្នាក់លើសិន ។ ប្រហែលជាម៉ោង៥ល្ងាច មេភូមិបានត្រឡប់មកផ្ទះខ្ញុំម្ដងទៀតរួចនិយាយថា «ថ្នាក់លើអនុញ្ញាតិឲ្យដាក់ឈ្មោះនេះហើយ តែមីងនិងពូត្រូវសន្យាថា បើថ្ងៃក្រោយថ្នាក់លើរកឃើញថាមិត្តនេះជាទាហាន មីងនិងពូត្រូវទទួលខុសត្រូវដោយខ្លួនឯងចំពោះមុខអង្គការ ហើយចាប់ពីថ្ងៃស្អែកទៅត្រូវឲ្យមិត្តនេះទៅធ្វើការនៅឯវាលស្ពឺយ ជាមួយយុវជននិងយុវនារីដែលកំពុងរំលើងគល់ធ្វើស្រែថ្មី» ។ ថ្ងៃមួយពេលដែលខ្ញុំកំពុងធ្វើការ ក៏បានឃើញចិនម្នាក់ត្រូវអង្គការយកទៅកសាងដោយសារតែបានធ្វើឲ្យបាក់ដងចបរបស់អង្គការ ។ រយៈពេលពីរបីថ្ងៃ ទើបមេកងប្រាប់ថា មិត្តនោះអង្គការឲ្យទៅរស់នៅភូមិថ្មីហើយ ។ ពេលនោះអ្នកដែលធ្វើការជាមួយខ្ញុំមិនយល់ពីអ្វីដែលហៅថាភូមិថ្មីនោះទេ ។ ដោយសារតែឆ្ងល់និងចេះតែលួចសួរគ្នាពីម្នាក់ទៅម្នាក់ ស្រាប់តែមានបុរសម្នាក់ដែលមានបងប្អូនជាអ្នកមូលដ្ឋានមកប្រាប់ខ្ញុំតិចៗថា គេយកទៅវាយចោលបាត់ហើយ ។ គ្រាន់តែឮដូច្នេះភ្លាម យើងទាំងអស់គ្នាទន់ដៃទន់ជើងស្មើរតែដើរមិនរួច ។ ជារៀងរាល់ថ្ងៃ ខ្ញុំធ្វើការស្មើរតែគ្មានពេលសម្រាក ពេលព្រឹកចាប់តាំងពីម៉ោង៧ដល់ម៉ោង១១ថ្ងៃត្រង់ និងពេលល្ងាចពីម៉ោង១ដល់ម៉ោង៥ ប៉ុន្តែអាហារ

ដែលខ្ញុំទទួលបានគឺតិច ហូបមិនគ្រប់គ្រាន់ទេ ។ ហេតុនេះហើយបានជាពីមួយថ្ងៃទៅមួយថ្ងៃ កសិករថ្មីចេះតែមានជំងឺច្រើនឡើងៗរហូតដល់ខ្លះមិនអាចមកធ្វើការបាននិងហ៊ានលួចដំឡូងនិងរបស់ហូបផ្សេងៗទៀត ដោយមិនខ្លាចអង្គការយកទៅសម្លាប់ ។ ពីមួយខែទៅមួយខែ ដោយរបបអាហារកាន់តែតិចទៅៗ ខ្ញុំក៏មានជំងឺធ្លាក់ឈាមសន្លប់មិនដឹងខ្លួនត្រូវបញ្ជូនទៅកាន់មន្ទីរពេទ្យនៅវត្តភ្នំលាវ ដែលមានឈ្មោះថាមន្ទីរពេទ្យសង្គមកិច្ចដើម្បីព្យាបាល ។ សម្រាកនៅមន្ទីរពេទ្យអស់រយៈពេល៨ថ្ងៃ ជំងឺរបស់ខ្ញុំនៅមិនជាសះស្បើយឡើយ ព្រោះអង្គការផ្តល់ថ្នាំឲ្យខ្ញុំលេបតែថ្នាំអាចម៍ទន្សាយប៉ុណ្ណោះ ។ ថ្ងៃមួយមានតាចាស់ម្នាក់ប្រាប់ខ្ញុំថា ក្មួយឯងរកពន្លៃនិងអំបិលបុកផឹកទៅ វានឹងបាត់ហើយ ។ ក្រោយពីខ្ញុំធ្វើតាមអាការៈរបស់ខ្ញុំក៏បានធូរស្បើយបន្តិច ។ បន្ទាប់មកប្រធានមន្ទីរពេទ្យក៏អនុញ្ញាតឲ្យខ្ញុំត្រឡប់មកផ្ទះវិញ ។ មកដល់ផ្ទះមិនបានប៉ុន្មានថ្ងៃផង បងប្អូនចាមទាំងអស់ត្រូវខ្មែរក្រហមផ្លាស់ឲ្យទៅរស់នៅភូមិផ្សេងៗពីគ្នា ចំណែកឯក្រុមគ្រួសាររបស់ខ្ញុំនិងបីគ្រួសារទៀតត្រូវផ្លាស់ឲ្យមករស់នៅភូមិទួលស្រង៉ាំដែរ ។

នៅដើមឆ្នាំ១៩៧៧ បងប្អូនរបស់ខ្ញុំ៤នាក់ ត្រូវខ្មែរក្រហមផ្លាស់ឲ្យទៅរស់នៅជាមួយសមាជិក កងចល័តយុវជនយុវនារី ដោយមិនអនុញ្ញាតឲ្យមករស់នៅជាមួយឪពុកម្តាយទេ ។ ឯរូបខ្ញុំនិងយុវជនម្នាក់ទៀតឈ្មោះ ទីង ត្រូវកាប់ខសឲ្យបានមួយរទេះក្នុងមួយថ្ងៃដើម្បីផ្តល់ឲ្យរោងបាយសមូហភាព ។ ដោយសារជារៀងរាល់ថ្ងៃយើងទាំងពីរនាក់ផ្តល់ខសឲ្យរោងបាយមិនដែលខ្វះ ទើបធ្វើឲ្យអ្នកមូលដ្ឋានច្រណែន រួចរាយការណ៍ប្រាប់មេកងឲ្យធ្វើបាបយើងទាំងពីរ ។ មេកងបានបញ្ជាឲ្យយើងទៅកាប់រំលំដើមខ្នុរមួយដើមដែលដុះក្បែរស្រះទឹកនិងនៅលើភ្លឺ ។ «យើងដឹងថា ប្រសិនបើយើងកាប់ដើមខ្នុរនោះរលំចូលក្នុងស្រែឬស្រះទឹក អង្គការនឹងចោទយើងថាជាខ្មាំង តែយើងមិនអាចប្រកែកបានទេ» ។ ដោយសារការបន់ស្រន់និងសុំខ្ចីអាពីអាល់ឡោះឲ្យបាន ស្ទីម៉ាត់ក្នុងការរំលំដើមឈើនោះ យើងក៏កាប់ដើមឈើនោះរលំទៅតាមបណ្តោយភ្លឺស្រែ ដោយគ្មានធ្លាក់ចូលក្នុងទឹក ឬក៏ខូចស្រូវក្នុងស្រែឡើយ ។ ក្រោយពីរំលំរួច មេកងក៏ដើរមកត្រួតពិនិត្យមើលហើយសួរខ្ញុំថាមិត្តឯងចេះកាប់ពីណាមក? ខ្ញុំក៏ឆ្លើយថា ខ្ញុំធ្លាប់ធ្វើការងារនេះពីមុនមក ម្យ៉ាងទៀតឪពុករបស់ខ្ញុំធ្លាប់បង្រៀនកាលខ្ញុំនៅឯស្រុក ។ សួររួចមេកងក៏ត្រឡប់ទៅវិញ ហើយយើងទាំងពីរនាក់ក៏បន្តកាប់ខសតទៅទៀត ។ ខ្មែរក្រហមបានជ្រើសរើសខ្ញុំឲ្យធ្វើជាកងចល័តលើកទំនប់នៅកោះស្លា ស្រុកកំពង់ត្រាច ។ ធ្វើដំណើររយៈពេល២ថ្ងៃ ខ្ញុំនិងកងចល័តស្រុកកំពង់ត្រាច ទាំងយុវជននិងយុវនារី សរុបចំនួន ១,៦០០នាក់ ក៏បានមកដល់កោះស្លា ។ នៅទីនោះខ្ញុំឃើញនៅជុំវិញមានសុទ្ធតែព្រៃ ដោយមានដើមឈើខ្ពស់ៗស្វាត់ជ្រងំនិងគ្មានផ្ទះសម្បែងនៅក្បែរនោះទេ ។ ខ្ញុំតែងតែព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនណាស់ក្រោយពីមិត្តខ្ញុំម្នាក់ដែលជាអ្នកមូលដ្ឋានត្រៀមបានប្រាប់ខ្ញុំថា «កន្លែងនេះ គេយកមនុស្សមកវាយចោលច្រើនណាស់ យើងត្រូវតែមានការប្រុងប្រយ័ត្ន កុំនិយាយអ៊ីផ្តេសផ្តាសគិតតែពីធ្វើការទៅ ទោះបីជាការហូបចុកមានការខ្វះខាតយ៉ាងណាក៏ដោយ» ។ ក្នុងរយៈពេល៥ខែនេះ យើងទាំងអស់គ្នាហូបមិនបានគ្រប់គ្រាន់ ការងារធ្វើគ្មានពេលសម្រាក ដែលជាហេតុធ្វើឲ្យយើងទាំងអស់គ្នាខ្លះមានជំងឺគ្រុនចាញ់ រាក ពស់ចឹក ហើយខ្លះទៀតត្រូវបាត់ខ្លួនដោយមិនដឹងមូលហេតុ ដែលសរុបមកស្លាប់៤០នាក់និងបាត់ខ្លួនជាង២០នាក់ ។ ចំណែកនៅស្រុកកំពតវិញ ប្រជាជនស្លាប់ជាង៤០០នាក់ បន្ទាប់មកស្រុកទូកមាស ពីព្រោះស្រុកទាំងពីរនេះជាស្រុកដែលមានការខ្វះខាតច្រើនជាងគេ ។ ពេលធ្វើទំនប់ចប់ យើងទាំងអស់គ្នាក៏ធ្វើដំណើរត្រឡប់មកកែបវិញ ហើយចូលសម្រាកនៅក្នុងផ្ទះថ្មមួយដែលគ្មានបង្អួចនិងទ្វារ ។ ស្អែកឡើងយើងនាំគ្នាធ្វើរបងនិងទៅចាប់ត្រី ដោយក្នុងមួយថ្ងៃចាប់បានយ៉ាងតិច៥០០គីឡូ ។

នៅខែមិថុនា ឆ្នាំ១៩៧៨ ពេលខ្ញុំត្រឡប់មកលេងផ្ទះវិញ ខ្ញុំក៏សួរបងប្អូននៅក្នុងភូមិថាដែលបានត្រីហូបទេ? នៅពេលអ្នកភូមិនិងបងប្អូនរបស់ខ្ញុំឆ្លើយថា មិនដែលបានត្រីហូបទេ ។ ខ្ញុំមានចម្ងល់យ៉ាងខ្លាំងថាតើខ្មែរក្រហមយកត្រីទៅណាបានជាមិនឲ្យប្រជាជនហូប ព្រោះខ្ញុំទៅអូសមោងបានត្រីមិនដែលខានថ្ងៃណាឡើយ ។ ចាប់ពីថ្ងៃនោះមក នៅក្នុងស្រុកមានសភាពច្របូកច្របល់យ៉ាងខ្លាំង ដោយសារអង្គការចេះតែបាត់នេះបាត់នោះមិនចេះចប់ ហើយនៅតាមព្រំដែនមានសភាពការណ៍មិនសូវស្រួលដែរ ។ នៅថ្ងៃទី២ ឬថ្ងៃទី៣ ប្រធានកងនៅក្នុងភូមិម្នាក់បានមកឆែកឆេរគ្រប់

ផ្ទះទាំងអស់ រួមទាំងផ្ទះរបស់ខ្ញុំផងដើម្បីរកចានស្ពាបព្រាដែលបាត់ ។ ក្រោយពីឆែកឆេររកមិនឃើញ ប្រធានកងក៏មកអង្គុយនៅលើរានដែលខ្ញុំធ្លាប់ដេក រួចឃើញនៅលើរាននោះមានសៀវភៅគីតាបជាច្រើនរបស់ខ្ញុំ ប្រហែលជាមួយបាវដែលខ្ញុំបានលាក់ទុកជាយូរមកហើយ ។ ពេលនោះ ម្ដាយរបស់ខ្ញុំដែលនៅចាំផ្ទះមានការភ័យតក់ស្លុតយ៉ាងខ្លាំង រួចក៏អង្វរមេកងនោះថា «នេះគឺជាសៀវភៅធម៌ទេ» ។ ក្រោយមក មេកងនោះឆ្លើយថា «យាយឯងចង់សាប់ឬ នេះគឺជាខ្មាំងបង្កប់ទេ» រួចក៏ហៅកងឈ្លបផ្សេងទៀតឲ្យមកយកសៀវភៅទាំងអស់នោះទៅរោងបាយ ។ នៅយប់នោះអង្គការបានប្រជុំសម្រេចថានឹងយកខ្ញុំទៅរស់នៅកែប ។ ស្អែកឡើងស្រាប់តែមានយុវជនម្នាក់រត់មកជួបខ្ញុំ ហើយនិយាយថា បងខ្ញុំស្រឡាញ់បងណាស់ សូមបងគិតមើលទៅ សៀវភៅរបស់បងគេរកឃើញអស់ហើយ គេប្រជុំសម្រេចថានឹងមកយកបងនៅស្អែកនេះហើយ តើបងគិតធ្វើយ៉ាងម៉េច? ឮភ្លាម ខ្ញុំទន់ដៃទន់ជើងរកធ្វើអ្វីមិនកើតទេ រួចក៏ឆ្លើយថាប្អូនបងមិនដឹងធ្វើដូចម្ដេចទេ យុវជនរូបនោះក៏និយាយថា បងយកទូករត់ទៅស្រុកយួនទៅ បើមិនទៅបងប្រាកដជាស្លាប់ហើយ ។ កំពុងតែនិយាយគ្នា ស្រាប់តែងាកទៅឃើញមេក្រុមដើរមក រួចខ្ញុំក៏បែកគ្នាទៅកន្លែងរៀងៗខ្លួន ។ ពេលត្រឡប់មកដល់ក្នុងផ្ទះ ខ្ញុំពិបាកចិត្តខ្លាំងណាស់ សូម្បីតែដេកក៏មិនលក់ដែរ រហូតដល់ម៉ោងប្រហែលជា១១យប់ ទើបខ្ញុំដើរទៅមាត់សមុទ្រក្រោយកន្លែងដេកអង្គុយនៅក្បែរទូក ដែលខ្ញុំដាក់មោងរាល់ថ្ងៃ ។ ប្រហែលមួយម៉ោងក្រោយមក ខ្ញុំក៏សម្រេចចិត្តថាត្រូវតែរត់ មិនត្រូវនៅចាំគេយកទៅសម្លាប់ទេ ។ កំពុងតែគិតស្នូរកាំភ្លើងបាញ់គ្នានៅជិតភ្នំកែបក៏ផ្ទុះឡើងយ៉ាងខ្លាំង ពេលនោះខ្ញុំឃើញកងទ័ពនៅក្បែរនោះរត់ចេញពីក្នុងផ្ទះរួចប្រាប់គ្នាដែលនៅក្បែរនោះថា ខ្មាំងយួនចូលមកយកក្ដាតបានហើយ វាឡើងមកសុទ្ធតែរថក្រោះតាមទឹក បន្ទាប់មកនៅខាងកើតគ្រាប់ផ្លោងធ្លាក់មកជាច្រើនគ្រាប់ដោយបាញ់ចេញពីភ្នំកូនត្រុំ ហើយធ្លាក់នៅមុំភូមិខ្ញុំ ។ ស្នូរប្រយុទ្ធគ្នាឮសូរកាន់តែខ្លាំងឡើងៗ ឯកងទ័ពដែលនៅជាមួយខ្ញុំក៏នាំគ្នារត់ចេញទៅយកគ្រាប់បែកដើម្បីបោកកម្ទេចទូកប៉េអឺធំៗដែរ ។ ខ្ញុំឮសូរសំឡេងមេបញ្ជាការស្រែកថា យើងថយចេញពីកែបសិនដើម្បីស្វែងរកកន្លែងទប់ទល់នៅផ្លូវជាតិលេខ៣ ព្រោះទ័ពធំរបស់យើងនៅចាំនៅទីនោះ ។ ម៉ោងប្រហែលជា ៣ឬ៤ល្ងាច ខ្មែរក្រហមបានរត់ចុះរត់ឡើងដើម្បីប្រមូលរបស់របរផ្សេងៗនិងអង្ករចានឆ្នាំងដាក់លើរថយន្ត ព្រោះឮមេបញ្ជាការប្រាប់ថាខ្មាំងយួនយកផ្សាររលកបានហើយ ត្រូវចេញដំណើរទៅកាន់ស្រុកកំពង់ត្រាចភ្លាម ។ ប្រហែលជាម៉ោង១រសៀល យើងក៏បានមកដល់ភ្នំទ្រងអណ្ដើក ដែលមានប្រជាជនរាប់ពាន់នាក់រស់នៅជុំគ្នាប្រកបដោយទឹកមុខស្រងូតស្រងាត់ និងភ័យខ្លាច ។ មិនយូរប៉ុន្មានស្នូរកាំភ្លើងក៏ផ្ទុះឡើងយ៉ាងខ្លាំងនៅខាងកើតផ្សាកំពង់ត្រាច ដោយខ្ញុំបានឃើញទាហានអាវខ្មៅរាប់រយ នាក់រត់កាត់តាមបណ្ដោយថ្នល់ ហើយស្រែកថា យើងឡើងទៅផ្លូវជាតិលេខ៤វិញ ព្រោះមិនអាចទប់ទល់នឹងខ្មាំងយួនបានទេ ។ គ្រាន់តែឮដូច្នេះភ្លាម ប្រជាជនរាប់ម៉ឺននាក់និងកងទ័ពអាវខ្មៅបានរត់សំដៅទៅកាន់ភ្នំវល្លិ៍ ប៉ុន្តែខ្ញុំនិងបងប្អូនមួយចំនួនទៀតមិនទាន់ចេញទៅណាទេ ដោយនៅរង់ចាំមើលបន្តិចទៀតសិន ។ ស្នូរកាំភ្លើងចេះតែឮជិតឡើងៗ គ្រាប់កាំភ្លើងធំខ្លះក៏ធ្លាក់មកខាងលិចផ្សារកំពង់ត្រាច ដែលជាហេតុធ្វើឲ្យប្រជាជនមួយចំនួនត្រូវរងរបួស ។ ប៉ុន្តែខ្ញុំបែរជាមានសេចក្ដីសង្ឃឹមនៅក្នុងចិត្តទៅវិញ ព្រោះគិតថានឹងអាចរួចផុតពីក្រញាំបិសាច និងបានជួបជុំជាមួយនឹងក្រុមគ្រួសារបងប្អូននៅពេលខាងមុខ ។ កំពុងតែគិតដូច្នេះ ស្រាប់តែកងឈ្លបអាវខ្មៅ៤ឬ៥នាក់មកដល់ហើយស្រែកថាទៅឲ្យឆាប់ព្រោះខ្មាំងយួនមកដល់ឥឡូវនេះហើយ ។ ដោយខ្លាចកងឈ្លបអាវខ្មៅទាំងនោះ ខ្ញុំនិងមិត្តពីរបីនាក់ទៀតក៏ចេញទៅជាមួយគេឯង នាំគ្នាដើរគេចខ្លួនតាមជើងភ្នំទិសខាងលិចកាត់ព្រៃតូចធំអស់ពេញមួយយប់រហូតដល់ម៉ោង៤ភ្លឺ ទើបបានមកដល់ចម្ការដូង ដួន សំអោក ដែលជាកន្លែងដែលខ្ញុំធ្លាប់កាប់ខសពីមុន ។ នៅទីនោះ ខ្ញុំឃើញមានប្រជាជនរាប់ពាន់នាក់នៅសម្រាកជុំៗគ្នា ។ ដោយស្គាល់ច្បាស់ថាជាប្រជាជនភូមិខ្ញុំទាំងអស់ ខ្ញុំក៏សួរអ្នកទាំងនោះថាមានឃើញឪពុកម្ដាយរបស់ខ្ញុំទេ? មីងម្នាក់បានប្រាប់ខ្ញុំថា ម្ដាយមិត្តឯងនៅខាងនោះ ។ ពេលខ្ញុំក្រឡេកទៅឃើញឪពុកម្ដាយនិងបងប្អូនកំពុងអង្គុយនៅជុំគ្នា ខ្ញុំក៏រត់ទៅជួបគាត់ដោយទឹកមុខសប្បាយរីករាយ ។

មិនយូរប៉ុន្មានមេឃក៏ភ្លឺ ខ្ញុំបាននិយាយទៅកាន់បងប្អូនទាំងអស់ថា យើងត្រូវតែទៅរកកងទ័ពវៀតណាមនៅឯផ្លូវជាតិវិញ

*យើងមិនត្រូវរស់នៅទីនេះទេ គេមិនមែនច្បាំងយកទឹកដីទេ គឺយកមនុស្ស ដូច្នេះកុំជឿតាមសម្តីខ្មែរក្រហមទៀត ។ និយាយរួចខ្ញុំនិងគ្រួសារព្រមទាំងបងប្អូនរាប់ពាន់នាក់បានធ្វើដំណើរសំដៅទៅរកផ្លូវជាតិទាំងអស់គ្នា ដោយមានអ្នកខ្លះដើរ អ្នកខ្លះបររទេះគោ និងអ្នកខ្លះរែក ។ យើងឃើញមានរថក្រោះនិងទាហានជាច្រើនរត់ចេញមកទទួលដោយក្នុងនោះមានទាហានខ្មែរយើងម្នាក់កាន់មេក្រូស្រែកថា "សូមបងប្អូនវិលទៅកាន់ភូមិស្រុកវិញ ព្រោះលែងមានខ្មែរក្រហមទៀតហើយ" ។ ពុំបែបនេះ បងប្អូនទាំងអស់គ្នាស្រែកហ៊ោរដោយសេចក្តីត្រេកអរថា ជយោ! ជយោ!ពន្លឺសន្តិភាពរស់ឡើងវិញហើយ ។ ធ្វើដំណើរអស់រយៈពេលបីថ្ងៃទើបមកដល់ស្រុកភូមិវិញ គឺថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំនិងគ្រួសារក៏ធ្វើដំណើរមកដល់ភូមិ ។ ខ្ញុំសង្កេតឃើញគ្មានផ្ទះសម្បែងអ្វីឡើយ ឃើញតែម៉ាស៊ិតសល់ពាក់កណ្តាលដែលខ្មែរក្រហមវាយចោលមិនអស់ ។ ដូច្នេះយើងក៏យកម៉ាស៊ិតនោះធ្វើជាកន្លែងស្នាក់នៅបណ្តោះអាសន្នសិន ។ ចាប់តាំងពីពេលនោះមក យើងក៏បានរស់នៅដោយសុខសាន្ត ។*

**សិន ឌុលឡោះ**

# ការិយាល័យព័ត៌មានសាធារណៈ

*"ការិយាល័យព័ត៌មានសាធារណៈ" នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលិកទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តនៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងទិសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*"ការិយាល័យព័ត៌មានសាធារណៈ" មានផ្តល់ជូននូវសេវា៣យ៉ាង ៖*

**១) *បណ្ណាល័យ*** *៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។*

**២) មជ្ឈមណ្ឌលអប់រំ** *៖ មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទផងទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។*

**៣) *ក្រុមការងារផ្នែកតុលាការ*** *៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ីវ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។*

# សេចក្តីប្រកាសរកប្តី និងបងថ្លៃជីដូនមួយ

នាងខ្ញុំឈ្មោះ មី សយ អាយុ៥៧ សព្វថ្ងៃរស់នៅភូមិគគី ឃុំគគី ស្រុករមាសហែក ខេត្តស្វាយរៀង។ ខ្ញុំមានកូនប្រុស៥នាក់ ស្លាប់អស់៤នាក់។ ខ្ញុំសូមប្រកាសស្វែងរកប្តីឈ្មោះ គឹម ពុធ (សព្វថ្ងៃគាត់មានអាយុ៦៣ឆ្នាំ) និង បងប្អូនជីដូនមួយឈ្មោះ ឌួង ថន (សព្វថ្ងៃមានអាយុ៤០ឆ្នាំ) មានស្រុកកំណើតនៅភូមិគគី ឃុំគគី ស្រុករមាសហែក ខេត្តស្វាយរៀង។ នៅឆ្នាំ១៩៧៥ ពេលដែលកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះ គ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសទៅរស់នៅខេត្តពោធិ៍សាត់។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាត់តាំងប្តីរបស់ខ្ញុំឲ្យធ្វើការនៅកន្លែងមួយឆ្ងាយពីភូមិ។ ក្រោយមក ប្រជាជននៅក្នុងភូមិបានមកប្រាប់ខ្ញុំថា គាត់ត្រូវអង្គការចាប់ដាក់រថយន្ត រួចបញ្ជូនទៅក្រុងភ្នំពេញ។ ចាប់តាំងពីពេលនោះ ខ្ញុំមិនដែលបានទទួលដំណឹងពីគាត់ឡើយ។ ចំណែក ថន ត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅរស់នៅខេត្តបាត់ដំបង រួចក៏បាត់ខ្លួនរហូតដែរ។

ប្រសិនបើបងប្អូនណាបានស្គាល់ ឬបានឮដំណឹងពីឈ្មោះទាំងពីរខាងលើនេះ សូមមេត្តាទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ខណ្ឌចំការមន ក្រុងភ្នំពេញ។ សូមអរគុណ។

# សេចក្តីប្រកាសរកគ្រួសារបងស្រី

នាងខ្ញុំឈ្មោះ គ្រាន់ ហ៊ុយឆេង ហៅ ឡា សព្វថ្ងៃរស់នៅអាមេរិក មានឪពុកឈ្មោះ គ្រាន់ ម៉ុងឈាង និង ម្តាយឈ្មោះ ឈួ ហ្គេចអេង មានស្រុកកំណើតនៅភូមិផ្សារកំពត ឃុំកំពត ស្រុកកំពត ខេត្តកំពត។ ខ្ញុំជាកូនទី៣ក្នុងចំណោមបងប្អូន១៤នាក់ (ស្រី៧ និងប្រុស៧)។ សូមប្រកាសស្វែងរកក្រុមគ្រួសារបងស្រីឈ្មោះ គ្រាន់ ហ៊ុយគីម ហៅ គ្រាន់ ហ៊ុយឡាន និងប្តីឈ្មោះ ប៉ូ គាន់ មានមុខរបរធ្វើចម្ការម្រេចនៅព្រៃនប់ ខេត្តកំពត។ នៅក្នុងរបបខ្មែរក្រហម គ្រួសាររបស់ ហ៊ុយគីម មានកូនស្រីពីរនាក់ និងប្រុសពីរនាក់ ១) គាន់ ស៊ីឈី (ប្រុស) នៅក្នុងរបបខ្មែរក្រហមអាយុប្រហែល១០ឆ្នាំ, ២) គាន់ ស៊ីងី (ប្រុស) អាយុប្រហែល៨-៩ឆ្នាំ, ៣) គាន់ ស៊ុនឡេង (ស្រី) អាយុ៥ឆ្នាំ និង ៤) គាន់ ស៊ុនអ័ង (ស្រី) អាយុ៤ឆ្នាំ។ មួយសប្តាហ៍មុនពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ គ្រួសាររបស់ ហ៊ុយគីម រស់នៅផ្សារកំពង់សោម ខេត្តកំពង់សោម។ ក្រោយមក ខ្ញុំបានទទួលដំណឹងថា គ្រួសាររបស់ ហ៊ុយគីម បានចុះឈ្មោះទៅរស់នៅប្រទេសវៀតណាម។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលទទួលបានដំណឹងពីគ្រួសារ របស់ ហ៊ុយគីម ទេ។

ប្រសិនបើបងស្រីបានឃើញសេចក្តីប្រកាសនេះ ឬបងប្អូនណាបានស្គាល់ ឬបានឃើញឈ្មោះខាងលើនេះ សូមទាក់ទងមកនាងខ្ញុំ តាមអាសយដ្ឋានៈ ៣១៧០ *Serena Avenue CLOVIS, CA 93619 US, Phone: (559) 322-5175/ Cel (559) 301-1888, and Email: www.sovannkuoch@yahoo.com* ។

# ដំណឹងស្វែងរកម្តាយ និងប្អូនប្រុសឈ្មោះ មិន លី

នាងខ្ញុំឈ្មោះ មិន គីមអាង ភេទស្រី អាយុ៥២ឆ្នាំ បច្ចុប្បន្នរស់នៅភូមិត្រពាំងឈូក ឃុំមានរិទ្ធ ស្រុកដងទង់ ខេត្តកំពត។ ម្តាយឈ្មោះ ពៅ សួន ឪពុកឈ្មោះ មិន ម៉ាង ស្លាប់ក្នុងឆ្នាំ១៩៧៩ នៅខេត្តពោធិ៍សាត់។ មានបងប្អូនចំនួន ៥នាក់ ប្រុស ៣នាក់ និង ស្រី ២នាក់។ ១) មិន គីមអាង ភេទស្រី ២) មិន លី ភេទប្រុស (បាត់ខ្លួន) ៣) មិន ដាន ភេទប្រុស (ស្លាប់) ៤) មិន ផល ភេទប្រុស (ស្លាប់) និង ៥) មិន អេង ភេទស្រី (ស្លាប់)។

សូមប្រកាសស្វែងរកម្តាយឈ្មោះ ពៅ សួន និងប្អូនប្រុសទី២ឈ្មោះ មិន លី ដែលបានបែកគ្នាក្នុងពេលរត់ទៅខេត្តពោធិ៍សាត់ មួយខែ មុនពេលកងទ័ពវៀតណាមរំដោះប្រទេសក្នុងឆ្នាំ១៩៧៩។

ប្រសិនបើបងប្អូនញាតិមិត្តណាបានទទួលដំណឹងអ្នកទាំងពីរ សូមមេត្តាជួយផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥។ សូមអរគុណ។



ឈុតមួយនៃការសម្តែងក្នុងរឿងទម្លាយភាពស្ងប់ស្ងាត់

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 111, March 2009 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.